ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៨នាទី**

**សវនាការលើកទី៣៥៤**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2017, 13:44
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជើ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms. Marie GUIRAUD)*

លោក ឡៅ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វូ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក មុយ វ៉ាន់នី (2-TCW-987) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក មុយ វ៉ាន់នី** (2-TCW-987)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី .................... ទំព័រ ៤
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី .................... ទំព័រ ៩
សួរដោយលោក ពេជ អង្គ ផ្តើមពី .................... ទំព័រ ៤៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី .................... ទំព័រ ៥២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.................... ទំព័រ ៥៩
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី.................... ទំព័រ ៦៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:០៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-987។ ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ! មានបញ្ហាបកប្រែភាសាបារាំង? មន្ត្រីរដ្ឋបាលតុលាការ!

ហើយលោក ឯម ហ៊ុយ បន្តការរាយការណ៍បន្តទៀត!

**ក្រឡាបញ្ជី៖**

ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺមានរហស្សនាម 2-TCW-987។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន --

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ! អត់មានភាសាបារាំងដដែល យ៉ាងម៉េចទៅ?

*(មានបញ្ហាបច្ចេកទេស)*

[០៩:១៥:១១]

**ប្រធានអង្គជំនុំ៖**

ហើយធ្វើការបញ្ជាក់ឡើងវិញអំពីដែលការស្បថ និងភាពមិនមានចំណងទាក់ទងញាតិលោហិត ញាតិពន្ធរបស់សាក្សី។

**ក្រឡាបញ្ជី៖**

បាទ លោកប្រធាន។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយ--

**ប្រធានអង្គជំនុំ៖**

បាន១ អត់ទាន់ អត់មាន។ អង្គុយសិនទៅ អត់មានទេ។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយសារមានបញ្ហាបច្ចេកទេស ហើយខាង អេ.វី ហើយអ្នកបច្ចេកទេសស្នើសុំរយៈពេល១៥ ទៅ២០នាទីសិន ដើម្បីរៀបចំសាឡើងវិញលើ ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធសំឡេងទាំងអស់នេះ។ ដូច្នេះអង្គជំនុំជម្រះសម្រេចថា យើងសម្រាករយៈពេល១៥ ទៅ២០នាទី រង់ចាំលទ្ធភាពនៃការអ្នកបច្ចេកទេសរៀបចំជូន ហើយរួចយើងនឹងចូលវិញ។

ឥឡូវសម្រាក២០នាទីចុះ!

*(សវនាការសម្រាកពីម៉ោង ០៩:២០ នាទី ដល់ម៉ោង ០៩:៤៣ នាទី)*

[០៩:៤៣:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាលោក ឯម ហ៊ុយ ឡើងរាយការណ៍បន្តអំពី ពាក់ព័ន្ធជាមួយនឹងបញ្ហាសាក្សី។

**ក្រឡាបញ្ជី៖**

បាទ សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះគឺ មានរហស្សនាម 2-TCW-987។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីព្រឹកមិញ។ សាក្សីមានមេធាវីប្រឹក្សា គឺលោក ឌុច ផារី ប៉ុន្តែលោកអវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ សាក្សីមានវត្តមានរួចហើយនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-988។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា ឬលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:៤៥:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្តទៅនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលនូវលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង

មានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភ័ស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺខ្នង ឈឺចង្កេះ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:៤៦:៣៥]

ហើយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តគឺបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-987 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកមានឈ្មោះអី?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ឈ្មោះ មុយ វ៉ាន់នី។

[០៩:៤៨:៤៧]

**ស៖** អរគុណលោក មុយ វ៉ាន់នី។ តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណា លោកចាំទេ? កុំអាលទាន់ឆ្លើយតប! រង់ចាំក្បាលមីក្រូហ្វូនក្បាលក្រហម ណ៎ះ! ឲ្យសញ្ញាភ្លើងក្រហមសិន បានមានន័យថាប្រតិបត្តិការ ហើយលោក ប្រព័ន្ធសំឡេងរបស់លោកហ្នឹង គឺបែងចែកចាយគ្រប់ភាគីទាំងអស់នៃរឿងក្ដីដំណើរការនេះ ក៏ដូចជាសាធារណជន ឬក៏ជាពិសេស គឺអ្នកបកប្រែភាសាទៅជាភាសាពីរទៀតនៃសម្ដីរបស់លោក ជាភាសាអង់គ្លេស និងភាសាបារាំង។ បង្អង់បន្តិចទៅ ដើម្បីគិតថា តើគួរឆ្លើយតបនឹងសំណួរហ្នឹង យ៉ាងដូចម្ដេច? តើកើតនៅថ្ងៃ ខែ ឆ្នាំ ណា លោកចាំទេ?

**ឆ៖** ថ្ងៃទី០៧ ខែ៦ ឆ្នាំ១៩៦៧។

**ស៖** អរគុណលោក វ៉ាន់នី តើទីកន្លែងកំណើតរបស់លោក នៅទីកន្លែងណា?

**ឆ៖** នៅភូមិអន្លង់អក ឃុំស្វរគង ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** អរគុណ។ ចុះទីលំនៅបច្ចុប្បន្ន តើលោករស់នៅទីកន្លែងណា?

**ឆ៖** នៅភូមិសំបួរមាស “ក” ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** បាទ អរគុណ។ តើលោកប្រកបមុខរបរអ្វីសព្វថ្ងៃនេះ?

**ឆ៖** ជាគ្រូបង្រៀនបឋមសិក្សា។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះ អេង លី។ ម្ដាយឈ្មោះ ឃ្លោក ប៉ាង។

[០៩:៥០:៤០]

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអ្វី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ឈ្មោះ ខេង សុភាព (ស្លាប់) កូនស្រីមួយ។

**ស៖** លោក មុយ វ៉ាន់នី តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២នេះទេ។ តើរបាយការណ៍នេះពិតដែរទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានធ្វើសម្បថហើយ

ឬនៅ នៅចំពោះមុខអ្នកតាដំបងដែក នៃសាលាដំបូង -- នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនៅពីខាងកើតសាលសវនាការនេះ?

**ឆ៖** ខ្ញុំបានធ្វើរួចមកហើយ។

**ស៖** ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក មុយ វ៉ាន់នី ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ ដែលនាំឲ្យដាក់ពិរុទ្ធភាពលើកខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងដែលលោកអះអាងនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោក មុយ វ៉ាន់នី ក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតបទៅរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណា ឬដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោករួចហើយ ក្នុងឋានៈលោកជាសាក្សីអម្បាញ់មិញនេះ។

[០៩:៥២:៤៨]

ហើយក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតែការណ៍ដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោក មុយ វ៉ាន់នី តើលោកធ្លាប់ផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ រយៈពេលកន្លងមក? ហើយប្រសិនបើធ្លាប់ ធ្វើប៉ុន្មានដង? ហើយធ្វើនៅទីកន្លែងណា លោកចាំដែរទេ?

**ឆ៖** ខ្ញុំធ្លាប់បានធ្វើបានពីរដង។ នៅដល់ទីកន្លែង ហើយនិងនៅកន្លែងសាលាក្ដីហ្នឹងម្ដង។

**ស៖** ហើយមុននឹងពេលចូលមកដល់ចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្ដល់ចម្លើយកាលពីពេលមុនចំនួនពីរដង ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ប្រហែលជាបានខ្លះ មើលទៅវាមិនសូវព្យាយាមដែរ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេ ថា

កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំរបស់លោកនោះ ពិតជាត្រឹមត្រូវ ឬក៏ស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីពីរលើកមុននោះដែរឬទេ?

**ឆ៖** មិនដឹងថាយ៉ាងម៉េចទេ ចាំមើលស្តាប់សំណួរសិន ព្រោះវាយូរក្រែលណាស់មកហើយ។

[០៩:៥៥:៥១]

**ស៖** យើងចង់សួរបញ្ជាក់ថា បើលោកបានអាន បានអានខ្លឹមសារដើម្បីរំឭកការចងចាំរបស់លោកឡើងវិញនេះ ខ្លឹមសារដែលលោកផ្តល់សក្ខីកម្មលើកមុនហ្នឹង ដែលលោកបានអានហ្នឹង វាសមស្រប វាដូចគ្នា ឬប្រហាក់ប្រហែលគ្នាទៅនឹងចម្លើយដែលលោកផ្តល់កាលពីពេលមុននោះដែរឬទេ? ចម្លើយ កំណត់ហេតុដែលលោកអានដើម្បីរំឭកការចងចាំនេះ ព្រោះលោកបានផ្តល់សក្ខីកម្មហ្នឹងយូរហើយ ណា៎! រយៈពេលយូរហើយ បួនប្រាំឆ្នាំហើយ។

**ឆ៖** ប្រហាក់ប្រហែល។

**ស៖** បាទ អរគុណ។ ហើយការរៀបចំកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោក អង្គជំនុំជម្រះបាន តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានផ្តល់នូវមេធាវីប្រឹក្សាសាក្សី គឺលោក ឌុច ផារី សម្រាប់អង្គុយក្បែរលោកដើម្បីពិភាក្សាលើបញ្ហាមួយចំនួន ដែលពាក់ព័ន្ធជាមួយនឹងការអនុវត្តសិទ្ធិក្នុងការឆ្លើយតប ដែលមិនឆ្លើយតបនឹងសំណួរ ប៉ុន្តែវាជាអកុសលដោយសារមានការកែប្រែនូវកាលវិភាគសវនាការ ជាហេតុនាំឲ្យលោកមេធាវីប្រឹក្សាសាក្សីគឺលោក ឌុច ផារី គឺមិនអាចចូលរួមនៅសវនាការនៅក្នុងថ្ងៃនេះបាន។ ហើយអង្គជំនុំជម្រះសួរទៅលោកសាក្សីថាលោក មុយ វ៉ាន់នី តើរយៈពេលប៉ុន្មានថ្ងៃ ពីរបីថ្ងៃកន្លងមកនេះ តើលោកធ្លាប់បានជួបពិភាក្សាជាមួយនឹងមេធាវីប្រឹក្សាសាក្សីដែលអង្គជំនុំជម្រះផ្តល់ឲ្យលោកតាមសំណើរបស់លោក តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែរឬទេ?

**ឆ៖** ធ្លាប់បាន។

[០៩:៥៦:៥៦]

**ស៖** លោកបានពិភាក្សាជាមួយគាត់ទេ? លោក មួយជាមួយមេធាវី ឌុច ផារី ដែរទេ? ប៉ុន្មានថ្ងៃនេះ លោកបានជួបជាមួយនឹងលោកមេធាវី ឌុច ផារី ដែលជាមេធាវីប្រឹក្សាសាក្សី គឺដែលតាមសំណើរបស់លោក តើលោកបានជួបគាត់ទេ?

**ឆ៖** បានជួប។

**ស៖** ហើយលោកបានពិភាក្សា ស្ដាប់ប្រឹក្សាយោបល់ជាមួយគាត់យ៉ាងម៉េចទេ អំពីការដែលលោកនឹងឆ្លើយតប ការអនុវត្តនិងករណីយកិច្ចក្នុងការឆ្លើយតបទៅនឹងសំណួរនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ?

**ឆ៖** បានប្រឹក្សាជាមួយគាត់ ហើយគាត់បាននិយាយថា បើអ្វីដែលយើងដឹង អ្វីដែលយើងចងចាំយើងអាចនិយាយបាន។

**ស៖** បាទ អរគុណ។ ហើយលោក មុយ វ៉ាន់នី តើលោកយល់ពាក្យដែលយើងប្រាប់អំពីសិទ្ធិរបស់លោកអំមិញទេ គឺសិទ្ធិមិនឆ្លើយតបទៅនឹងសំណួរ ឬក៏សូមឲ្យលោកធ្វើអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង? តើលោកយល់ពាក្យនេះដែរទេ? ហើយលោកមេធាវីប្រឹក្សាសាក្សី ប្រឹក្សារបស់លោកបានពន្យល់អំពីពាក្យនេះទេ អំពីសិទ្ធិនេះទេចំពោះលោក?

**ឆ៖** បាទ បានពន្យល់ហើយ។

**ស៖** លោកយល់ទេ លោកយល់ច្បាស់លាស់ទេ លើតាមការពន្យល់របស់គាត់?

**ឆ៖** បានច្បាស់ខ្លះ មិនច្បាស់ខ្លះដែរ។

[០៩:៥៩:២៥]

**ស៖** បាទ អរគុណ។ ហើយយើងបញ្ជាក់ឡើងវិញថា សិទ្ធិក្នុងការមិនឆ្លើយតបនឹងសំណួរគឺសំណួរ ឬក៏សូមអត្ថាធិប្បាយណាមួយដែលពីភាគី ឬចៅក្រមសួរ -- ចៅក្រមដែលអ្នកសួរចំពោះលោកហ្នឹង ការប្រើប្រាស់សំណួរ គឺសួរឲ្យលោកឆ្លើយថាលោកដូចជាការលោកចូលរួម ឬក៏លោកប្រព្រឹត្តនូវអំពើអាក្រក់នៅក្នុងរបបនោះដោយផ្ទាល់ ចូលរួមជាមួយនឹងអ្នកដទៃ ឬក៏ប្រព្រឹត្តដោយខ្លួនឯងផ្ទាល់នូវអំពើអាក្រក់ផ្សេងៗដែលកើតមាននៅក្នុងរបបនោះ។ ឧបមាចាប់មនុស្ស សម្លាប់មនុស្សអីអ៊ីចឹង អាហ្នឹងជាសំណួរដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង បានន័យថា វាជាអំពើអាក្រក់ដែលសង្គមគេស្អប់ខ្ពើមដែលជាអំពើខុសច្បាប់។ ហើយសិទ្ធិរបស់លោក គឺលោកអាចឆ្លើយតបដោយ បើសិនជាលោកដឹងរឿងហ្នឹង ហើយលោកមិនបានប្រព្រឹត្តទេ អាហ្នឹងគឺសិទ្ធិរបស់លោក គឺលោកអាចឆ្លើយតបបាន។ ហើយបើសិនជាលោកយល់ថា មិនគប្បីឆ្លើយតបនឹងសំណួរបែបនេះ គឺលោកអាចសម្រេចមិនឆ្លើយតប ឬក៏អាចមួយទៀតដែលយើងផ្ដល់មធ្យោបាយឲ្យលោក គឺលោកអាចធ្វើការសាកសុំសាកសួរទៅមេធាវីរបស់លោក តាមរយៈទូរស័ព្ទបាន។ ហើយប្រសិនបើករណីនេះកើតមាន គឺភាគីអង្គជំនុំជម្រះនឹងមិនឲ្យ -- ឲ្យ

សួរសំណួរផ្សេងទៀត ហើយតម្កល់ទុកនូវសំណួរប្រភេទនេះ សម្រាប់ឆ្លើយនាពេលក្រោយ នៅពេលដែលឱកាសដែលលោកបានឆ្លើយប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីប្រឹក្សារបស់លោករួចហើយ។ ហើយទី២ សំណួរ និងការដែលសុំធ្វើអត្ថាធិប្បាយ ប្រសិនបើមាន មានសួរដូច្នេះហ្នឹងគឺថាអង្គជំនុំជម្រះនឹងពិនិត្យមើលជាក់ស្តែង បើសិនជាលោកអាចសួរមកអង្គជំនុំជម្រះថា សំណួរហ្នឹងប្រភេទម៉េច អាចឆ្លើយបាននោះ អង្គជំនុំជម្រះនឹងពិចារណាពិនិត្យលើបញ្ហានេះជាក់ស្តែង សម្រេចថា ឲ្យឆ្លើយតប ឬក៏មិនឲ្យឆ្លើយតប វាអាស្រ័យលើចរិតនៃសំណួរដែល ឬក៏ការសុំធ្វើអត្ថាធិប្បាយរបស់ភាគីនេះចំពោះលោកនេះ គឺតាមករណីជាក់ស្តែង។ តើលោកអាចយល់បានទេ លោកគ្រូ ជាគ្រូបង្រៀនផង?

**ឆ៖** បាទ អាចយល់បាន។

[១០:០១:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក មុយ វ៉ាន់នី។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយម៍ ដេស្មាឯល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយម៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ វាំងសង់ ឌីវីល។ ខ្ញុំនឹងសួរសំណួរទៅលោកតាងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញានៅព្រឹកនេះ និងរសៀលនេះ។ សូមលោកស្តាប់ឲ្យច្បាស់បើលោកមិនយល់សំណួរសូមលោកប្រាប់ខ្ញុំ។ ហើយសូមលោកកុំឆ្លើយតាមការស្រមើស្រមៃ លោកឆ្លើយនូវអ្វីដែលលោកបានឃើញ និងបានឮ។ អម្បាញ់មិញនេះលោកឆ្លើយថា លោកបានកើតនៅថ្ងៃទី០៧ ខែ៦ ឆ្នាំ១៩៦៧ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ក៏លោកបានឆ្លើយអ៊ីចឹងដែរ។ ដូច្នេះខ្ញុំចង់ដឹងថា តើថ្ងៃខែឆ្នាំកំណើតរបស់លោកនេះត្រឹមត្រូវដែរឬទេ? ហើយវាមាន ឬក៏លោកឆ្លើយតាមថ្ងៃខែឆ្នាំ

កំណើតដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណរបស់លោក?

[១០:០៣:៣០]

**លោក មុយ វ៉ាន់នី៖**

**ឆ៖** បាទ តាមអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំ។

**ស៖** ចុះថ្ងៃខែឆ្នាំកំណើតពិតប្រាកដរបស់លោកហ្នឹង គឺដូចមាននៅក្នុងអត្តសញ្ញាណប័ណ្ណ ឬក៏មាន លោកមានថ្ងៃខែឆ្នាំកំណើតខុសពីនុ៎ង?

**ឆ៖** អត្តសញ្ញាណប័ណ្ណ។ នៅក្នុងអត្តសញ្ញាណប័ណ្ណ។

**ស៖** លោកសាក្សី សូមលោកនិយាយឲ្យខ្លាំងបន្តិច យើងស្តាប់សំឡេងលោកមិនសូវបានទេ។ ឥឡូវនេះ ខ្ញុំសួរអ៊ីចេះវិញ។ លោកចាំទេ ថាលោកមានអាយុប៉ុន្មានពេលលោកទៅធ្វើការនៅវត្តអូរត្រកួន នោះ?

**ឆ៖** ខ្ញុំមិនបានចាំអាយុដែរ ជំនាន់នោះ ខ្ញុំនៅក្មេងពេក។

**ស៖** លោកសាក្សី គឺលោកបានផ្តល់អាយុពីរខុសគ្នា ខ្ញុំនឹងរំឭកនូវអ្វីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទី២ ដែលមានលេខ E319/19.3.93 លោកបានឆ្លើយ<នៅ>ចម្លើយទី៣ថាដូចតទៅ ខ្ញុំសូមដកស្រង់៖ "តាមកាលដែលខ្ញុំចាំកាលនោះ ខ្ញុំអាយុប្រហែល១២ឆ្នាំ ពេលដែលគេបញ្ជូនខ្ញុំពីភូមិទៅវត្តអូរត្រកួន។" សូមបញ្ចប់ការដកស្រង់។ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយទៀត គឺកំណត់ហេតុទី១ គឺចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១១ នៅចម្លើយទី១តែម្តងគឺឯកសារលេខ E319/19.3.219 លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ជំនាន់នោះ ខ្ញុំត្រូវបានគេឲ្យមកនៅក្នុងវត្តអូរត្រកួន ខ្ញុំធ្វើជាកងការពារ ហើយមានអាយុប្រហែលជា១៤ឆ្នាំនៅពេលនោះ។ ខ្ញុំតែងតែទៅតាមប្រធានខ្ញុំនៅពេលដែលគាត់ទៅពិនិត្យមូលដ្ឋានទ័ព។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះបើខ្ញុំគិតមើលទៅតាមអត្តសញ្ញាណប័ណ្ណរបស់លោកទៅ ពេលនោះគឺលោកមានអាយុប្រហែល១១ឆ្នាំ គឺនៅឆ្នាំ១៩៧៨ ក៏ប៉ុន្តែលោកៗបានឆ្លើយម្តងថា១២ឆ្នាំ ម្តងថា១៤ឆ្នាំ <នៅក្នុងបទសម្ភាសន៍ទី២>។ ដូច្នេះលោកអាចនឹក<>ឡើងវិញទៅមើលថា លោកមានអាយុប្រហែលប៉ុន្មាននៅពេលនោះ? គឺខ្ញុំសំដៅទៅឆ្នាំ១៩៧៨ សូមលោកនឹកមើលឡើងវិញទៅមើល។

[១០:០៧:០៧]

**ឆ៖** ពេលនោះ ខ្ញុំវាមិនបានយកចិត្តទុកដាក់រឿងអាយុហ្នឹងដែរ គ្រាន់ថាប៉ាន់ស្មាន ព្រោះខ្ញុំវាអត់

ចេះអីដែរជំនាន់នុ៎ង។ គ្រាន់តែការប៉ាន់ស្មានរបស់ខ្ញុំ ជួនកាលទៅក៏ប្រហែលជា១១, ១២អីហ្នឹង រវាងប៉ុណ្ណឹង ព្រោះមិនដឹង។

**ស៖** បាទ សូមអរគុណ។ មុននឹងចូលទៅសួរអង្គហេតុជាក់លាក់តែម្តង ខ្ញុំសួរអំពីទីកន្លែងរស់នៅរបស់លោក និងការងារជាបន្តបន្ទាប់របស់លោក ក្នុងអំឡុងចន្លោះពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩។ លោក១ថា លោកកើតនៅភូមិអន្លង់អក ឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម។ លោកចាំទេថា តើភូមិរបស់លោកនេះត្រូវបានកាន់កាប់ដោយកងកម្លាំងបដិវត្តន៍នៅឆ្នាំណាដែរ? មុនឆ្នាំ៧៥ មែនទេ?

**ឆ៖** ប្រហែលជាខ្ញុំមិនអាចដឹងដែរ ព្រោះវាមិន១អាចប៉ាន់ ខ្លួនខ្ញុំមិនអាចប៉ាន់ស្មានថា បើនិយាយរឿងឆ្នាំជំនាន់នុ៎ងគឺ ខ្ញុំវានៅមិនយកចិត្តទុកដាក់ មិនដឹងឆ្នាំណា អីឆ្នាំណាអ៊ីចឹងណ៎ា។

**ស៖** ខ្ញុំដឹងហើយថា លោកនៅក្មេងពេលសម័យនោះ។ អ៊ីចឹងលោករស់នៅកន្លែងណាខ្លះ បន្ទាប់ពីលោកចេញពីភូមិអន្លង់អកនោះ? លោកទៅរស់នៅកន្លែងណាខ្លះ?

**ឆ៖** ខ្ញុំបាននៅកងចល័តកុមារ នៅក្នុងភូមិរបស់ខ្ញុំហ្នឹង។ ទៅរួចទៅគេ ខ្ញុំមានរឿងហេតុអីផ្សេង១ដែលខ្ញុំយកបាយយកមកហូបនៅផ្ទះ ហើយមេកងហ្នឹងឲ្យខ្ញុំកាប់ដីកាប់អី ធ្វើទណ្ឌកម្មខ្ញុំអ៊ីចឹងទៅ ក៏គេបញ្ជូនខ្ញុំទៅកងចល័តជាមួយធំ១។ បាទ ពេលនោះយើងខ្ញុំនៅវ័យក្មេងដែរ។

**ស៖** ពេលដែល<លោកនិយាយថា> គេឲ្យលោក<ប្តូរ>ទៅនៅកងចល័តជាមួយមនុស្សធំហ្នឹង លោកចង់សំដៅលើមនុស្សប្រភេទណាដែរ អាយុប្រហែលប៉ុន្មានដែរ? អ្នកដែលលោកថា មនុស្សធំហ្នឹង គឺអាយុចន្លោះពីប៉ុន្មានទៅដល់ប៉ុន្មានដែរ?

[១០:១០:១៦]

**ឆ៖** អាយុពី២០ ទៅ៣០ឆ្នាំ។

**ស៖** ដូច្នេះនៅក្នុងកងចល័តហ្នឹង គឺលោកក្មេងជាងគេបង្អស់មែនទេ?

**ឆ៖** បាទ ជាការពិត នៅក្មេង១។

**ស៖** តើកងចល័តនេះ<>ទៅធ្វើការនៅច្រើនកន្លែងទេ<នៅស្រុកពាមជីកងនោះ> ឬក៏នៅ<>ឈរជើងតែមួយកន្លែង<នៅឃុំណាមួយ>ទេ? លោកអាចជម្រាបពីឈ្មោះកន្លែងដែលលោកទៅធ្វើការនៅក្នុងកងចល័តហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំអាចជម្រាបបាន។ មុនដំបូងខ្ញុំនៅកងចល័តឃុំ រួចបន្ទាប់មកគេបញ្ជូនខ្ញុំទៅកងចល័តស្រុក។ និយាយនៅក្នុងស្រុកទេ។

**សៈ** លោកធ្លាប់ទៅធ្វើការនៅឃុំស្តៅទេ?

**ឆៈ** បាទ ខ្ញុំធ្លាប់ កងចល័តនៅឃុំ នៅក្នុងឃុំស្តៅហ្នឹង។

**សៈ** <តើលោកទៅធ្វើការនៅទីនោះរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំ?> ខ្ញុំដឹងថា វាស្មុគស្មាញបន្តិចនៅពេលដែលលោកគិតអំពីរយៈកាលនោះ ប៉ុន្តែ<និយាយពីប្រហាក់ប្រហែល> តើលោកធ្វើការនៅក្នុងកងចល័តស្រុកហ្នឹង អស់រយៈពេលប៉ុន្មានខែ ឬប៉ុន្មានឆ្នាំដែរ?

**ឆៈ** ខ្ញុំមិនចាំដែរ កងចល័តស្រុកហ្នឹង។ រហូតដល់នៅទាល់តែប្រហែលជាប៉ុន្មានដែរទេ គេហៅខ្ញុំទៅនៅជាមួយគេហ្នឹង។ ខ្ញុំអត់បានចាំ និយាយរួមទៅគឺមិនបានចាំឆ្នាំដែរ មិនបានចាំខែឆ្នាំផង។

[១០:១៣:០៤]

**សៈ** លោកចាំទេថា ប៉ុន្មានខែមុនវៀតណាមវាយចូល ដែលគេបញ្ជូនលោកទៅវត្តអូរត្រកួនហ្នឹង?

**ឆៈ** ប្រហែលជាពីរឆ្នាំជាងអី។

**សៈ** លោកច្បាស់ទេថា លោកធ្វើការអស់រយៈពេលជាងពីរឆ្នាំនៅវត្តអូរត្រកួននោះ? ហើយលោកធ្វើការហ្នឹងក្រោមបង្គាប់របស់ ហាន មែនទេ? បាទ គឺឈ្មោះ ហាន។

**ឆៈ** បាទ ខ្ញុំនៅជាមួយគាត់ ឈ្មោះ ហាន ហ្នឹងមែន។ ជា ហៅថា បើយើងនិយាយសព្វថ្ងៃ គេថាកងអី អង្គរក្ស ការពារមេហ្នឹងទៅសួរសុខទុក្ខទ័ពអីចឹង ទៅមើលទ័ពនៅក្នុង ប្រចាំក្នុងស្រុក តែប៉ុណ្ណឹង។

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយអំពីឈ្មោះ ហាន នេះនៅពេលក្រោយ។ នៅក្នុងឯកសារលេខ E319/19.3.93 លោកបានឆ្លើយដូចតទៅ នៅចម្លើយទី៣៨ ខ្ញុំសូមដកស្រង់៖ “ខ្ញុំធ្វើការជាមួយ ហាន ប្រហែល៥ ឬ៦ខែ <មុន>របបខ្មែរក្រហមដួលរលំ។” សូមបញ្ចប់ការដកស្រង់។ ពេលនោះលោកឆ្លើយជាមួយអ្នកស៊ើបអង្កេតថា ៥ឬ៦ខែ មុនពេលរបបខ្មែរក្រហមដួលរលំ។ ឥឡូវលោកនិយាយថាពីរឆ្នាំ។ ដូច្នេះលោកអាចបញ្ជាក់ឲ្យច្បាស់បានទេ? គឺប្រហែលជាប៉ុន្មានខែ ឬក៏ច្រើនឆ្នាំ?

**ឆៈ** ខ្ញុំស្តាប់សំណួរមិនបានអំមិញហ្នឹង ដល់បញ្ជាក់ប្រាប់វិញ គឺដូចលោកប្រធានបាននិយាយអំមិញអីចឹង ថានៅកងចល័តនោះ វាយូរមកហើយ ដល់អីចឹងទៅ បានវាហៅខ្ញុំមកនៅជាមួយ ប្រហែលជាបីបួនខែហ្នឹងទៀត។

[១០:១៦:០៩]

**ស៖** ដូច្នេះពេលដែលលោកនិយាយថា លោកធ្វើការអស់រយៈពេលជាងពីរឆ្នាំហ្នឹង គឺលោកបូកទាំងពេលដែលលោកធ្វើការនៅកងចល័តស្រុកទៀត ហើយនៅជាមួយ ហាន នៅវត្តអូរត្រកួនហ្នឹង លោកធ្វើការតែប្អូន ប្រាំ ប្រាំមួយខែទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** ពេលដែលលោកធ្វើការជាមួយ ហាន ពេលយប់នោះ លោកសម្រាកនៅវត្តអូរត្រកួន<រាល់យប់> ឬក៏លោក គឺថាសម្រាក<>នៅកន្លែងហ្នឹង<ម្តងម្កាលទេ>?

**ឆ៖** បាទ នៅក្នុងហ្នឹង គឺបានសម្រាកនៅក្នុងអូរត្រកួនហ្នឹង គឺបានតិច។ ច្រើននៅតាមទ័ព។

**ស៖** <ពេលដែលលោកនិយាយថា ជាទូទៅ>លោកសម្រាកជាមួយនឹងទ័ពហ្នឹង លោកសំដៅទៅលើទ័ពស្រុកដែលឈរជើងនៅតាមទីតាំងផ្សេងៗ នៅក្នុងស្រុកកងមាស មែនទេ? ឬក៏លោកនិយាយអំពីទ័ពនៅក្នុងវត្តអូរត្រកួន?

**ឆ៖** ទ័ពនៅតាមឃុំៗ។ មិនមែនទ័ពនៅអូរត្រកួនទេ ទ័ពនៅតាមឃុំ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីតួនាទីរបស់ ហាន ក៏ប៉ុន្តែខ្ញុំចង់ដឹងពេលនេះ គឺមន្ទីររបស់ ហាន ហ្នឹងនៅទីណាដែរ? ហើយតើ ហាន មានមុខងារអ្វីដែរ នៅថ្នាក់ស្រុក?

**ឆ៖** សូមម្តងទៀត។

**ស៖** ខ្ញុំនឹងបំបែកសំណួរជាពីរ។ នៅក្នុងវត្តអូរត្រកួន តើ ហាន មានមន្ទីរនៅទីនោះទេ?

**ឆ៖** បាទ មាន។ មន្ទីរវត្តអូរត្រកួនហ្នឹង គឺកន្លែងសន្តិសុខ ធ្វើជាមន្ទីរតែម្តង។

**ស៖** ហើយ ហាន គាត់មានតួនាអ្វីដែរ នៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួននោះ?

**ឆ៖** ឈ្មោះ ហាន គាត់ជាប្រធានសន្តិសុខមួយស្រុកកងមាស ប្រធានសន្តិសុខស្រុក។

[១០:១៩:៣៦]

**ស៖** អ៊ីចឹងពេលដែលគាត់ជាប្រធានសន្តិសុខស្រុកកងមាសហ្នឹង គាត់ក៏ជាប្រធានមន្ទីរសន្តិសុខវត្តអូរត្រកួនដែរ មែនទេ?

**ឆ៖** បាទ។ ប្រធានសន្តិសុខផង ប្រធានយោធាស្រុកផង ក្តាប់ពីរផ្នែក។

**ស៖** ឥឡូវនេះ ខ្ញុំទៅនិយាយអំពីពេលដែលលោកធ្វើការនៅកងចល័តស្រុកអស់រយៈពេលប្រហែលជាពីរឆ្នាំ។ តើមានយុវជនមកពីភូមិនៃឃុំរបស់លោក ឬក៏មានយុវជនមកពីគ្រប់ឃុំនៃស្រុកកងមាសដែរឬទេ នៅក្នុងកងចល័តរបស់លោកនោះ?

**ឆ៖** បាទ មានចម្រុះគ្នា តាមឃុំមួយៗហ្នឹងមាន។ គេហៅកងចល័តស្រុកហ្នឹង គឺចម្រុះគ្នាចម្រុះគ្រប់ឃុំ។ ប៉ុណ្ណឹង ឃុំខ្លះតិច ឃុំខ្លះច្រើនអ៊ីចឹងទៅ។

**ស៖** អ្នកណាជាប្រធានកងចល័តនោះ?

**ឆ៖** ចង់ភ្លេចឈ្មោះទៀត។ ប្រធានកងចល័តឈ្មោះស្អី។

**ស៖** បាទ ខ្ញុំនឹងរំឮកអំពីឈ្មោះដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺនៅចម្លើយទី៧៣ នៃកំណត់ហេតុ<ស្តាប់ចម្លើយទី២ គឺលេខ> E319/19.3.93 ពេលនោះលោកឆ្លើយថា <“> ប្រធានកងចល័តហ្នឹងឈ្មោះ ឈុន – ឈ-ុ-ន។ ហើយគាត់ហ្នឹង គឺជាប្រធានកងចល័តថ្នាក់ស្រុក។ <”> អ៊ីចឹងលោកចាំឈ្មោះហ្នឹងឡើងវិញទេ ឈ្មោះ ឈុន?

**ឆ៖** បាទ ចាំ។ ដល់រំឮកឡើងវិញអ៊ីចឹងចាំ ឈ្មោះ ឈុន។

[១០:២២:១៥]

**ស៖** តើមានយុវជនប៉ុន្មាននាក់ដែរ នៅក្នុងកងរបស់លោក? ខ្ញុំសំដៅលើក្រុមរបស់លោកផ្ទាល់តែម្តង ខ្ញុំមិនសំដៅទៅលើកងស្រុកទាំងមូលទេ ខ្ញុំចង់ដឹងថាក្នុងក្រុមលោកហ្នឹង មានយុវជនធ្វើការប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** មួយកងខ្ញុំ ប្រហែលជា៣០នាក់ កងចល័ត។

**ស៖** ក្នុងកងលោក ដែលថាមានគ្នាប្រហែល៣០នាក់ហ្នឹង មានជនជាតិចាមទេ? ហើយបើមានមានប៉ុន្មាននាក់ដែរ?

**ឆ៖** មានជនជាតិចាមខ្លះ ប៉ុន្តែខ្ញុំមិនដឹងថា ចំនួនប៉ុន្មាន បើនៅចម្រុះគ្នាអ៊ីចឹង។

**ស៖** នៅក្នុងចម្លើយដដែលដែលខ្ញុំបានដកស្រង់អម្បាញ់មិញនោះ គឺលោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “នៅក្នុងកងខ្ញុំមានសមាជិក៣០នាក់ ក្នុងនោះមានជនជាតិចាម ២៥នាក់។” តើលោកនឹកឃើញឡើងវិញទេ ពាក់ព័ន្ធទៅនឹងចំនួនជនជាតិចាម ដែលមាននៅក្នុងកងរបស់លោកនោះ?

**ឆ៖** បាទ ប្រហែលប៉ុណ្ណឹង វាមិនបានចាំដែរ។

**ស៖** អ៊ីចឹងមានន័យថា <លោកយល់ស្របថាមាន>ជនជាតិចាម<>ភាគច្រើននៅក្នុងកងរបស់លោក មែនទេ?

**ឆ៖** បាទ។

**ស៖** ម៉េចបានជាលោកដឹងថា ពួកគាត់ទាំងអស់ហ្នឹងជាជនជាតិចាម? លោកកំណត់យ៉ាងម៉េច

បានថាពួកគាត់ជាជនជាតិចាម?

[១០:២៤:៣៨]

**ឆ៖** ជួនកាលយើង ការនិយាយស្ដីរបស់គាត់អាចសម្គាល់បាន យើងសួរខ្លះអ៊ីចឹងទៅ សួរសុខទុក្ខ ថាបងនៅឯណា អ៊ីចឹងទៅណ៎ា វាអ៊ីចឹង។

**ស៖** ពេលដែលលោកឮឈ្មោះអ្នកទាំងអស់ហ្នឹង លោកអាចដឹងថាពួកគាត់ហ្នឹងជាចាមទេ? <គឺឈ្មោះខុសពីឈ្មោះខ្មែរមែនដែរឬទេ?>

**ឆ៖** បាទ ដឹង។

**ស៖** ចុះបើគ្រាន់តែមើលរូបរាងកាយខាងក្រៅ លោកគ្រាន់តែក្រឡេកឃើញអ្នកហ្នឹងអ៊ីចឹង លោកអាចបែងចែកដាច់ទេ ថាអ្នកហ្នឹងជាចាម ឬក៏ជាខ្មែរនោះ?

**ឆ៖** អ៊ីចេះដោយសារមិត្តភក្តិនៅជាមួយគ្នា ចេះតែសួរទៅថា បងប្អូនចាមអីអ៊ីចឹង មាននៅជាមួយគ្នាអីអ៊ីចឹង។ រួចដល់ចុងក្រោយមក គេយកបងប្អូនចាមយកទៅអស់អ៊ីចឹងទៅ បានយើងដឹងថាកំណត់ថាចាមមានប៉ុន្មានអីអ៊ីចឹង យើងអត់បានកំណត់ពេលវេលាហ្នឹងទេ គ្រាន់តែថា គេយកចាមទៅមួយចំនួនអ៊ីចឹងទៅ យកទៅបាត់តែហ្មង យកទៅសម្លាប់ចោលពីខ្មែរទៀតទៅ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហានេះនៅពេលក្រោយ។ នៅក្នុងស្រុកកងមាសនោះ តើលោកដឹងថាជនជាតិចាមទាំងអស់ហ្នឹងមកពីភូមិណាខ្លះ? ហើយមានភូមិណាខ្លះដែលមានសុទ្ធតែជាជនជាតិចាមតែម្ដងនោះ? មុនពេល ខ្ញុំសំដៅលើមុនពេលដែលគេរៀបចំជាកងចល័តនោះ។

**ឆ៖** នៅច្រើនអង្គរបាន ហើយនិងឃុំពាមជីកង – ឃុំអង្គរបាន និងឃុំពាមជីកង។ ហើយក៏ភូមិអង្គរបានដែរ ហើយទៅឃុំពាមជីកងមានសាច់ស្ងួ។

**ស៖** នៅក្នុងកងចល័តស្រុក ជាកន្លែងដែលជនជាតិចាម<ក្មេងៗ>ទាំងអស់ហ្នឹងធ្វើការ តើពួកគេមានសិទ្ធិនិយាយភាសាចាមជាមួយគ្នាទេ ឬក៏ពួកគេត្រូវតែនិយាយភាសាខ្មែរដូចគេ ដូចឯងទៀត?

[១០:២៧:៣៩]

**ឆ៖** និយាយតែភាសាខ្មែរ ប៉ុន្តែរាងរដឹនជាង ប៉ៃឡាំៗ។ អត់ហ៊ាននិយាយភាសារបស់គាត់អ៊ីស្លាមហ្នឹងទេ។

**ស៖** ចុះខោអាវវិញ ជនជាតិចាមមានសិទ្ធិស្លៀកខោអាវខុសពីខ្មែរទេ? ហើយពួកគេមានសិទ្ធិគោរពសាសនា ឬក៏ប្រារព្ធពិធីសាសនាចាមអីបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ជំនាន់នោះគឺគ្មានទេបាទ ខ្មែរក៏ដូចចាម ចាមក៏ដូចខ្មែរ គឺអត់មានការគោរពតាមសាសនាអ៊ីចឹងទេ អត់មានបិទ គេហៅថាបិទសាសនាទាំងខ្មែរ ទាំងបងប្អូនចាមតែហ្មង។

**ស៖** អ្នកណាជាអ្នកបំបិទមិនឲ្យនិយាយភាសាចាម ឬមិនឲ្យស្លៀកសម្លៀកបំពាក់ប្រពៃណីចាមនោះ ឬក៏ហាមមិនឲ្យគោរពសាសនាចាម? តើលោកធ្លាប់ឮកម្មាភិបាលខ្មែរក្រហមពិភាក្សាគ្នាអំពីរឿងបំបិទសិទ្ធិហ្នឹងទេ?

**ឆ៖** អត់ដែលឮផង ប៉ុន្តែគ្រាន់តែថាការនិយាយស្ដីគឺគ្មាន អត់មាននិយាយភាសាខុសគ្នានិយាយតែខ្មែរតែមួយ។ ខ្ញុំអត់បានដឹងថាគេអីយ៉ាងម៉េចៗផង។

**ស៖** លោកធ្លាប់ឮកម្មាភិបាលខ្មែរក្រហមនិយាយ<ក្នុងពេលនោះទេ>ថា នៅកម្ពុជាប្រជាធិប-តេយ្យហ្នឹង គឺមិនមានជនជាតិភាគតិចអីផ្សេង ដូចជាចាម ឬក៏វៀតណាមទេ គឺមានតែ<ប្រទេសតែមួយនិង>ជនជាតិតែមួយគត់គឺខ្មែរ។ លោកធ្លាប់ឮកម្មាភិបាលខ្មែរក្រហមនិយាយអ៊ីចឹងទេ?

[១០:៣០:០០]

**ឆ៖** ការនិយាយមិនចាប់អារម្មណ៍ ប៉ុន្តែគ្រាន់តែថា ធ្លាប់នៅជាមួយគ្នាហ្នឹងគឺអត់មាននិយាយពីភាសាខុសគ្នាផង និយាយតែភាសាខ្មែរ។

**ស៖** តើលោកអាចរៀបរាប់អំពីរឿងរ៉ាវ ដែលកើតឡើងចំពោះជនជាតិចាមនៅក្នុងកងចល័តស្រុករបស់លោកនេះបានទេ?

**ឆ៖** បាទ ខ្ញុំអាចរៀបរាប់បានខ្លះ។ កាលពេលនោះ គឺខ្ញុំនៅជាមួយកងចល័តគ្នាឯងហ្នឹងទៅពេលនុំងគេចាត់ខ្ញុំឲ្យទៅច្រូតស្មៅនៅកន្លែងឆ្ងាយ។ ល្ងាចបានមកដល់ យប់អ៊ីចឹង ខ្ញុំឃើញគេចងបណ្ដើរអ៊ីចឹងទៅ ខ្ញុំជិះរទេះគោហ្នឹងមក គឺគេចងទៅ ស្គាល់តែពីរបីនាក់ទេដែលខ្ញុំមើលតាម ព្រោះវាយប់ទៅហើយ។ ដល់ក្រោយមក ខ្ញុំលបមកស្ដាប់នៅផ្ទះដែលខ្ញុំនៅហ្នឹង។ ដល់អ៊ីចឹងទៅខ្ញុំចេញមកក៏ស្ងាត់ជ្រាបនៅតែឃើញតែខ្មែរៗគ្នាឯងហ្នឹងប៉ុន្មាននាក់។ ខ្ញុំសួរថា ពួកហ្នឹងទៅណាអស់ហើយ? គេថា គេចាប់ទៅអស់ហើយ។ រួចចុះម៉េចយើង? ថា យើងអត់អីទេ ថាអ៊ីចេះ។ អ៊ីចឹងវាដឹងគោលដៅអ្វីដែលចាម ឬក៏ខ្មែរអីវាដឹងៗ មុខ ប្រវត្តិរូបហ្នឹងអស់ហើយ។

**ស៖** ពេលដែលមានការចាប់ខ្លួនជនជាតិចាមទាំងអស់ហ្នឹង លោកនៅក្នុងភូមិអី ឃុំអីដែរ?

**ឆ៖** នៅក្នុងឃុំស្ដៅ។

**ស៖** ពេលដែលលោកចូលទៅកន្លែងដែលលោកសម្រាកនោះ លោកឃើញ<មនុស្ស>សល់

ប៉ុន្មាននាក់ដែរ? ហើយខ្មែរអីសល់ប៉ុន្មាននាក់ដែរ?

[១០:៣២:២៨]

**ឆ៖** គឺអត់មានសល់ផង នៅតែខ្មែរៗ និយាយទៅ។

**ស៖** លោកចាំទេ ពេលដែលលោកចូលទៅកន្លែងលោកសម្រាកនោះ លោករាប់ទៅឃើញជនជាតិខ្មែរយើងសល់ប្រហែលប៉ុន្មាននាក់?

**ឆ៖** ខ្ញុំអត់បានរាប់ផង ប៉ុន្តែគ្រាន់ថាដឹងថាគេប្រមូលចាមទៅ កងចល័តដែលនៅជាមួយគ្នាគឺប្រមូលទៅអស់ទៅហើយ។ ដឹងតែប៉ុណ្ណឹង គឺយើងភ័យខ្លួនយើងដែរ មិនបានរាប់គ្នា គ្រាន់ថាគ្នាយើងថានៅ តែយើងអ៊ីចឹង ដល់ពេល -- តែខ្មែរអ៊ីចឹង។

**ស៖** ចុះឪពុកម្តាយរបស់ជនជាតិចាម<>ដែលគេចាប់ខ្លួននៅថ្ងៃនុ៎ង ឪពុកម្តាយ ឬក្រុមគ្រួសាររបស់ពួកគេនោះ លោកដឹងទេថា មានរឿងហេតុអ្វីកើតឡើងដែរចំពោះសាច់ញាតិ ឬក៏ឪពុកម្តាយរបស់ជនជាតិចាមដែលគេចាប់ខ្លួនទៅហ្នឹង?

**ឆ៖** បាទ គឺអត់បានដឹងផង អត់បានដឹង។ គ្រាន់ថាដឹងនៅជាមួយគ្នា ប៉ុន្តែឪពុកម្តាយខាងកងចល័តហ្នឹងគឺអត់ដឹងថា ឪពុកម្តាយគេយកទៅមុន ឬយកទៅក្រោយ ឬក៏យកស្មើគ្នា គឺអត់ដឹង។

**ស៖** ចុះក្រោយមកទៀតនោះ លោកដឹងទេ ឧទាហរណ៍ដូចជាក្រោយឆ្នាំ<៧៩>មកនោះ លោកដឹងអំពីហេតុការណ៍ដែលបានកើតឡើងចំពោះសាច់ញាតិរបស់ក្មេងៗចាមទាំងអស់ហ្នឹងទេ?

**ឆ៖** អត់បានដឹងទេ គ្រាន់ថាគេប្រមូលចាមៗអ៊ីចឹង យើងវាអត់ដឹងថាយ៉ាងម៉េចទៅទៀតហ្នឹង ពីព្រោះយើងវានៅអត់បានដែលទៅលេងនៅផ្ទះផងហ្នឹង។ ផ្ទះសុទ្ធតែនៅបែកៗពីគ្នា ចាមនៅផ្សេងទៅ រួចមិនដែលបានទៅ ហើយគ្រាន់ដឹងថាឪពុកម្តាយរបស់គេហ្នឹងអីយ៉ាងម៉េចៗ គឺអត់ដឹង។

[១០:៣៥:២៣]

**ស៖** <នៅក្នុងអំឡុងពេល>ប៉ុន្មាន<សប្តាហ៍ ឬប៉ុន្មាន>ថ្ងៃ<>ដែលគេចាប់ជនជាតិចាម<ដែលធ្វើការជាមួយលោក>ទាំងនោះ តើលោកបានដឹងថាពួកចាមទាំងអស់នោះ មានការភ័យខ្លាចថា គេនឹងមានមកចាប់ខ្លួនទេ ឬក៏ពួកគេ<ភ្ញាក់ផ្អើល>ទេ <នៅពេលគេចាប់ខ្លួន>ជនជាតិចាមទាំងអស់ហ្នឹង<នៅពេលយប់នោះ>? សូមលោកឆ្លើយតែអ្វីដែលលោកដឹង បើលោកមិនដឹងលោកឆ្លើយថាមិនដឹង។ <មិនមានបញ្ហាទេ។>

**ឆ៖** បាទ គឺខ្ញុំអត់បានដឹងការចាប់មុន ឬក៏ក្រោយ គឺអត់មានដឹងទេ។ ស្រាប់ដល់ហ្នឹងគឺចាប់តែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម្តង អ៊ីចឹងតែម្តង ប្រមូលទៅតែម្តង។

**ស៖** លោកឆ្លើយថាលោកបានទៅកន្លែងលោកសម្រាកវិញ ហើយលោកឃើញគេ<កំពុងតែ> ចាប់ជនជាតិចាមទៅអស់ <ហើយគេឲ្យឈរជាជួរ>។ ពេលនុ៎ង ពេលគេចាប់ហ្នឹង <>លោកមាន ឃើញជនជាតិចាមណាម្នាក់ព្យាយាមតដៃ ឬក៏រត់គេចអីទេ?

**ឆ៖** អត់បានឃើញផង ព្រោះយើងជួបកណ្តាលផ្លូវទេ ដែលៗខ្ញុំស្គាល់មើលពីលើរទេះហ្នឹង។ ដល់មកយប់ព្រលប់ទៅ ខ្ញុំអត់ហ៊ានចូល ខ្ញុំមកស៊ើបសួរអ្នកមកនោម មកក្រោមហ្នឹង វាងស្ងាត់មនុស្ស ខ្ញុំលបសួរ ឮថាគេចាប់បងប្អូនចាមទៅអស់ហើយ។ ហើយពួកហ្នឹងអត់ឃើញសកម្មភាពដែរ បងប្អូន ចាមតដៃ ឬក៏យ៉ាងម៉េច គឺអត់បានដឹង ព្រោះខ្ញុំនៅមុខព្រួញផ្សេងគ្នា គេចាត់ឲ្យទៅច្រូតស្មៅ ដល់ឃើញ ត្រឡប់មកវិញបានឃើញ ហើយពេលយប់ហូបបបរអីរួច បានគេចាប់ទៅ យើងអត់បានដឹង។

[១០:៣៧:២៨]

**ស៖** អ្នកណាដែលជាអ្នកចាប់ខ្លួន រួចបណ្តើរជនជាតិចាមទាំងអស់ហ្នឹងទៅហ្នឹង?

**ឆ៖** អត់ស្គាល់។ មិនដឹងពួកខាងណាគេមក ខ្ញុំអត់ស្គាល់ផង រួចយើងក៏មិនហ៊ានសួរជជីកថា អ្ហែ! ខាងណេះ មកចាប់ខាងណោះមកចាប់ គឺអត់ដឹង។

**ស៖** នៅក្នុងចម្លើយលេខ៧៣ ដែលខ្ញុំបានដកស្រង់មុនហ្នឹង លោកបាននិយាយថា <ជាពួករក្សា សន្តិសុខ ឬ>ពួកឈ្លប។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ ថាអ្នកដែលមកចាប់ហ្នឹង គឺជាពួកឈ្លបមែន ទេ?

**ឆ៖** បាទ ក្នុងការប៉ាន់ស្មានរបស់ខ្ញុំ ប្រហែលជាពួកឈ្លបហើយ ព្រោះក្រៅពីហ្នឹងអត់មានពី ណាពីណី ឬក៏ឈ្លបភូមិ ឬឃុំម៉េចមិនដឹង។ ខ្ញុំមិនសូវយកចិត្តទុកដាក់ស្តាប់ នេះដែរ មិនសូវជានេះ ព្រោះ ជំនាន់ហ្នឹងរកតែទុកតែខ្លួនដែរ។

**ស៖** មិនអីទេលោក។ ប៉ុន្តែនៅពេលក្រោយមក លោកធ្វើការនៅវត្តអូរត្រកួន ហើយបន្ទាប់មក ទៀត ថាតើលោកអាច<ស្គាល់នរណាម្នាក់>នៅក្នុងចំណោមសន្តិសុខដែលលោកឃើញទាំងអស់ហ្នឹង ដែលធ្វើការនៅវត្តអូរត្រកួន ឬមួយក៏ធ្វើការនៅក្នុងភូមិ នៅក្នុងឃុំ ក្នុងនាមជាឈ្លប<ដែរឬទេ?> តើ លោកធ្លាប់ឃើញមុខពួកគេដែរឬទេ? ហើយប្រសិនបើលោកធ្លាប់ឃើញមុខពួកគេ តើនៅពេលក្រោយ មកទៀត លោក<ស្គាល់អ្នកណាខ្លះដែរ>ទេ?

**ឆ៖** បាទ ពេលនោះគឺខ្ញុំធ្លាប់ឃើញ ប៉ុន្តែដល់ឥឡូវហ្នឹងវាបែកខ្ញែកគ្នាទៅ គ្រាន់តែថាស្គាល់ម្នាក់

ប៉ុន្តែស្លាប់ទៅហើយ។ បាទ ឈ្មោះ ហ៊ាន់។

[១០:៤០:០១]

**សៈ** តើ ហ៊ាន់ ដែលលោកនិយាយហ្នឹង ថាតើគាត់នៅក្នុងកងអ្វីដែរ? ថាតើគាត់នៅក្នុងថ្នាក់ឃុំ ថ្នាក់ស្រុក ឬមួយក៏គាត់ធ្វើការនៅវត្តអូរត្រកួន?

**ផៈ** គាត់ហ្នឹងធ្វើការនៅវត្តអូរត្រកួនតែម្ដង។

**សៈ** នៅចម្លើយ៧៣របស់លោក គឺឯកសារ E319/19.3.93 លោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "គឺកើតឡើងប្រហែលនៅ -- គឺហេតុការណ៍នេះ កើតឡើងនៅយប់មួយដែលខ្ញុំនៅជាមួយបងប្អូនចាម វេលាម៉ោងប្រហែលប្រាំបីប្រាំបួន មានក្រុមសន្តិសុខបានមកដល់កន្លែងពួកយើងស្នាក់នៅភូមិស្ដៅ ឃុំស្ដៅ ស្រុកកងមាស។ គេបាន<បញ្ជា>ឱ្យប្រធានកង<ហៅជនជាតិ>ចាមទាំងអស់ ហៅមកប្រជុំនៅលើផ្ទះមួយ។ បន្ទាប់មកជនជាតិចាមទាំងអស់នោះ ត្រូវបានគេចង ហើយបញ្ជូនចេញពីកន្លែងនោះ។ ប្រធានកងចល័តឈ្មោះ ឈុន គឺជាកងចល័តថ្នាក់ស្រុក។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះតើលោកបានឃើញគេចាប់ចងជនជាតិចាមទាំងអស់នោះ ដោយផ្ទាល់ ឬមួយក៏លោកឮគេប្រាប់ទេ?

**ផៈ** ខ្ញុំអត់បានឃើញផ្ទាល់ទេ សកម្មភាពហ្នឹង គ្រាន់ថាយើងមកពាក់កណ្ដាលផ្លូវ ឃើញស្គាល់តែម្នាក់ ពីរនាក់ ព្រោះវាងងឹតផងអីផង ដើរវាច្រើន ដឹងចងទាំងខ្សែៗ។ យើងអត់ហ៊ានមើលទៀត គ្រាន់តែក្រឡេកកន្ទុយភ្នែក ឃើញស្គាល់ម្នាក់ហ្នឹង។ ដល់ត្រឡប់មកពីបាយទឹកអី យប់អីចឹងទៅ ក៏ខ្ញុំ ដូចខ្ញុំខាងដើមថា គេចាប់បងប្អូនចាមទៅអស់ហើយ។

**សៈ** ប៉ុន្តែលោកទើបតែនិយាយថា លោកបានឃើញពួកគេ គឺឈរជាជួរ ហើយត្រូវបានគេចង ហើយលោកចាំពួកគេ<ម្នាក់ ឬ>ពីរនាក់។ ដូច្នេះ តើលោកចាំឈ្មោះអ្នកដែលលោកស្គាល់នៅពេលល្ងាចហ្នឹងដែរឬទេ តើគេឈ្មោះអ្វី?

[១០:៤២:៥១]

**ផៈ** ដូចជាភ្លេច -- ដូចគ្មានផង ព្រោះគេយកទៅពាក់កណ្ដាលផ្លូវទៅហើយ បានឃើញ ឃើញគេចងបណ្ដើរទៅហើយ ដែលខ្ញុំជិះរទេះដឹកស្មៅត្រឡប់ពីម៉ោងប្រាំមួយ ប្រាំពីរហ្នឹង។

**សៈ** ដូច្នេះខ្ញុំនៅចង់សួរលោកដដែល លោកបាននិយាយថា លោកបានឃើញពួកគេ។ ដូច្នេះនៅពេលដែលលោកឃើញពួកគេហ្នឹង តើនៅពេលដែលលោកឃើញហ្នឹង ពួកគេហ្នឹងត្រូវបានគេចង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយឬនៅ?

**ឆ៖** បាទ គេបណ្ដើរទៅហើយៗ។ គ្រាន់តែដឹងថា គេចង គេបណ្ដើរទៅរាប់គីឡូដី បានខ្ញុំមកជួបពាក់កណ្ដាលអីអ៊ីចឹងណា។

**ស៖** មិនអីទេលោក។ បើសិនបើខ្ញុំយល់មិនខុសទេគឺបានន័យថា លោកទៅភូមិវិញ ហើយលោកបានឃើញពួកគេនៅតាមផ្លូវ ហើយពួកគេទាំងអស់នោះត្រូវបានគេបណ្ដើរចេញពីភូមិទៅ។ អ៊ីចឹងមានន័យថា ពួកគេទាំងអស់ហ្នឹង ត្រូវបានគេចាប់ខ្លួន ហើយបណ្ដើរចេញទៅហើយ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបអំមិញថា គេចងរួចទៅហើយ បានខ្ញុំឃើញពាក់កណ្ដាលផ្លូវនុ៎ង ជួបពាក់កណ្ដាលផ្លូវហ្នឹង អាសកម្មភាពដែលកំពុងហៅអីយ៉ាងម៉េចៗ អត់បានឃើញទេ។

[១០:៤៥:០៦]

**ស៖** មិនអីទេ។ មុននេះបន្តិចលោកបាននិយាយថា គឺងាយស្រួលក្នុងការស្គាល់ថា អ្នកណាចាមអ្នកណាមិនចាម ដោយសារតែសំឡេង ដោយសារតែភាសា <និងឈ្មោះ>។ ដូច្នេះខ្ញុំចង់សួរលោកថាតើលោកធ្លាប់ដឹងអំពីការស្រង់បញ្ជីឈ្មោះចាមនៅក្នុងកងចល័ត នៅក្នុងឃុំ ភូមិ នៅក្នុងស្រុករបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ក៏ប៉ុន្តែដល់ពេលដែលយកទៅ ព្រោះយើងអត់មានតួនាទីអី ធ្វើស្ថិតិហ្នឹង ដូចខ្ញុំនិយាយថា ធ្វើស្ថិតិហ្នឹង គឺយើងអត់ដឹង។ មានតែប្រធានកង អីក៏អីអ៊ីចឹងទៅណា បានគេដឹង។

**ស៖** តើលោកដឹងទេថា គេយកពួកយុវជនចាមហ្នឹងទៅទីណាដែរ? ហើយថាតើពួកជនជាតិចាមហ្នឹងជួបប្រទះនូវជោគវាសនាបែបណាដែរ នៅចុងក្រោយ?

**ឆ៖** នៅពេលនោះឯង ក្រោយពីប៉ុន្មានថ្ងៃមក ចេះតែឮតគ្នាអ៊ីចឹងទៅ គេថាយកទៅសម្លាប់ចោលអស់ ប៉ុនមិនដឹងស្លាប់នៅកន្លែងណា។ ថានៅ អ្នកខ្លះគេថានៅវត្តស្ដៅ ក៏មិនដឹង អីមិនដឹង ព្រោះយើងកំពុងកាលហ្នឹង កំពុងស្លុតដែរ ឃើញគេចាប់ទៅ ក្រែងលោយើងទៀត។ ចេះតែនាំគ្នាបារម្ភ។

**ស៖** លោកនិយាយនៅក្នុងចម្លើយ៧១ គឺនៅក្នុងឯកសារ E319/19.3.93 លោកបាននិយាយដូចតទៅនេះ៖ "ខ្មែរក្រហមប្រមូលយុវជន យុវនារី<ជនជាតិចាមនៅ>ក្នុងកងរបស់ខ្ញុំទាំងអស់ បញ្ជូនយកទៅសម្លាប់នៅវត្តអូរត្រកួន។ កាលនោះចំពោះយុវជន យុវនារីខ្មែរមិនមានរឿងអ្វីកើតឡើងទេ។" ដូច្នេះខ្ញុំចង់ដឹងថា នៅពេលក្រោយមក លោកមានទទួលព័ត៌មានអ្វីដែរឬទេ ដែលថាយុវជន យុវនារីចាមហ្នឹង ត្រូវបានគេយកទៅសម្លាប់នៅវត្តអូរត្រកួន ដូចដែលលោកឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ

ជាមួយសហចៅក្រមស៊ើបអង្កេតនោះ? តើអ៊ីចឹងមែនទេ?

[១០:៤៧:៥៨]

**ឆ៖** ដូចជាមិនបានដឹងដែរ អត់បានដឹង។

**ស៖** នៅក្នុងចម្លើយដដែលនេះ ដែលក្នុងចម្លើយនោះលោកនិយាយយ៉ាងច្បាស់ គឺចម្លើយ៧៣៖ "តាមដែលលោកដឹង តើការចាប់ខ្លួនក្មេងៗ ជនជាតិចាមនោះធ្វើឡើងដោយរបៀបណា? ហើយលោកឆ្លើយថា៖ នៅថ្ងៃបន្ទាប់មក គេបានប្រាប់យើងថា ក្មេងៗចាមទាំងនោះត្រូវបានបញ្ជូនទៅវត្តអូរត្រកួន។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះនៅពេលនុ៎ងលោកហាក់ដូចជាច្បាស់លាស់ថា គេបញ្ជូនពួកទាំងអស់នោះទៅវត្តអូរត្រកួន ប៉ុន្តែឥឡូវនេះ លោកនិយាយថា លោកដឹងតែគេចាប់ខ្លួនចាម ប៉ុន្តែលោកមិនដឹង ឬលោកមិនប្រាកដថាគេបញ្ជូនទៅវត្តនោះទេ?

**ឆ៖** ខ្ញុំមិនអាចដឹងថា គេបញ្ជូនទៅខាងណាអី ប៉ុន្តែក្រោយពីបាត់ចាមហ្នឹង ប្រហែលជាបីបួនថ្ងៃ ឮល្បៀងៗតាមខ្សឹបប្រាប់គ្នាថា គេយកទៅសម្លាប់ ប៉ុន្តែមិនដឹងសម្លាប់នៅកន្លែងណា ក៏យើង -- ប៉ុន្តែពួកហ្នឹងឮខ្សឹបទៅថា យកទៅសម្លាប់នៅវត្តស្ដៅ នៅក្នុងឃុំស្ដៅ ប៉ុន្តែមិនដឹងកន្លែងណា តំបន់។ គ្រាន់តែថានៅឃុំស្ដៅហ្នឹង ព្រោះខ្ញុំនៅហ្នឹងស្ដៅហ្នឹងដែរ កងចល័តជាមួយគ្នា ប៉ុនចេះតែឮខ្សឹបខ្សៀវៗ ព្រួយបារម្ភ ផងអីផង។

**ស៖** មិនអីទេ <ខ្ញុំយល់ តើ>លោក--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ បាទ ឥឡូវនេះពេលវេលាសមស្របសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សវនាការសម្រាកពីម៉ោង ១០:៥១ នាទី ដល់ម៉ោង ១១:០៤ នាទី)*

[១១:០៤:០២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកបាននិយាយអំពីការចាប់ខ្លួនយុវជនចាម<ទាំងអស់>នៅក្នុងកងចល័ត<>របស់លោក។ ដូច្នេះនៅពេលក្រោយមកទៀតនោះ ខ្ញុំចង់ដឹងថា លោកធ្លាប់ឃើញជនជាតិចាមទាំងអស់ហ្នឹងវិញទេ ឬក៏ពួកគាត់បាត់ខ្លួនរហូតតែម្ដង?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** បាទ ពេលនោះគឺបាត់ខ្លួនតែម្ដង។

**ស៖** ចុះលោកដឹងទេថា ក្មេងៗ ឬក៏យុវជន យុវនារីចាមផ្សេងទៀតនោះនៅក្នុងកងផ្សេង ដូចជាកងចល័ត ឬក៏កងកុមារផ្សេងដែលនៅក្នុងស្រុកហ្នឹងមានត្រូវបានគេចាប់ខ្លួនដែរឬទេ?

[១១:០៥:៥១]

**ឆ៖** អត់បានដឹងដែរ ព្រោះយើងនៅតែមួយកន្លែងៗមិនអាចដើរឆ្វេចឆ្វាចបានអ៊ីចឹង។ មិនដឹងជាកន្លែងណាខ្លះគេចាប់ កន្លែងណាខ្លះគេមិនចាប់អ៊ីចឹង។ គ្រាន់តែថា ភាគច្រើនគឺគេប្រមូលអ៊ីចឹងតែម្ដងតាមកន្លែងមួយៗ។ ដូចយើងអត់មានសិទ្ធិដើរហើរទៅពីឃុំមួយ ទៅភូមិមួយផងហ្នឹង។ ដើរទៅធ្វើការបើថានៅកន្លែងណាមួយ នៅឃុំណាមួយនៅតែឃុំហ្នឹង។

**ស៖** <ខ្ញុំយល់ហើយថា លោកមិនដឹងអ្វីទេនៅក្នុងពេលនោះ> ចុះលោកធ្លាប់ឮគេនិយាយគ្នាទេនៅក្រោយឆ្នាំ១៩៧៩នោះ ឬក៏លោកអាចធ្លាប់ពិភាក្សាជាមួយអ្នកណាដែលអាចនាំឲ្យលោកដឹងថា នៅ

<ក្នុងស្រុកកងមាស>តាមកងផ្សេងៗទៀតនុំងក៏គេមានការចាប់ខ្លួនជនជាតិចាមនុំងដែរនោះ?

**ឆ៖** ដូចជាមិនបានដឹងៗ។

**ស៖** ដូច្នេះជារួមពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ នៅក្នុងស្រុកកងមាស តើមានជនជាតិចាមណាអាចនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះលោកប្រធាន ព្រោះថាសាក្សីហ្នឹងគាត់មិនមានតួនាទីអ្វីអាចឆ្លើយទៅនឹងសំណួរនេះឡើយ។ គាត់អាចយ៉ាងច្រើនត្រឹមតែនិយាយអំពីសមាជិកជនជាតិចាមនៅក្នុងកងចល័ត<របស់គាត់>នៅក្នុងឃុំ ឬក៏ស្រុក ប៉ុន្តែចំពោះការដឹងបែបនេះគឺថា គាត់មិនអាចដឹងបាននោះឡើយ <>ដោយសារតែពេលនោះគាត់ទើបតែមានអាយុ១០ ឬក៏១១ឆ្នាំប៉ុណ្ណោះ។

[១១:០៨:០៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសួរតែអ្វីដែលគាត់ដឹងតែប៉ុណ្ណោះ <ខ្ញុំមិនបានសួរគាត់ឲ្យឆ្លើយស្មានទេ>។ ខ្ញុំចង់ដឹងថា ខ្លួនគាត់ហ្នឹង គាត់ដឹងថាមានជនជាតិចាមណាខ្លះដែលនៅរស់រានមានជីវិតដែរឬទេ នៅក្នុងស្រុករបស់គាត់នេះ? ខ្ញុំគិតថាសំណួរហ្នឹងដូចជាមិនមានបញ្ហាអ្វីទេ <ហើយសាក្សីអាចឆ្លើយនូវអ្វីដែលគាត់ដឹង>។ ដូច្នេះ ខ្ញុំគួរតែអនុញ្ញាតឲ្យសួរសំណួរនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ចំពោះសំណួរនេះ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរ។ សាក្សីអាចឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិចុងក្រោយអម្បាញ់មិញនេះ ហើយប្រសិនបើលោកអាចឆ្លើយបាន។

**លោក មុយ វ៉ាន់នី៖**

**ឆ៖** បាទ មាននៅសល់ម្នាក់ដែរ។ ពីរនាក់ប្តីប្រពន្ធហ្នឹង គាត់រត់ចូលព្រៃ រត់ចូលបឹង គាត់រត់ចូល សម្ងំចូលបឹងស៊ីខ្យង ស៊ីក្តាមអីចឹងទៅ ដល់ពេលដាច់បានដឹងថា គាត់ហ្នឹងមាននៅម្នាក់ នៅទាល់

រាល់ថ្ងៃហ្នឹង។

**ស៖** តើលោកដឹងទេថា ពីរនាក់ប្ដីប្រពន្ធហ្នឹងមកពីភូមិណា? ហើយគាត់ឈ្មោះអ្វី?

**ឆ៖** គាត់នៅសាច់ស្ង នៅឃុំពាមជីកង។

[១១:០៩:៤៤]

**ស៖** ក្រៅពីប្ដីប្រពន្ធទាំងពីរនាក់នេះ លោកមិនបានដឹងថាមានអ្នកណាផ្សេងទៀត<នៅស្រុកកងមាស>ដែលជាជនជាតិចាមហ្នឹងនៅរស់រានមានជីវិតទេ មែនទេ?

**ឆ៖** បាទ ជាការពិត។ ដល់ពេលដាច់ហើយ ដឹងថា គាត់នៅតែម្នាក់ ពីរនាក់ប្ដីប្រពន្ធគាត់ហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីវត្តអូរត្រកួន និងពេលដែលលោកត្រូវបានបញ្ជូនទៅធ្វើការនៅវត្តអូរត្រកួន គឺលោកធ្វើការនៅក្រោមបង្គាប់របស់ ហាន <>លោកជាកងការពាររបស់ ហាន។ <ហានជាប្រធានមន្ទីរសន្តិសុខ ហើយគាត់ក៏ជាមេសន្តិសុខស្រុកដែរ ដូចអ្វីដែលលោកបានរៀបរាប់អម្បាញ់មិញនេះ។> ខ្ញុំចង់ដឹងថាតើមន្ទីរសន្តិសុខអូរត្រកួននេះ ស្ថិតនៅក្រោមបង្គាប់ថ្នាក់ណា? ថ្នាក់ឃុំ ឃុំពាមជីកង ឬក៏ថ្នាក់ខ្ពស់ជាងឃុំនេះទៅទៀត?

**ឆ៖** សន្តិសុខហ្នឹង គឺសន្តិសុខស្រុក មួយកងមាសហ្នឹងហ្មង។ អូរត្រកួនហ្នឹងគឺសន្តិសុខស្រុក។

**ស៖** តើវត្តនេះស្ថិតនៅជិតមន្ទីរ<គណៈ>ស្រុកកងមាសដែរឬទេ?

**ឆ៖** នៅជិតប្រហែលជា២គីឡូអី បើតាមស្មាន ប្រហែល២គីឡូពីវត្តទៅស្រុក។

**ស៖** <តាមលោកនិយាយ ខ្ញុំមិនច្បាស់ថាវត្តហ្នឹងនៅក្នុងភូមិអី។> លោកបាននិយាយថា វត្តនេះស្ថិតនៅក្នុងឃុំពាមជីកង <ប៉ុន្តែលោកមិនបានប្រាប់ថានៅក្នុងភូមិអ្វីនោះទេ។> ឥឡូវហ្នឹងខ្ញុំចង់ដឹងពីភូមិ តើវត្តហ្នឹងស្ថិតនៅក្នុងភូមិអីកាលពីសម័យនោះ? ហើយចុះសម័យឥឡូវនេះវិញ វត្តហ្នឹងស្ថិតនៅក្នុងភូមិអីដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

សំណួរម្ដងទៀតលោកសហព្រះរាជាអាជ្ញារងអន្តរជាតិ! សំណួរចុងក្រោយរបស់លោកគាត់ឆ្លើយហើយ ប៉ុន្តែឆ្លើយនៅក្នុងអំឡុងពេលដែលក្បាលមីក្រូហ្វូនមិនប្រតិបត្តិការ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំចង់ដឹងថា តើវត្តអូរត្រកួននេះស្ថិតនៅក្នុងភូមិអី?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ភូមិសំប្ញូរមាស "ក"។

[១១:១៣:១៣]

**ស៖** ម៉េចបានជាគេជ្រើសរើសយកលោកឲ្យទៅធ្វើការនៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួន? តើមានហេតុផលអ្វី? តើគេជ្រើសរើសហ្នឹង គេជ្រើសយ៉ាងម៉េច?

**ឆ៖** ខ្ញុំអត់បានដឹងដែរពេលនោះគឺ ខ្ញុំនៅជា នៅគេហៅថា កងចល័ត។ កងចល័តហ្នឹង វាអត់បាយពេក ខ្ញុំស្ម័គ្រចិត្តថា អ្ហេ! ទៅធ្វើទ័ព។ ក៏សួរអ៊ីចឹង សួរប្រវត្តិខ្ញុំថា មានបងប្អូនប៉ុន្មាននាក់? នៅភូមិណាអីអ៊ីចឹងទៅ ក៏ហើទៅ។ គឺខ្ញុំអត់ចាប់អារម្មណ៍ថាអីយ៉ាងម៉េច ហើយដល់ឮគេក្រោយមក គេហៅមេៗកងរបស់ខ្ញុំហ្នឹង គេថា "ណំ! បងគាត់ឲ្យហៅ អ្អែងទៅនៅអូរត្រកួនហើយ"។ ឮអ៊ីចឹង ខ្ញុំមានការតក់ស្លុត ព្រោះឮដំណឹងហ្នឹងមក គឺថាវាកន្លែងសម្លាប់មនុស្សទៅហើយ។ ដល់អ៊ីចឹងវាហៅខ្ញុំទៅៗ នៅ។

**ស៖** ពេលដែលលោកទៅដល់មន្ទីរសន្តិសុខវត្តអូរត្រកួន ឬកន្លែងសម្លាប់មនុស្សវត្តអូរត្រកួននោះ តើលោកដឹងទេថា <មាន>សន្តិសុខផ្សេងទៀតហ្នឹង អាយុច្រើនជាងលោកទេ ឬក៏ខ្ញុំចង់បានន័យថា លោកក្មេងជាងគេបង្អស់មែនទេ ក្នុងចំណោមកងសន្តិសុខទាំងអស់ហ្នឹង?

**ឆ៖** បាទ គេមានអាយុច្រើន។ មានសាមជាង មានសែជាងអីអ៊ីចឹង តាមខ្ញុំប៉ាន់ស្មាន ព្រោះខ្ញុំជាក្មេងជាងគេ។

**ស៖** មានអ្នកណាដែលមានអាយុ១៦, ១៧, ១៨ឆ្នាំអីទេ ក្នុងចំណោមកងសន្តិសុខទាំងអស់ហ្នឹង?

**ឆ៖** អត់មានផង មានតែខ្ញុំពីរនាក់សម្រាប់ ដូចថាដូរដោះគ្នាការពារណ៎ា។ មេទៅណាអ៊ីចឹងទៅយើងជិះម៉ូតូក្រោយគេអ៊ីចឹងទៅ ទៅពិនិត្យទ័ព ទៅមើលទ័ពអីអ៊ីចឹងទៅ។

[១១:១៥:៥៩]

**ស៖** ដូច្នេះ<បើខ្ញុំយល់មិនច្រឡំទេ> លោកជួន ហាន ទៅពិនិត្យមើលកន្លែងទ័ព ក៏ប៉ុន្តែលោកមិនទៅជារៀងរាល់ថ្ងៃទេ មែនទេ? <គឺលោកប្តូរវេនគ្នាជាមួយកងសន្តិសុខផ្សេងទៀត ត្រូវទេ?>

**ឆ៖** បាទ អត់ទៀងទេ។ ជួនកាល នៅជាមួយទ័ពហ្នឹងៗហ្នង។ រួចគេនុំង គេទៅម្នាក់ទៀត គេដូរគ្នាទៅ គេទៅមួយកន្លែងទៀតទៅ ដូចថាត្រូវគេពេញចិត្តយើងអ៊ីចឹង គេហៅយើងទៅជាមួយទៅ

គេឯណោះរាងធុញតិចទៅ ដូរគ្នា។

**ស៖** លោកបាននិយាយថា លោកជាកងការពាររបស់ ហាន។ តើកងការពារនេះ មានតួនាទីជានីរសារដែរឬទេ? ខ្ញុំចង់បានសួរលោកថា តើនីរសារ និងកងការពារនេះ តាមពិតតួនាទីតែមួយទេ មែនទេ?

**ឆ៖** បាទ។

**ស៖** តើ ហាន ឬក៏កម្មាភិបាលផ្សេងទៀតនៅវត្តអូរត្រកួន ធ្លាប់ប្រគល់សំបុត្រឱ្យលោកយកទៅស្រុក ឬយកទៅឃុំផ្សេងៗនៅក្នុងស្រុកកងមាសដែរឬទេ?

**ឆ៖** អត់ដែលមានផង។

**ស៖** អ៊ីចឹងខ្ញុំចង់សួរអំពីតួនាទីជានីរសារ <ឬ>ជាកងការពារ<មានធ្វើអ្វីខ្លះ តើការងារហ្នឹងដូចគ្នាទេ? នៅពេល>ដែលលោក<>និយាយថា <ជា>នីរសារវាមានន័យថាអ្នកនាំសំបុត្រ ឬក៏នាំលិខិតទៅកន្លែងណាមួយ <តើលោកធ្លាប់ធ្វើអ៊ីចឹងទេ>?

**ឆ៖** ចង់និយាយអ៊ីចេះ កាលនុ៎ងគេហៅថានីរសារ គឺកងការពារហ្នឹងហ្នង មិនមែនរត់សំបុត្រទេ។ បើអ្នករត់សំបុត្រៗតែ ឧទាហរណ៍ថាដកទ័ពពីឃុំនេះទៅនៅឃុំនោះ ហ្នឹងយើងមាន។ ហៅសំបុត្រទៅស្រុកទៅអី គឺអត់ដែលមានផង។

[១១:១៨:៥៦]

**ស៖** នៅពេលដែលលោកត្រូវនាំសំបុត្រទៅតាមឃុំមួយចំនួននោះ អ្នកណាជាអ្នកប្រគល់សំបុត្រហ្នឹងឱ្យលោកយកទៅហ្នឹង? ជាមេរបស់លោក ហាន ហ្នឹង ឬក៏ជាអ្នកណាផ្សេង?

**ឆ៖** លោក ហាន ហ្នឹងតែម្តង។

**ស៖** <ដើម្បីឱ្យកាន់តែច្បាស់> ខ្ញុំសូមអាននូវចម្លើយរបស់សាក្សីមួយរូបដែលគាត់ឆ្លើយពាក់ព័ន្ធនឹងលោក។ ខ្ញុំមិនអាចបញ្ចេញឈ្មោះគាត់ទេ គឺក្នុងឯកសារ<កំណត់ហេតុរបស់ អូ.ស៊ី.ភី> លេខ E3/ គឺ <E3/7827> គាត់ជាអតីតព្រះសង្ឃនៅវត្តអូរត្រកួន។ នៅទំព័រ៣ ជាភាសាអង់គ្លេស, ទំព័រ២ ជាភាសាបារាំង និងទំព័រ៤ ជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់៖ "អ្នកយាមគុក គឺនៅមានរស់រានជីវិតមកដល់សព្វថ្ងៃ គាត់ជាគ្រូ គាត់ឈ្មោះ មុយ វ៉ាន់នី។ គាត់ជានីរសាររបស់មន្ទីរសន្តិសុខ។ នៅពេលសម័យនោះគាត់មានអាយុប្រហែល១៦ ឬ១៧ឆ្នាំ។ ឥឡូវនេះគាត់បង្រៀននៅសាលាសំបួរមាស។" ចំណុចទី១ គាត់និយាយថា លោកជានីរសាររបស់មន្ទីរសន្តិសុខ។ ដូច្នេះខ្ញុំចង់ដឹងថា លោកជានីរសាររបស់ ហាន

ផ្ទាល់តែម្នាក់ ឬក៏ជានីរសាររបស់មន្ទីរសន្តិសុខទាំងមូលតែម្តង? ក្នុងនេះមានន័យថា លោកជាអ្នកនាំសំបុត្រ ទោះបីជា ហាន មិនមានវត្តមានក៏ដោយ ក៏លោកអាចនាំសំបុត្របានដែរ។ តើលោកអាចបញ្ជាក់ចម្លើយនេះ ឲ្យបានច្បាស់បានទេ?

**ឆ៖** អាហ្នឹងវាជាការពិតហើយ វាមិនមែនជាអីទេ ប៉ុនគ្រាន់ថា ជួនកាលគេប្រើយើង បានយើងទៅដែរ។ បើគេមិនប្រើទេ ជួនកាលគេទៅទាំងអស់គ្នា គឺមេទៅណា គឺយើងទៅនុ៎ង។ បើមេមិនទៅទេ គេខ្ជិលអ៊ីចឹងទៅ គេឲ្យយើងទៅ ប្រាប់គេថា អំ ទៅដកទ័ពត្រង់នេះៗ ឲ្យមកនៅស្រុកនេះវិញ ឃុំនេះអីអ៊ីចឹងណា៎។ គ្រាន់តែប៉ុណ្ណឹង។ ជួនកាលទៅទាំងអស់ហ្នឹង អ៊ីចឹងទៅ។

[១១:២១:៤៦]

**ស៖** សាក្សីរូបនោះ គាត់បាននិយាយថា លោកមានអាយុប្រហែល១៦, ១៧ឆ្នាំ ក៏ប៉ុន្តែលោកលោកថា អាយុប្រហែល១១, ១២ឆ្នាំ ពេលដែលលោកនៅវត្តអូរត្រកួន។ ដូច្នេះតើសាក្សីរូបនោះ គាត់ច្រឡំអំពីអាយុរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** ប្រហែលជាគាត់ច្រឡំហើយ ព្រោះការស្គាល់គ្នាវាមិនច្បាស់លាស់ ដូចយើងនៅជាមួយគ្នាទេ។ យើងវាអត់ច្បាស់ ព្រោះខ្ញុំវានៅក្មេងមែនទែនហើយ។ ហើយខ្ញុំមិនដែលស្គាល់គាត់ដែរ គាត់គ្រាន់តែថាឃើញ ធ្លាប់ឃើញខ្ញុំអីជិះម៉ូតូជាមួយមេអីអ៊ីចឹងទៅណា៎។ ហើយអ៊ីចឹង ការប៉ាន់ស្មានរបស់គាត់។

**ស៖** បើខ្ញុំមិនប្រាប់ឈ្មោះគាត់ទៅលោកទេ អ៊ីចឹងប្រហែលជាលោកមិនអាចដឹងច្បាស់ទេ។ ឥឡូវនេះ ខ្ញុំចង់ដឹងថា តើ ហាន គាត់មកពីតំបន់ណាដែរ នៃប្រទេសកម្ពុជា?

**ឆ៖** បាទ ជំនាន់នោះ គឺខ្ញុំមិនចាំបានទេ ថាពួកគេនិយាយថា មកពីខាងនិរតី។ ហើយខ្ញុំក៏មិនដឹងថា និរតីនៅឯណាដែរ ស្រុកណាដែរ ខ្ញុំអត់បានដឹង។

**ស៖** នៅសម័យនោះ លោកធ្លាប់<រួមដំណើរជាមួយ> ហាន ទៅក្រៅស្រុកកងមាសទេ? ឧទាហរណ៍ដូចជា ពេលដែលគាត់ត្រូវទៅប្រជុំនៅថ្នាក់តំបន់ ឬថ្នាក់ភូមិភាគអីហ្នឹង លោកធ្លាប់ជូនគាត់ទៅទេ?

**ឆ៖** អត់ដែល។

**ស៖** ក្នុងឋានៈលោកជាកងការពារនោះ លោកមានកាំភ្លើងទេ? ហើយបើមាន កាំភ្លើងហ្នឹង ជាកាំភ្លើងប្រភេទណាដែរ?

[១១:២៤:០៧]

**ឆ៖** មានកាំភ្លើង ប៉ុនកាំភ្លើងអា.កា ប្រភេទ អា.កា។ ដល់ក្រោយមកទៅ ខ្ញុំវាធ្ងន់ពេក ត្អូញជិះម៉ូតូ នេះហើមស្មាទៅ ខ្ញុំនៅមិនស្រួល ក៏ដូរកាំភ្លើងទៀតទៅ យកអាស្រាល កាប៉ាប៊ីន កាត់ស្វាយ។

**ស៖** ចុះកងការពារផ្សេងទៀត នៅ<វត្ត>អូរត្រកួនទុំង មានកាន់កាំភ្លើងទេ? ហើយបើមាននោះកាំភ្លើងជាកាំភ្លើងប្រភេទអីដែរ?

**ឆ៖** បាទ មាន ប៉ុន្តែកាំភ្លើងដូចខ្ញុំបាននិយាយខាងដើម ដូរគ្នាទៅ បើគេទៅៗ គេយកកាំភ្លើងហ្នឹងទៅៗ។ ខ្ញុំទទេទៀតហើយ មានអី។ វាអត់ត្រូវការទៅណាផង ខ្លួនទទេធម្មតា។

**ស៖** ដូច្នេះមានន័យថានៅក្នុងវត្តហ្នឹង គឺកងការពារទាំងអស់ហ្នឹងមានកាន់កាំភ្លើងគឺ <កាំភ្លើងខ្លី ឬ> អា.កា <>។ ចុះមានអ្នកណាកាន់ដាវវែងទេ?

**ឆ៖** អាហ្នឹងមាន ប៉ុន្តែផ្នែកគេផ្សេង។ ផ្នែកគេអ្នកកាន់ផ្សេង ខ្ញុំអត់មានតួនាទីអីផង ដឹងតែថាមេទៅណា ខ្ញុំទៅហ្នឹង អ៊ីចឹងទៅ។

**ស៖** អ៊ីចឹងនៅពេលដែលលោកនិយាយអំពីក្រុមដាវវែងហ្នឹង អ្នកទាំងអស់ហ្នឹងនៅក្រៅវត្ត ឬក៏នៅក្នុងវត្ត<ហ្នឹង>?

**ឆ៖** នៅក្នុងវត្ត។

[១១:២៦:៣០]

**ស៖** តើលោកអាចរៀបរាប់ឈ្មោះ<ជំនួយការ>របស់ ហាន <នៅវត្តអូរត្រកួន>បានទេ? ឬក៏អាចថា តើអ្នកណាជាអ្នកដឹកនាំ<អង្គភាពឆ្មាំ>សន្តិសុខហ្នឹង ពេល ហាន មិននៅ?

**ឆ៖** ឈ្មោះ គួង។ ដល់ពេល គួង ហ្នឹងសម្លាប់ចោលអ៊ីចឹងទៅ មាន! ចង់ភ្លេចឈ្មោះ អីឈ្មោះ បុត្រ ដំបូង។ បុត្រ ហ្នឹងស្លាប់។ ដល់ស្លាប់អ៊ីចឹងទៅឡើងឈ្មោះ គួង បន្ទាប់ពីឈ្មោះ ហាន ហ្នឹងមិននៅកន្លែងហ្នឹង គឺឈ្មោះ គួង។

**ស៖** ខ្ញុំគិតថា ប្រហែលជាមានការភ័ន្តច្រឡំបន្តិច ពីព្រោះថាក្នុងចម្លើយ៥៩ នៅក្នុងឯកសារ E319/19.3.93 លោកបានឆ្លើយដូចតទៅ៖ “ក្រោយពី បុត្រ ស្លាប់ហ្នឹង គួង បានក្លាយជា<ជំនួយការ>របស់ ហាន។” ដូច្នេះខ្ញុំចង់ដឹងថាពីរនាក់ហ្នឹង បុត្រ និង គួង អ្នកណាមុន អ្នកណាក្រោយ?

**ឆ៖** បុត្រ មុន។

**ស៖** លោកជាកងការពាររបស់ ហាន ហើយលោកធ្វើការនៅក្នុងវត្ត។ <តើ>លោកអាចដើរទៅណា មកណាបានដោយសេរីនៅក្នុងបរិវេណវត្តហ្នឹង<>ទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំអាចដើរបាន ប៉ុន្តែគ្រាន់ថាវា យើងនៅក្មេង យើងខ្លាចតិចដែរ។ នៅខ្លាចនៅឡើយ មិនសូវហ៊ានដើរ។

**ស៖** លោកបាននិយាយថា លោកមិននៅជាប់ជាមួយ ហាន រហូតទេ ពេលខ្លះហ្នឹងមានកង ការពារផ្សេងទៀត។ អ៊ីចឹងពេលដែលលោកមិនជូន ហាន ទៅនោះ លោកត្រូវបំពេញភារកិច្ចអ្វីខ្លះនៅក្នុង វត្តអូរត្រកួននោះ? ឧទាហរណ៍ជាលោកមានដើរយាមនៅក្នុងវត្ត ឬក៏យកបាយទៅឲ្យអ្នកទោស ឬក៏ ជួយដាំស្ល ដាំបន្លែអ៊ីចឹង លោកមានធ្វើអ៊ីចឹងទេ? <ខ្ញុំគ្រាន់តែលើកជាឧទាហរណ៍ ខ្ញុំមិនបាននិយាយថា លោកធ្វើការងារទាំងអស់នេះទេ។> ខ្ញុំចង់ដឹងថា លោកធ្វើអ្វីខ្លះពេលដែលលោកមិនជូន ហាន ទៅណា មកណានោះ លោកនៅក្នុងវត្តហ្នឹង លោកធ្វើអ្វីខ្លះ?

[១១:២៩:៣៣]

**ឆ៖** ខ្ញុំអត់ដែលមានធ្វើអីផង ពេលដែលអត់មានការងារ ដេកទៅ និយាយលេងជាមួយអ្នក ដែលមានទោសស្រាលៗហ្នឹងទៅ ទៅលេងគាត់ ជួនកាលឲ្យគាត់ឡើងបេះទឹកដោះអីញ៉ាំអ៊ីចឹងទៅណា ឲ្យគាត់ហូបផង ខ្ញុំហូបផងអ៊ីចឹងទៅ ព្រោះគាត់អ្នកចេះឡើងអ៊ីចឹង គាត់អ្នកទោសស្រាល អ៊ីចឹងគាត់ អាចបេះបាន។ បេះជាទំពក់ បេះជាអ៊ីចឹងទៅ ទម្លាក់មកអ៊ីចឹងទៅ។

**ស៖** ចុះលោកធ្លាប់ចូលទៅក្នុងកន្លែងដែលគេឃុំអ្នកទោសនៅក្នុងវត្តទេ? ហើយលោកមានបាន សង្កេតឃើញថាតើអ្នកទោសនៅក្នុងកន្លែងដែលគេឃុំហ្នឹងមានស្ថានភាពបែបណាអីទេ?

**ឆ៖** បាទ ធ្លាប់អើតមើលអីអ៊ីចឹងទៅ ព្រោះយើងមកថ្មីៗអ៊ីចឹង យើងក្មេងជាងគេ យើងមិន ដែលឮ។ ដំបូងៗជួនលប ជួនអើតមើលដែរ លបមើលអីអ៊ីចឹងណា សួរសុខទុក្ខអីគាត់អីអ៊ីចឹង បើមេទៅ បាត់ហើយ យើងឆ្មក់បន្តិចទៅ។

**ស៖** តើលោកអាចរៀបរាប់បានទេថា នៅក្នុងកន្លែងដែលគេឃុំអ្នកទោសហ្នឹង លោកបាន ឃើញអ្វីខ្លះ លោកអាចរៀបរាប់បន្តិចបានទេ <ដោយសារចំណុចនេះមិនទាក់ទងនឹងសវនាការថ្ងៃនេះ ទេ>?

**ឆ៖** បាទ ឃើញគេដាក់ខ្នោះជើងអ៊ីចឹងទៅ។ ឃើញតែអ៊ីចឹង បើក្នុងវិហារលោកហ្នឹងគេដាក់ ខ្នោះទៀត ខ្នោះកងជើង។

**ស៖** ចុះ<អំពីលក្ខខណ្ឌនៃការឃុំខ្លួន និយាយជាទូទៅគឺអំពី>អនាម័យ ហើយនិងរបបហូបចុក របស់អ្នកទោសនោះ យ៉ាងម៉េចដែរ លោកដឹងទេ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ខ្ញុំបានដឹងដែរ គឺបបរហ្នឹងលាយត្រកួនទៅ លាយដំឡូងអីចឹងទៅ។

[១១:៣២:២១]

**ស៖** តើរបបអាហារនេះ មានលក្ខណៈគ្រប់គ្រាន់ដើម្បីឲ្យអ្នកទោសគាត់ហូបទៅ គាត់មានសុខភាពល្អអីទេ?

**ឆ៖** គឺអត់មានទេ គឺបបរសាបតែម្ដង។ ចែកមួយត្រឡោកៗម្នាក់ បន្តិចៗម្នាក់ មួយវែកៗម្នាក់។

**ស៖** អ្នកណាជាមេផ្ទាល់របស់ ហាន នៅស្រុកកងមាសនោះ? លោកដឹងទេ <>អ្នកណាជាប្រធានស្រុកកងមាស?

**ឆ៖** មានអង្គាល់ជំនាន់នោះគេហៅថា ថៅហ្វាយស្រុកៗអីចឹង ឈ្មោះ កាន។

**ស៖** លោកដឹងទេថា កាន ហ្នឹងមកពីនិរតីដូច ហាន ដែរមែនទេ?

**ឆ៖** បាទ ឮគេនិយាយថាសុទ្ធពួកនិរតីនៅធ្វើការនៅក្នុងស្រុកហ្នឹង។ មេឃុំ មេស្រុក សុទ្ធតែពួកនិរតី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណព្រះរាជអាជ្ញារងអន្តរជាតិ។ បាទ ឥឡូវនេះពេលវេលាដល់ពេលត្រូវសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:២៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅមានពេលវេលាសរុប៤០នាទី ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

មានបញ្ហាបកប្រែភាសាទៀតហើយ មន្ត្រីរដ្ឋបាលតុលាការ!

ភាសាអង់គ្លេស អត់មានភាសាអង់គ្លេស ណ៎ះ!

*(មានបញ្ហាបច្ចេកទេស)*

បាទ ឥឡូវនេះ អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការ។ ហើយអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោយសាក្សីរូបនេះ។ ហើយសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៅមានពេលសេសសល់ហ្នឹង គឺ៤០នាទីទៀត។ សូមអញ្ជើញ!

[១៣:៣៤:៥៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ យើងបានចាប់ផ្ដើមព្រឹកមិញកាលពីម៉ោងដប់ព្រឹក ដូច្នេះយើងខ្ញុំនឹងព្យាយាមបញ្ចប់ត្រឹម៤០នាទី<ជាមួយខាងដើមបណ្ដឹងរដ្ឋប្បវេណី> ក៏ប៉ុន្តែខ្ញុំគិតថាប្រហែលជាអាចប្រើដល់៥០នាទី លោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សី កាលពីព្រឹកមិញលោកបាននិយាយថា មេរបស់លោកនៅវត្តអូរត្រកួនឈ្មោះ ហន ហើយប្រធានស្រុក ឬចៅហ្វាយស្រុកនោះឈ្មោ កាន។ ហើយ កាន នេះជាមេរបស់ ហន។ ពេលដែល ហន សម្រេចអ្វីមួយនៅវត្តអូរត្រកួន តើគាត់រាយការណ៍ទៅ កាន ដែរឬទេ? ហើយតើឈ្មោះ ហន

នេះធ្លាប់ទទួលបញ្ជាពី កាន ទេ? ព្រោះថាលោកៗទៅជាមួយ ហាន នេះញឹកញាប់ អ៊ីចឹងខ្ញុំគិតថា ប្រហែលជាលោកដឹងអំពីទំនាក់ទំនងរវាង ហាន និង កាន។

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំអត់បានដឹងដែរ រឿងបញ្ហាហ្នឹង។

**ស៖** លោកនិយាយថា វត្តមានចម្ងាយ២គីឡូម៉ែត្រពីមន្ទីរស្រុកកងមាស។ ដូច្នេះដោយសារតែទីតាំងទាំងពីរហ្នឹងមានទីតាំងជិតគ្នា ដូច្នេះតើ កាន <ដែលជាប្រធានស្រុក>នេះធ្លាប់មកពិនិត្យមើលនៅមន្ទីរសន្តិសុខអូរត្រកួន ឬក៏ធ្លាប់មកប្រជុំនៅមន្ទីរសន្តិសុខអូរត្រកួនទេ?

**ឆ៖** អត់ដែលឃើញផង។

[១៣:៣៦:៥៨]

**ស៖** កាលពីព្រឹកមិញនេះ លោកបាននិយាយថា មាន<អ្នក>យាមនៅវត្តនុ៎ងគឺមានកាន់<>កាន់ដាវ។ ចុះនៅក្នុងឃុំពាមជីកង មានក្រុមឈ្លបដាវវែងទេ?

**ឆ៖** អត់ដែលដឹងដែរ ព្រោះខ្ញុំនៅមួយកន្លែងខ្ញុំ គឺដឹងតែស្គាល់តែកន្លែងហ្នឹង អត់បានដែររហេតរហូតអីផង។

**ស៖** លោកបាននិយាយ<យ៉ាងច្បាស់>អំពីអ្នកយាមនៅវត្តអូរត្រកួន ដូច្នេះតើអ្នកយាមទាំងអស់ហ្នឹងជាកងទ័ពស្រុកមែនទេ? ព្រោះព្រឹកមិញនេះ លោកនិយាយថាមន្ទីរសន្តិសុខហ្នឹងគឺស្ថិតនៅក្រោមបង្គាប់របស់ស្រុកកងមាស ដូច្នេះខ្ញុំចង់ដឹងថា អ្នកយាមទាំងអស់ហ្នឹងសុទ្ធតែជាកងទ័ពស្រុកមែនទេ?

**ឆ៖** វាម៉េចទេ ព្រោះធម្មតាៗ ចូលបានតែគ្នាអ្នកនៅហ្នឹង ក្រៅពីហ្នឹងអត់មានពីណាចូល។

**ស៖** ខ្ញុំបានសួរលោកថា តើ<កងសន្តិសុខនៅ>វត្តអូរត្រកួនហ្នឹងស្ថិតនៅក្រោមបង្គាប់ថ្នាក់ឃុំ ឬក៏ថ្នាក់ស្រុក?

**ឆ៖** ខ្ញុំធ្លាប់ឃើញថា ការទំនាក់ទំនងរបស់មេស្រុកហ្នឹង គឺគ្រាន់តែដឹងថាឈ្មោះ កាន ជាចៅហ្វាយស្រុក ប៉ុន្តែខ្ញុំអត់ដឹងពីសភាពថា អ្នកដែលនៅក្នុងវត្តអូរត្រកួននុ៎ង អត់មានអ្នកយាមអីទេ គឺថាមានតែអ្នកនៅចំណុះនៅក្នុងវត្តហ្នឹង មានតួនាទីគឺនៅតែអ៊ីចឹងតែហ្នឹង នៅធម្មតាអ៊ីចឹង ដូចយើងផ្ទះយើងអ៊ីចឹង អត់មានអ្នកយាមអីពីរបីជាន់ អត់មានទេ។

**ស៖** បាទ ខ្ញុំយល់អំពីចំណុចនេះ។ អ៊ីចឹងអ្នកដែលធ្វើការនៅក្នុងវត្តហ្នឹង ក្រោមបង្គាប់របស់

ហាន និង គួង នេះ ពួកគេដើរចាប់មនុស្សក្នុងឃុំផ្សេងៗនៃស្រុកកងមាស មែនទេ?

[១៣:៤០:០៣]

**ឆ៖** កាលនោះ គឺខ្ញុំនៅជិតរយៈពេលខ្លី ហើយខ្ញុំមិនដែលឃើញដែរ គ្រាន់តែឃើញគេបញ្ជូនមក មិនដឹងពីណាទៅ ៗចាប់ ឬក៏ទៅចងអីយកមក ឃើញតែគេដឹកយកមកអ៊ីចឹង។ អត់ដឹងថា អ្នកសន្តិសុខហ្នឹងផ្ទាល់ទៅចាប់ ឬក៏អី ខ្ញុំអត់ដឹង។

**ស៖** ខ្ញុំចង់ដកស្រង់នូវចម្លើយទី១៨នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E319/19.3.93 គឺចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤។ ពេលនោះគេសួរលោកដូចទៅ ខ្ញុំសូមដកស្រង់៖“តើលោកចាំឈ្មោះមនុស្សខ្លះនៅក្នុងក្រុមដាវវែងនោះទេ? ពេលនោះលោកឆ្លើយដូចតទៅ៖ បាទ ខ្ញុំចាំខ្លះ ដូចជាឈ្មោះ គួង, មឿន និង ហ៊ាន់។ ពួកគេជាអ្នកស្រុកកងមាស គឺមិនមែនមកពីនិរតីនោះទេ។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះលោកអាចបញ្ជាក់បានទេ ថាឈ្មោះ គួង, មឿន និង ហ៊ាន់ នេះគឺជាអ្នកដែលធ្វើការនៅមន្ទីរសន្តិសុខវត្តអូរត្រកួន មែនទេ?

**ឆ៖** ដែលជាការពិត ក៏ប៉ុន្តែអ្នកហ្នឹងគ្រាន់តែជាចាំកន្លែង ត្រង់ថាគេបានពីណាពីណីមក បានគេបញ្ចូលមកនុ៎ង បានទទួលខុសត្រូវនៅកន្លែងនុ៎ងហ្នុង។ អត់មានទៅណាទៅណី គឺខ្ញុំអត់បានដឹង ព្រោះខ្ញុំវាមិនសូវយកចិត្តទុកដាក់ដែរ វានៅស្ទើរ។

**ស៖** <តើមានអ្វីកើតឡើង>នៅពេលដែលគេបញ្ជូនមនុស្សមកដល់មន្ទីរសន្តិសុខនោះ<?> ខ្ញុំចង់ដឹងថា អ្នកណាជាអ្នកនាំមក? គឺមានឈ្លប<ដែលជាអ្នកក្រៅ> គេនាំយកមនុស្សយកមកប្រគល់ឱ្យមន្ទីរសន្តិសុខ ឬក៏មនុស្សដែលអ្នកធ្វើការនៅក្នុងវត្តហ្នឹងតែម្តង ដែលជាអ្នកចេញទៅចាប់មនុស្ស ហើយនាំយកមកមន្ទីរនុ៎ង?

[១៣:៤២:៤៧]

**ឆ៖** ជួនកាលប្រធានកងគេអី ឈ្លបភូមិឈ្លបអីគេក៏មិនដឹង ខ្ញុំមិនសូវបានចាប់អារម្មណ៍ដែររឿងហ្នឹង ឃើញតែគេយកមកដាក់រទេះគោដាក់អី។ គេបង្វែរថា ទៅកន្លែងនេះ កន្លែងនោះ ស្រាប់តាមការពិត គឺយកមកពីវត្តអូរត្រកួនតែម្តងអ៊ីចឹង គ្រាន់តែឃើញតែអ៊ីចឹង។ មកដល់ឃើញមនុស្សពីរបីនាក់អ៊ីចឹងទៅ ប៉ុន្តែមិនដឹងមកពីភូមិណា ឃុំណា អត់បានដឹង។

**ស៖** ឈ្លបដែលនាំមនុស្ស<ពីរបីនាក់>មកមន្ទីរសន្តិសុខនុ៎ង ពួកគេមានសិទ្ធិចូលទៅដល់ក្នុងបរិវេណវត្តទេ? ឬក៏គេប្រគល់អ្នកដែលគេចាប់ខ្លួនហ្នឹង មកឲ្យកងសន្តិសុខនៅវត្តហ្នឹង គេមិនបានចូល

ទៅខាងក្នុងទេ?

**ឆ៖** គេយកមកតែម្តង ដូចថាតែមានរបស់អីមកដល់ហ្នឹង គេបញ្ជូនមកដល់ត្រឹមហ្នឹង គេទទួលត្រឹមហ្នឹងតែម្តង ត្រឹមកន្លែងសន្តិសុខហ្នឹងតែម្តង។

**ស៖** លោកបានឆ្លើយថា លោកបានជូនដំណើរ ហាន ទៅស្ទើរតែគ្រប់កន្លែងនៅក្នុងស្រុកកងមាស។ ជាពិសេសនោះ គឺទៅមើលកងទ័ព។ អ៊ីចឹងនៅពេលដែលលោកជូនគាត់ទៅហ្នឹង លោកធ្លាប់ឃើញគេចាប់ខ្លួនមនុស្សទេ? ដូចជាចាប់ខ្លួនអ្នកភូមិនៅក្នុងឃុំផ្សេងៗនៅក្នុងស្រុកកងមាសនោះ។

**ឆ៖** អត់ដែលឃើញផង។ មិនដឹងជាយ៉ាងម៉េច បើខ្ញុំមិនដែលឃើញ។ ស្រាប់ទៅដល់ ជូនកាលថៃ្ងដន្សទៅ ខ្ញុំពេលទំនេរឃើញមនុស្សនៅនឹងវត្តអូរត្រកួនហ្នឹងទៅ។ មិនដឹងជាគេចាប់តាមខ្សែរយៈណាអី យ៉ាងម៉េចឲ្យពីណាចាប់អី គឺដូចមិនដែលឃើញ។ បើឈ្មោះ ហាន ទៅចាប់ផ្ទាល់អត់ដែលមានទេ មិនដែលជួបប្រទះ។

[១៣:៤៥:៣១]

**ស៖** ឥឡូវនេះ ខ្ញុំចង់ឲ្យលោកឆ្លើយបញ្ជាក់ពីព្រោះថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E319/19.3.93 សំណួរចម្លើយ១៧ ពេលនោះគេសួរលោកថា៖ “លោកធ្លាប់បានឃើញដោយផ្ទាល់ភ្នែកនូវការចាប់អ្នកទោស ឬអ្នកស្រុកនៅតាមភូមិដែរឬទេ? លោកបានឆ្លើយដូចតទៅ៖ បាទ ខ្ញុំឃើញអំពីការចាប់ខ្លួនខ្លះនៅក្នុងស្រុក។ តាមខ្ញុំដឹង ហាន បានទទួលរបាយការណ៍ពីឃុំ អំពី<អ្នក>ដែលត្រូវចាប់ខ្លួន។ ដូច្នេះពេលខ្លះគាត់ផ្ទាល់សហការជាមួយក្រុមសន្តិសុខខាងផ្នែកដាវរែង ធ្វើដំណើរចុះទៅឃុំដើម្បីចាប់ខ្លួន។ ប៉ុន្តែមានពេលខ្លះគេបានប្រើឧបាយកលប្រាប់ឲ្យអ្នកទោសនោះ ធ្វើដំណើរមកមន្ទីរសន្តិសុខដោយខ្លួនឯងតែម្តង។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះតាមរយៈចម្លើយនេះ ដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត លោកថា លោកបានឃើញការចាប់ខ្លួនមនុស្សនោះដោយផ្ទាល់នឹងភ្នែក។ លោកអាចបញ្ជាក់អំពីចំណុចនេះបានទេ?

**ឆ៖** ខ្ញុំដូចជាមិនដែលឃើញដែរ ព្រោះធម្មតាគេអ្នកធំ គេមិនដែលចាប់ទេ គ្រាន់តែថា បញ្ហាយ៉ាងម៉េច គឺខ្ញុំអត់ដឹងថា អីយ៉ាងម៉េច ទៅគេទៅមួយកន្លែងណាផ្សេងទៀតទៅ សួរសុខទុក្ខទាហានគេទៅ អីទៅ។ អារឿងថាឃើញចាប់ចងអីនោះ ដូចមិនដែលប្រទះជាមួយមេហ្នឹងដែរ។

**ស៖** ពេលដែលលោកធ្វើការជាមួយ ហាន នៅវត្តអូរត្រកួន តើលោកធ្លាប់ឃើញគេនាំជនជាតិចាម ឬក៏បណ្តើរជនជាតិចាមទៅវត្តហ្នឹងទេ?

**ឆ៖** ធ្លាប់។ គ្រាន់តែថា មកដល់ចូលគេ អ្នកនាំនោះផ្សេងទៅ យើងអ្នកទទួលនៅខាងក្នុង គេអ្នកមាន ប្រធានគេនៅខាងក្នុងគេដឹងទិចនិកអីយ៉ាងម៉េចៗ គឺខ្ញុំអត់ដឹងដែរព្រោះខ្ញុំ វាមានតួនាទីតែត្រឹមតែគេហៅថា អង្គរក្ស មេតែប៉ុណ្ណឹង រឿងផែនការយ៉ាងម៉េចៗគឺអត់ដឹង។ គេអត់ឲ្យយើងដឹងទេ។

[១៣:៤៨:៥៧]

**ស៖** ពេលដែលលោកឃើញ<គេនាំ>ពួកចាមមកដល់វត្តនោះ លោកនៅខាងក្នុងវត្តឬក៏នៅខាងក្រៅវត្ត?

**ឆ៖** ខ្ញុំនៅខាងក្នុង មើលពីចម្ងាយអ៊ីចឹងទៅព្រោះដូចខ្ញុំបាននិយាយអ៊ីចឹងថា ខ្ញុំអត់មានតួនាទីអីទៅធ្វើអីក្រៅពីដើរជាមួយមេទេ។ ជួនកាលដើរជាមួយមេ មិនមែនដើរជាប់រហូតឯណា ជួនកាលនៅផ្ទះធម្មតាដូចផ្ទះយើងធម្មតាអ៊ីចឹង ព្រោះខ្ញុំនៅក្មេងមិនសូវហ៊ានដើរឆ្វេចឆ្វាច ខ្លាចដែរ។

**ស៖** <ដូច្នេះ>លោកនៅជាមួយមេរបស់លោក អ៊ីចឹងលោកអាចជម្រាបបានទេថា អ្នកដែលជាជនជាតិចាម ដែលមកដល់ហ្នឹងធ្វើដំណើរដោយមធ្យោបាយអីខ្លះ មានអ្នកខ្លះដើរ ជិះរទេះ ឬក៏មានជិះទូកអីទេ?

**ឆ៖** ភាគច្រើន ច្រើនជិះរទេះ បាទ ជិះរទេះ ជិះរទេះគោ។

**ស៖** តើលោកធ្លាប់ឮគេនិយាយថា មាន<ទូកដែលដឹក>ជនជាតិចាម<> ហើយមកចតនៅក្បែរវត្ត នៅតាមដងទន្លេមេគង្គទេ?

**ឆ៖** បាទ ធ្លាប់ឃើញ។ គ្រាន់តែដឹងថា គេយកមកដាក់តាមកាណូតអីយ៉ាងម៉េច អាគេយកមកតាមនេះហ្នឹង គឺឃើញ ខ្ញុំដូចខ្ញុំនិយាយអ៊ីចឹងថា នៅនឹងកន្លែងទេ គ្រាន់តែថាឃើញទិដ្ឋភាពមកក្នុងវត្តហ្នឹង គឺឃើញមកដល់កន្លែងហ្នឹងតែម្តង។

**ស៖** <អ្នកទាំងនោះត្រូវបានគេបញ្ជូនមកតាមទូក តើជាក្រុមធំ ឬជាក្រុមតូច>?

[១៣:៥១:២៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ! កុំអាលទាន់ឆ្លើយ!

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ពេលខ្លះក៏ច្រើន ពេលខ្លះក៏តិចទៅ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បើច្រើននោះ តើលោកអាចជម្រាបបានទេថា មានប្រហែលជាប៉ុន្មានដែរ ដែលចូលទៅក្នុងវត្តម្ដងៗនោះ? មានលើសពី<រាប់សិប>នាក់ ឬក៏យ៉ាងម៉េច អាចរៀបរាប់បានទេ?

**ឆ៖** បាទ បើសិនជាដាក់កាណូតមកអ៊ីចឹងទៅ មួយសា៥០នាក់ ១០០នាក់អ៊ីចឹងទៅ។

**ស៖** ក្នុងចំណោមអ្នកដែលគេបញ្ជូនមកវត្តអូរត្រកួនហ្នឹង លោកដឹងយ៉ាងម៉េចបានថា មានជនជាតិចាមនោះ? ព្រោះអម្បាញ់មិញនេះ លោកថាលោកមានឃើញជនជាតិចាម ត្រូវបានគេនាំមកវត្ត។ អ៊ីចឹងលោក<តើ>លោកឃើញផ្ទាល់ភ្នែក ឬក៏<លោកបានដឹងរឿងនេះពីអ្នកផ្សេង ដែលអ្នកនោះគឺជា>ជនជាតិចាម<>?

**ឆ៖** គេនិយាយ ឮគេនិយាយថា ដែលគេប្រមូល មានផែនការមួយប្រមូលចាមហ្នឹង។ ឮគេនិយាយអ៊ីចឹង ខ្ញុំមិនដឹងដែរ។

[១៣:៥៣:១៥]

**ស៖** ក្នុងចំណោមអ្នកទោសទាំងអស់នៅវត្តអូរត្រកួនហ្នឹង អ្នកទោសជាជនជាតិចាមហ្នឹងមានភាគច្រើន ឬក៏ភាគតិច?

**ឆ៖** ភាគច្រើន។ ខ្មែរដូចតិចតួច ដូចថាមានរឿងអីបន្តិចបន្តួច គេមិនពេញចិត្តក្នុងសហករណ៍អ៊ីចឹងទៅ ជួនកាលគេមិនទាន់អីឲ្យភ្ញាក់ផ្អើលអ៊ីចឹងទៅ គេយកមកតាមក្រោយអី ដាក់អីផ្សេងទៀតទៅ។

**ស៖** សូមលោកនិយាយចម្លើយចុងក្រោយអម្បាញ់មិញនេះម្ដងទៀត ព្រោះថាអ្នកបកប្រែ គាត់អត់យល់ចម្លើយរបស់លោក?

**ឆ៖** គេចាមហ្នឹង គឺបើកាលណាច្រើនទៅ គេដាក់កាណូត។ ហើយបើខ្មែរយើង វាតិចតួច គេដាក់រទេះ ដាក់អីអ៊ីចឹងទៅ។ ហ្នឹងវាមិនមកព្រមគ្នាទេ វាដូចថា មិនដឹងថាយ៉ាងម៉េចទេ ខ្ញុំៗមិនដឹងរឿងផែនការគេចាប់ហ្នឹងដែរ។

**ស៖** ពេលគេបញ្ជូនទៅដល់វត្ត តើអ្នកយាមនៅវត្តហ្នឹង មានពិនិត្យផ្ទៀងផ្ទាត់មើលថាអ្នកទាំងអស់ហ្នឹងជាជនជាតិចាម ឬក៏មិនមែន? ឧទាហរណ៍ដូចជាគេសួរសំណួរដើម្បីឲ្យដឹងថាតើអ្នកហ្នឹងចាម ឬមិនមែនចាម គេស្ដាប់សំឡេង ស្ដាប់តុងអីអ៊ីចឹង មានធ្វើអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ព្រោះថាការងារដូចខ្ញុំនិយាយខាងដើមអ៊ីចឹងថា ខ្ញុំគ្រាន់តែដឹងថាឃើញមនុស្សហ្នឹងមក ហើយដឹងតែថាចាម ត្រង់ថាគេអីៗយ៉ាងម៉េចទៀត គឺខ្ញុំអត់មានសិទ្ធិទៅជ្រៀតជ្រែកការងាររបស់អ្នកដែលគេប្រគល់តួនាទីហ្នឹងណា៎។ ខ្ញុំគ្រាន់មានតួនាទីថាបើអត់មានការងារគឺនៅកន្លែង

តែម្តង អត់មានទៅធ្វើអីទៀត។ គ្រាន់ឃើញទិដ្ឋភាពថាគេយកមកអ៊ីចឹង ជួនកាលអត់ដឹងផង ស្រាប់ព្រលឹមឡើងឃើញមនុស្សណែនអីអ៊ីចឹង ព្រោះខ្ញុំនៅក្មេងខ្ញុំទៅសង្វាត ចូលចិត្តដេកៗច្រើន អត់មានយាមអីគេឯណាឯណីផង។

[១៣:៥៦:១៦]

**ស៖** ចុះអ្នកទោសខ្មែរដែលគេនាំទៅវត្តនោះ អ្នកដែលត្រូវបានគេចោទថាមានទោសធ្ងន់នោះ គេមានសួរចម្លើយទេ ពេលទៅដល់វត្តនោះ?

**ឆ៖** ខ្ញុំឃើញគេទៅសួរដែរ ប៉ុនមិនដឹងសួរពីអី ព្រោះគ្រាន់តែឃើញគេដូចថាថ្ងៃហ្នឹងត្រូវបញ្ចេញមនុស្សទៅសួរចម្លើយ គ្រាន់តែឃើញទៅអាកន្លែងសាលារៀន សព្វថ្ងៃនោះនៅកន្លែងស្រុកខ្ញុំហ្នឹងមានសាលារៀនមួយ សព្វថ្ងៃកំពុងដាក់សិស្សបង្រៀនផង ហើយខ្ញុំនៅបង្រៀននៅកន្លែងសួរចម្លើយហ្នឹងទៀត សម័យហ្នឹង រាល់ថ្ងៃហ្នឹង។ ប៉ុន្តែគ្រាន់តែឃើញទិដ្ឋភាពគេនាំទៅ យើងអត់មានតួនាទីគឺមិនអាចទៅបានទេ គេសួរតែពីរនាក់តទល់អីអ៊ីចឹងទៅ ហើយយ៉ាងម៉េចៗ គឺខ្ញុំមិនបានដឹងដែរ។

**ស៖** លោកថាអ្នកទោសខ្មែរត្រូវបានគេសួរចម្លើយដែរ។ ចុះអ្នកទោសចាមនោះ គេមានសួរចម្លើយទេនៅវត្តអូរត្រកួន?

**ឆ៖** អត់ដែលឃើញមានសួរចម្លើយ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី រ៉ុចទ័រ កូប៉េ!

**លោក រ៉ុចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយសារតែជាសំណួរនាំមុខដោយប្រើពាក្យថា "ផ្ទុយទៅនឹង"។ ដោយសារថា<មេធាវី>បានសួរ<សាក្សីឲ្យបញ្ជាក់ពី>ភាពផ្ទុយគ្នា<រវាងការសួរចម្លើយអ្នកទោសចាម និងអ្នកទោសខ្មែរ។ មេធាវីគួរតែសួរសំណួរបើកសិន តើមានការសួរចម្លើយ>ជនជាតិចាមទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅចំពោះសំណួរនេះ។

[១៣:៥៨:១៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** អ៊ីចឹងខ្ញុំដក<>ឃ្លាដើមចេញ។ ខ្ញុំសួរត្រឹមតែថា តើជនជាតិចាមត្រូវបានគេសួរចម្លើយឬក៏

អត់នៅវត្តអូរត្រកួន?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** គេអត់បានសួរទេ។ ទាល់តែមានរឿងអីផ្សេងៗ អាហ្នឹងប្រហែលជាខ្ញុំនឹកស្មានខ្លួនខ្ញុំទេ ព្រោះមនុស្សពីរបីរយនាក់ គេអត់សួរផង ជួនកាលសួរតែ ឃើញទៅម្នាក់ពីរអីអ៊ីចឹងទៅ មិនដឹងជាមូលហេតុអី ខ្ញុំវាមិនដឹងថាទោសហ្នឹងត្រូវយ៉ាងម៉េច អីយ៉ាងម៉េចដែរ។

**ស៖** គឺលោកបានឆ្លើយ<ច្បាស់ណាស់នៅក្នុងចម្លើយ៧៩>ដូចដែលជាកំណត់ហេតុរបស់លោកគឺ E319/19.3.93។ ពេលនោះគេសួរលោកថា៖ “តើជនជាតិចាមត្រូវបានគេសួរចម្លើយដែរឬទេពេលនាំទៅដល់មន្ទីរសន្តិសុខ? លោកថា៖ គេមិនសួរចម្លើយទេ គឺសម្លាប់ចោលបីបួនថ្ងៃក្រោយមកតែម្តង។” សូមបញ្ចប់ការដកស្រង់។ លោកដឹងទេថាហេតុអីបានជាអ្នកយាម ឬក៏អ្នកសួរចម្លើយនៅវត្តអូរត្រកួនហ្នឹងមិនសួរចម្លើយទៅលើអ្នកទោសចាម?

**ឆ៖** ខ្ញុំអត់បានដឹងពីមូលហេតុហ្នឹងដែរ ថាតួនាទីរបស់ខ្ញុំ គឺអត់មានសិទ្ធិទៅសួរនាំអារឿងបញ្ហាហ្នឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[១៤:០០:១៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដូចជាយឺតពេលបន្តិចទៅហើយ ប៉ុន្តែខ្ញុំសូមជំទាស់ទៅនឹងការដែលសួរសំណួររបស់សហព្រះរាជអាជ្ញា ព្រោះថាសាក្សីគាត់បានឆ្លើយខុសពីកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ ដូច្នេះ ត្រូវឲ្យគាត់ពន្យល់អំពីភាពខុសគ្នាហ្នឹងសិន មុននឹង<សួរសំណួរផ្សេងទៀត ឬ>យកចម្លើយពីកំណត់ហេតុហ្នឹង ថាជាចម្លើយត្រឹមត្រូវនោះ។ យើងធ្វើអ៊ីចឹងបានវាត្រឹមត្រូវ<និងអនុលោមទៅតាមនីតិវិធីរបស់តុលាការ> ពីព្រោះសាក្សីគាត់ឆ្លើយពេលនេះគឺខុសពីចម្លើយនៅក្នុងកំណត់ហេតុ។ អ៊ីចឹងយើងមិនគួរបំភ្លេចចម្លើយនៅទីនេះ ហើយយកតែចម្លើយក្នុងកំណត់ហេតុមកធ្វើជាត្រឹមត្រូវទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី អ៊ីចឹងខ្ញុំសូមសួរលោក។ លោកនៅក្នុងកំណត់ហេតុហ្នឹង លោកថា ជនជាតិចាមមិនត្រូវបានគេសួរចម្លើយទេ<។ ចំណុចនេះមិនច្បាស់ទេ>។ ដូច្នេះលោកអាចបញ្ជាក់<>ឲ្យបាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ច្បាស់បន្តិចបានទេ ថាតើអ្នកយាមនៅវត្តអូរត្រកួនហ្នឹងមានបានសួរចម្លើយអ្នកទោសចាមទេ ឬក៏ក្រុមអ្នកសួរចម្លើយនៅមន្ទីរសន្តិសុខហ្នឹងមានបានសួរចម្លើយទៅលើជនជាតិចាមទេ?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** មិនៗបានសួរចម្លើយទេ។

**ស៖** តើជនជាតិចាមដែលគេនាំទៅវត្តអូរត្រកួនហ្នឹង ត្រូវបានសម្លាប់ចោលទាំងអស់មែនទេ?

**ឆ៖** បាទ ជាការពិត។

**ស៖** លោកដឹងថាគេសម្លាប់ជនជាតិចាមនៅកន្លែងណាទេ បើធៀបទៅនឹងក្លោងទ្វារវត្តនោះ? តើមានកន្លែងណាមួយជាក់លាក់សម្រាប់សម្លាប់ជនជាតិចាមទាំងអស់ហ្នឹងទេ? ហើយកន្លែងសម្លាប់ជនជាតិចាមហ្នឹងវាខុសគ្នាពីកន្លែងសម្លាប់ជនជាតិខ្មែរមែនទេ?

[១៤:០២:២៧]

**ឆ៖** វាមិនខុសគ្នាទេ។ វាៗយកទៅសម្លាប់ គឺព្រលឹមឡើងគឺឃើញអស់ពីក្នុងវិហារតែម្តង។ ព្រោះគេយកទៅសម្លាប់ពេលយប់ មិនដឹងយប់ថ្មើរណា បើខ្ញុំជាក្មេង ខ្ញុំដូចខ្ញុំនិយាយអ៊ីចឹងថា ភាគច្រើនក្មេងចូលចិត្តដេកៗ។ អត់ដឹងគេ ថាគេយកសម្លាប់ម៉ោងប៉ុន្មានអីម៉ោងប៉ុន្មានអីផង ស្រាប់ព្រលឹមឡើងស្រាប់តែបាត់មនុស្សអស់រលីងទៅ អ៊ីចឹង។ ហើយយកទៅសម្លាប់នោះ គឺមិនជាឆ្ងាយពីកន្លែងវត្តទេ រាល់ថ្ងៃហ្នឹង គឺដីចម្ការរបស់គេហ្នឹង គឺគេលុបចោលអស់ហើយ គេដាំក្រូច ដាំចេកអស់ ប្រហែលជាថា ១០០ម៉ែត្រចុះ ពីកន្លែងៗដាក់ពីវត្តទៅនេះ មិនដល់ផង ប៉ុន្តែខ្ញុំស្មានទៅហ្នឹង ប្រហែលជាប៉ុណ្ណឹង។

**ស៖** ក្នុងសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញហ្នឹង លោកនិយាយថា គេមិនបានសួរចម្លើយអ្នកទោសច្រើនទេ គឺគេសម្លាប់តែម្តង ក្រោយពីឃុំបានបីបួនថ្ងៃ។ ដូច្នេះខ្ញុំចង់ដឹងថា <តើវាកើតឡើងដែរឬទេថា>ជនជាតិចាមណាដែលត្រូវបានគេនាំយកមកវត្តហើយ<ត្រូវបានគេ>សម្លាប់ចោលតែម្តង ដោយអត់មានឃុំខ្លួនទេ?

**ឆ៖** អាហ្នឹងខ្ញុំអត់ដឹង។

**ស៖** តើលោកធ្លាប់ឃើញការសម្លាប់ជនជាតិចាមហ្នឹង ដោយផ្ទាល់ភ្នែកលោកទេ នៅក្នុងបរិវេណវត្ត ឬក៏នៅជុំវិញបរិវេណវត្តហ្នឹង?

**ឆ៖** ខ្ញុំបានឃើញខ្លះដែរ ដោយសារជួនកាលគេ អ្នកធំគេហ្នឹងគេប្រើយើងយកទឹក យកអីទៅអ៊ីចឹងទៅណា ប៉ុន្តែខ្ញុំតក់ស្លុតណាស់។ ខ្ញុំចង់និយាយថា ខ្ញុំចង់យំតែម្តង ឃើញទិដ្ឋភាពហ្នឹង គឺខ្ញុំ

អាណោចអាធ័មណាស់។ ពួកម៉ាកខ្ញុំក៏ស្លាប់នៅហ្នឹង ស្រែកហៅឈ្មោះខ្ញុំទៀត។ ពេលនោះគឺខ្ញុំស្លុតស្មារតីមែនទែន ព្រឺអស់ហើយក្បាល ខ្ញុំជាក្មេងមួយស្លុត។

[១៤:០៥:១៧]

**ស៖** លោកបានឃើញគេសម្លាប់មនុស្សនុ៎ងប៉ុន្មានដងដែរ? លោកថាពេលខ្លះ អ៊ីចឹងចង់សួរដឹងថាប៉ុន្មានដងដែរ ពេលដែលលោកនិយាយថា ពេលខ្លះនុ៎ង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានឮសាក្សីថាគាត់បានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេ។ គាត់គ្រាន់តែឆ្លើយថា គាត់តក់ស្លុតណាស់។ តែនៅក្នុងថ្ងៃនេះ ក្នុងតុលាការគឺគាត់<មិន>បានឆ្លើយថា គាត់<បាន>ឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេ។ <លើកលែងតែមានការបកប្រែច្រឡំ។>

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបន្ថែមទៅនឹងការជំទាស់របស់មេធាវី កូប៉េ។ ជាភាសាបារាំង ខ្ញុំឮថា “ពេលខ្លះគេឲ្យខ្ញុំយកទឹកទៅ”។ នេះជាអ្វីដែលខ្ញុំស្តាប់ឮ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

ខ្ញុំឮ<>គាត់និយាយថា “បាទ ពេលខ្លះគាត់ឃើញ <ហើយគេឲ្យយើងយកទឹកទៅ>”។ អ៊ីចឹងខ្ញុំសួរម្តងទៀត។

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញការសម្លាប់មនុស្សហ្នឹងដោយផ្ទាល់ភ្នែកលោកទេ ទោះបីជាលោកមើលឃើញពីចម្ងាយក៏ដោយ?

[១៤:០៦:៣១]

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំគ្រាន់ថាគេប្រើទៅដល់ វាមិនទៅដល់កន្លែងជាក់ស្តែងទេ។ ខ្ញុំដូចថា ដំបូងខ្ញុំទៅគ្រាន់ជាថាយកទឹកទៅៗ គេឲ្យត្រឡប់មកវិញមក។ ប៉ុន្តែខ្ញុំលួចមើលទៅឃើញថា ដូចវាសាហាវពេកណ៎ាសាហាវត្រង់ថា មនុស្សរាប់រយដូចថាព្រលឹមឡើងបាត់អស់រលីង មិនដឹងគេធ្វើយ៉ាងម៉េចអីយ៉ាងម៉េច។

ខ្ញុំមិនដឹងដែរ។

**ស៖** ពេលដែលលោកយកទឹកទៅហ្នឹង នៅលើផ្លូវដែលនាំទៅរកប្រភពទឹកហ្នឹង ពីកន្លែងហ្នឹងទៅលោកមានបានឃើញហេតុការណ៍ដែលកើតឡើងនៅកន្លែងសម្លាប់មនុស្សហ្នឹងច្បាស់ទេ?

**ឆ៖** ខ្ញុំមិនបានឃើញច្បាស់ទេ គ្រាន់ថាទៅបានពាក់កណ្ដាលអ៊ីចឹងទៅ គេឲ្យខ្ញុំត្រឡប់មកវិញ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យអង្គជំនុំជម្រះបង្គាប់ទៅសហព្រះរាជអាជ្ញាវងអន្តរជាតិ ឈប់បញ្ចូលពាក្យនេះចូលមកក្នុងមាត់សាក្សីតែម្ដង<ដូចជាពាក្យ “ទីតាំងសម្លាប់” ឬ “បានឃើញការសម្លាប់”> ព្រោះសាក្សីអត់បាននិយាយដូចគាត់សួរអ៊ីចឹងទេ។ គាត់ថាប្រជាជនគេនាំចូលយកមក ហើយក៏បាត់អស់ទៅ ហើយគាត់រន្ធត់ណាស់។ គាត់អត់និយាយអំពីទីតាំងកន្លែងសម្លាប់ ហើយគាត់ក៏មិនបាននិយាយថាបានឃើញការសម្លាប់ហ្នឹងដោយផ្ទាល់ភ្នែក។ <ដូច្នេះ នេះជាការសួរនាំមុខ។>

[១៤:០៨:២៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន <ខ្ញុំមិនបានសួរនាំមុខសាក្សីទេ។> ខ្ញុំព្យាយាមបំភ្លឺ ពីព្រោះថាចម្លើយរបស់សាក្សីវាមិនច្បាស់។ អ៊ីចឹងហើយបានជាខ្ញុំសួរនោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** អ៊ីចឹងលោកសាក្សី ដើម្បីបំភ្លឺបញ្ហានេះឲ្យបានច្បាស់ ខ្ញុំសូមអានទូវចម្លើយរបស់លោក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺនៅចម្លើយទី៣៥ គឺក្នុងឯកសារដដែលE319/13.3.93។ លោកបានថា៖ “បាទ ខ្ញុំឃើញការសម្លាប់មនុស្សពីរបីដងដែរ។ គេសម្លាប់មនុស្សជាក្រុម ម្ដង១០នាក់ ហើយ<អ្នកទោសទាំងអស់ត្រូវបាន>គេចងស្លាបសេក។ គេបិទមុខ រួចនាំទៅមុខវត្តប្រហែលជាចម្ងាយ២០០ម៉ែត្រ ហើយនៅក្បែរនោះមានរណ្ដៅ<ដែលគេបានជីករួចហើយ>។ គេសម្លាប់អ្នកទោសនោះ ដោយប្រើ<ដែក>ភ្លៅរទេះ<ហើយទម្លាក់សាកសពទៅក្នុងរណ្ដៅ> ហើយក្នុងនុំងមានទាំងក្មេង ទាំងប្រុសទាំងស្រី។ មុនពេលស្លាប់នុំង ជនរងគ្រោះទាំងអស់នុំងស្រែកឲ្យគេជួយ។ ខ្ញុំបានស្ដាប់ឮថា ដំបូងឡើយហ្នឹង គេប្រើមីក្រូចាក់បំពងសំឡេង ដើម្បីបំភ័ន្តសម្រែកអ្នកទោស។ ប៉ុន្តែពេលដែលខ្ញុំបានឃើញនោះ

មិនមានការចាក់មីក្រូទេ ពីព្រោះការសម្លាប់អ្នកទោសហ្នឹង មានចំនួនតិចតួចប៉ុណ្ណោះ។" ដូច្នេះលោក សាក្សី តើលោកនឹកឃើញឡើងវិញទេ អំពីរឿងហេតុដែលថា លោកៗ បានឃើញការសម្លាប់នោះ? លោកៗបានឆ្លើយនៅក្នុងនេះ ថាលោកបានឃើញ <ឬបានស្ថិតនៅក្នុងហេតុការណ៍សម្លាប់ហ្នឹង>។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី កូប៉េ!

[១៤:១០:១៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងលក្ខណៈនៃការសួរបែបនាំមុខបែបនេះជាថ្មីម្តងទៀត។ គឺថាយើងគ្រប់គ្នា បានឃើញហើយថា <ចម្លើយដែលគាត់ផ្តល់ឲ្យគឺគ្មានតម្លៃ ពីព្រោះ>តំណាងសហព្រះរាជអាជ្ញា ព្យាយាមសួរនាំមុខជាច្រើន <>ដើម្បីទទួលបានចម្លើយដែលគាត់ចង់បាន។ <មានការខូចខាតរួចទៅ ហើយ។>

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំគ្រាន់តែព្យាយាមបំភ្លឺបញ្ហាតែប៉ុណ្ណោះ។ ខ្ញុំអានចម្លើយរបស់គាត់ពីមុន ខ្ញុំមិនបាន បង្កើតចម្លើយអីខ្លួនឯងទេ ហើយខ្ញុំសួរគាត់ថា តើគាត់ពិតជាបានឃើញការសម្លាប់មនុស្សហ្នឹង ដូចដែល គាត់បានឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬក៏អត់។ តែប៉ុណ្ណឹងទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ដែលជំទាស់នូវ សំណួរចុងក្រោយដែលសួរឡើងដោយសហព្រះរាជអាជ្ញារងនេះ។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរ ដែលសួរនេះ បើសិនបើជាលោកចាំសំណួរ។ បើលោកមិនចាំសំណួរ អាចសួរដល់តំណាងសហព្រះរាជ អាជ្ញាអន្តរជាតិ ឲ្យតាំងសំណួរនោះសាជាថ្មីវិញបាន។

**លោក មុយ វ៉ាន់នី៖**

បាទ សូមសួរសំណួរម្តងទៀត។

[១៤:១១:៤៤]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំអាននូវចម្លើយពីមុនរបស់លោក ដែលលោកបានឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនៅចម្លើយទី៣៥នុ៎ង លោកថា លោកបានឃើញពីរបីដងដែរ ឃើញគេសម្លាប់មនុស្សហ្នឹង ហើយលោកបានរៀបរាប់អំពីការសម្លាប់មនុស្សនោះទៀត។ ហើយជាចុងក្រោយនោះលោកថា៖ "ប៉ុន្តែពេលដែលខ្ញុំបានឃើញនោះ មិនមានការចាក់មីក្រូទេ ពីព្រោះការសម្លាប់អ្នកទោសមានចំនួនតិចតួចប៉ុណ្ណោះ។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់ឲ្យលោកនឹក<>មើល ថាតើលោកពិតជាបានឃើញការសម្លាប់មនុស្សមែន ឬក៏មិនមែន?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំអត់បានឃើញទេ។ គ្រាន់តែថា ដូចខ្ញុំនិយាយខាងដើមថា គ្រាន់ថាព្រលឹមឡើងវាបាត់មនុស្សហ្នឹងទៅអស់។ តើសកម្មភាពយ៉ាងម៉េច គឺខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំគ្រាន់តែថាមានសិទ្ធិ ដូចថាហុចទឹក ទឹកទៅហើយ ត្រឡប់មកវិញ គេឲ្យយើងមកវិញតែប៉ុណ្ណឹង។ ព្រលឹមឡើងអី ក៏ស្ងាត់មនុស្សអស់។ តែប៉ុណ្ណឹង។ អ៊ីចឹងយើងសន្មតថា គេយកទៅសម្លាប់អស់ហើយ អត់មានអី យកទៅណាទៅណីទៀតទេ។

**ស៖** ក្នុងសម្រង់ដែលខ្ញុំអាននោះ លោកបានផ្ដល់ព័ត៌មានលម្អិតជាច្រើន។ លោកថា គេសម្លាប់ជាក្រុម មានគ្នា១០នាក់ ហើយអ្នកទោសនីមួយៗត្រូវបានចងដៃស្លាបសេក និងបិទមុខ ហើយគេវាយនឹងដែកក្ដៅរទេះ ហើយក្នុងចំណោមអ្នកទោសហ្នឹង មានបុរស ស្ត្រី និងកុមារ។ បើលោកមិនបានឃើញការសម្លាប់មនុស្សទេ អ៊ីចឹងលោករៀបរាប់ហ្នឹង គេប្រាប់លោកទេ ឬក៏យ៉ាងម៉េច? ម៉េចបានជាលោកអាចរៀបរាប់លម្អិតម្ល៉េះនៅក្នុងចម្លើយរបស់លោកកាលពីមុននោះ?

<>

[១៤:១៣:៤៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ការ<ជំទាស់នឹងត្រូវបាន>បដិសេធ <ប្រាកដណាស់ ប៉ុន្តែជាថ្មី>ម្ដងទៀត គឺថាតំណាងសហព្រះរាជអាជ្ញានៅតែសួរសំណួរនាំមុខដដែល <គឺការលើកឡើងនូវចម្លើយដែលថាអាចនរណាម្នាក់ប្រាប់

គាត់>។ ដូច្នេះ ខ្ញុំសូមជំទាស់។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំអត់មានសួរនាំមុខអីទេ។ ខ្ញុំគ្រាន់តែព្យាយាមដោះស្រាយបញ្ហាដែលចម្លើយឆ្លើយខ្ទាស់គ្នានេះ<រវាងចម្លើយរបស់គាត់ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត និងសក្ខីកម្មនៅមុខអង្គជំនុំជម្រះនេះ>។ <សំណួរដែលខ្ញុំបានសួរទៅសាក្សីអម្បាញ់មិញនេះគឺថា តើគាត់បានឃើញការសម្លាប់មនុស្សទេ។ ហើយពេលនេះខ្ញុំសួរគាត់ថា តើគាត់ដឹងព័ត៌មានលម្អិតដោយសារតែមាននរណាប្រាប់គាត់ឬក៏យ៉ាងណា។> ហើយបើមិនបានឃើញទេ <គាត់អាចឆ្លើយថាមិនឃើញទៅ។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់នេះសាជាថ្មីម្ដងទៀត។ អង្គជំនុំជម្រះក៏ត្រូវការស្ដាប់ដើម្បីផ្ទៀងផ្ទាត់មើល ថាតើកំណត់ហេតុដែលផ្ដល់សក្ខីកម្មដែលអង្គជំនុំជម្រះយកធ្វើជាឯកសារសំអាងនៅក្នុងការសួរដេញដោលរបស់សាក្សីនេះ ពីសំណុំរឿងផ្សេង ហើយនិងការចម្លើយផ្ដល់សក្ខីកម្មនៅពេលនេះ តើវាមានខុសគ្នាយ៉ាងដូចម្ដេចដើម្បីអង្គជំនុំជម្រះថាតើគួរជឿយ៉ាងដូចម្ដេចនៅលើការ ទទួលយកភ័ស្ដុតាងដែលបានមកពីការដេញដោលនាពេលសវនាការនេះ ទៅបកស្រាយដើម្បីរៀបចំសាលក្រមនោះ។

[១៤:១៥:៣១]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ដូច្នេះលោកសាក្សី ខ្ញុំចង់ដឹងថា ហេតុដូចម្ដេចបានជាលោកដឹងព័ត៌មានលម្អិតម្ល៉េះ នៅពេលដែលលោករៀបរាប់ប្រាប់ការិយាល័យសហព្រះរាជអាជ្ញានោះ? តើលោក<បាន>ដឹង<ព័ត៌មានលម្អិតនេះ>មកពីណា មានអ្នកណាប្រាប់លោក<នៅក្នុងរយៈពេលនោះ>ឬ?

**ឆ៖** ខ្ញុំដឹងតាមខ្ញុំឆ្ងល់។ ឆ្ងល់ថាមនុស្សទៅណាអស់រលីងហើយព្រលឹមឡើង គេថាអូនឯងដឹងទេ? អត់ដឹងផង គេយកទៅណា? ថាគេយកទៅសម្លាប់អស់រលីង។ បានខ្ញុំដឹងត្រឹមពេលហ្នឹង ហើយគេយកទៅសម្លាប់របៀបយ៉ាងម៉េចអី សួរខ្ញុំស្ពុតរឿងបញ្ហាហ្នឹងដែរ។

**ស៖** ពេលដែលលោកធ្វើការនៅវត្តអូរត្រកួន ខ្ញុំដឹងថា វាពិបាកចំពោះលោក។ លោកថា លោកបាន<បន្តធ្វើការ>នៅទីនោះ ៥ឬ៦ខែ ក្រោមបង្គាប់របស់ ហាន។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកឃើញមនុស្សប៉ុន្មាននាក់ដែល<>បាន<>ចូលមកវត្តនៅពេលនោះ? លោកថា ពេលខ្លះមានក្រុមគ្នាតិច ពេល

ខ្លះមានគ្នាច្រើន ពី<៥០ ទៅ> ១០០នាក់អ៊ីចឹងម្តងៗ។ អ៊ីចឹងលោកអាចជម្រាបបានទេថា ក្នុងអំឡុងពេលដែលលោកធ្វើការនៅទីនោះ ចំនួន<មនុស្ស>ដែល<បាន>ចូលទៅ<ក្នុងវត្ត>សរុបទាំងអស់មានប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំមិនមែនអ្នកធ្វើស្ថិតិខាងហ្នឹងផង អត់ដឹងថាចំនួនថាប៉ុន្មានទេ ប៉ុន្តែគ្រាន់តែថា សាកសពនៅកន្លែងនោះ គេចុះនៅនោះថាជាង៣០.០០០នាក់។ គេសរសេរនៅ គេធ្វើស្តូបមួយសម្រាប់ដាក់ធាតុហ្នឹង។

**ស៖** នេះជាប្រធានបទចុងក្រោយរបស់ខ្ញុំ តើលោកធ្លាប់ទៅក្បែរវត្តទេ ក្រោយថ្ងៃទី០៧ មករា ៧៩ ក្រោយពេលដែលវៀតណាមវាយចូលនោះ លោកធ្លាប់ទៅកន្លែងដែលមានរណ្តៅសាកសពហ្នឹងទេ? គឺខ្ញុំចង់ដឹងថា ក្រោយពីថ្ងៃទី០៧ មករា ឆ្នាំ៧៩ លោកធ្លាប់ទៅមើលរណ្តៅសាកសពហ្នឹងវិញទៀតទេ? <ឬក៏លោកមិនដែលត្រឡប់ទៅទីតាំងនោះទេ?>

**ឆ៖** ខ្ញុំអត់បានទៅមើលទៀតទេ ព្រោះដូចថាវាអត់មានរឿងអីដែលយើងត្រូវទៅមើល រួចយើងវាផ្ទះឆ្ងាយផង មិននៅផ្ទះជិតឯណា។ ប៉ុន្តែសព្វថ្ងៃហ្នឹង គឺគេលុបបំបាត់អស់រលីងហើយ អត់ទុកអីជាភស្តុតាង ក្រហែងក្រហូងដូចអីផ្សេងទៀត កន្លែងផ្សេងទៀតគេទុកជាភស្តុតាង នៅនោះគឺគេម្ចាស់ចម្ការគេ គេភ្ជាមៗនោះ គេលុបដាំជាដំណាំអស់រលីងទាល់សព្វថ្ងៃហ្នឹង។

[១៤:១៩:០៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលៈ**

សូមអរគុណលោកប្រធាន ខ្ញុំអស់ពេលហើយ។ ខាងសហព្រះរាជអាជ្ញាជាតិក៏អត់មានសំណួរដែរ ក៏ប៉ុន្តែខាងសហមេធាវីនាំមុខ<ដើមបណ្តឹងរដ្ឋប្បវេណី>គាត់មានសំណួរខ្លះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងភាគី សាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរប្រាំប្រាំមួយសំណួរទេសម្រាប់សួរលោកសាក្សីរូបនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមជម្រាបសួរលោកសាក្សី។ ខ្ញុំបាទ ឈ្មោះ ពេជ អង្គ ជាមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាមួយលោកស្រី ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំសូមសួរសំណួរមួយចំនួនបញ្ជាក់បន្ថែមទៅលើអ្វីដែលសហព្រះរាជអាជ្ញាបានសួរអម្បាញ់មិញ។ ខ្ញុំបានឮលោកនិយាយថា នៅពេលដែលលោកយកទឹក យកទៅឲ្យគេ លោកបានលួចមើល។ តើលោកអាចបញ្ជាក់បានទេ លោកបានលួចមើលអ្វីនាពេលនោះ?

[១៤:២០:២០]

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំបាទឃើញគេចងមនុស្ស បណ្ដើរចេញទៅ តែបានតែត្រឹមប៉ុណ្ណឹង។ ចូលមកឃុំមុខទៅ គេដាក់ខ្សែពីក្រោមដៃចងស្លាបសេកហ្នឹង គ្រាន់តែឃើញប៉ុណ្ណឹង។ រួចទៅ ខ្ញុំត្រឡប់មកវិញ។

**ស៖** លោកអាចបញ្ជាក់បានទេ មនុស្សដែលលោកបានឃើញដែលគេចងស្លាបសេក ថាតើពួកគាត់មានគ្នាច្រើនទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! ឆ្លើយ!

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំអត់បានឃើញថាមានមនុស្សប៉ុន្មាននាក់សម្រាប់ចងអ្នកទោសហ្នឹងដែរ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ប្រហែលជាសំណួរខ្ញុំសួរខុសមើលទៅ។ តើអ្នកដែលគេចងហ្នឹង ឬក៏អ្នកដែលគេបញ្ជូនទៅហ្នឹងមានគ្នាច្រើនទេ?

**ឆ៖** មិនមានគ្នាច្រើនទេ។

[១៤:២១:៣៨]

**ស៖** លោកអាចនិយាយចំនួនបានទេ ប៉ុន្មាននាក់? ប្រហាក់ប្រហែលក៏បានដែរ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ម៉ុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំមិនអាចប៉ាន់ស្មានបានទេ ព្រោះអត់ឃើញការពិត។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ខ្ញុំដូចជាច្របូកច្របល់បន្តិច។ អម្បាញ់មិញលោកថាបានឃើញគេបណ្តើរមនុស្សចងស្លាបសេកពីក្រោយខ្នង។ តើអ្នកដែលលោក ដែលគេបណ្តើរទៅ ដែលលោកបានឃើញហ្នឹង តើមានគ្នាប៉ុន្មាននាក់ដែរ ដែលលោកបានឃើញមនុស្សដែលលោកបានឃើញ ហើយដែលគេចងស្លាបសេកគាត់បណ្តើរទៅហ្នឹង? លោកអាចនិយាយបានទេ គ្នាប៉ុន្មាននាក់ ដែលគេចងយកទៅហ្នឹង?

**ឆ៖** ចងមនុស្សសម្លាប់ហ្នឹង ដូចអ្នកបញ្ជូនពីកន្លែងទៅ មានពីរបីនាក់អីអ៊ីចឹងទៅ។

**ស៖** បាទ សូមទោស ខ្ញុំគិតថា សំណួរខ្ញុំដូចអត់ច្បាស់ដដែល។ អ្នកដែលត្រូវបានគេចង អ្នកដែលត្រូវបានគេចង ដែលគេបណ្តើរគាត់ទៅ គាត់មានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** មានពីពីរនាក់ទៅបីនាក់។

**ស៖** អ៊ីចឹងអ្នកដែលត្រូវបានគេ -- អ្នកដែលជនរងគ្រោះដែលគេបញ្ជូនទៅ មានគ្នាតែពីរបីនាក់អ៊ីចឹងអ្ហ៎! ខ្ញុំសូមបញ្ជាក់ម្តងទៀត ជាជនរងគ្រោះហ្នឹងគឺមានគ្នាតែពីរបីនាក់ទេ អ៊ីចឹងមែនទេ?

[១៤:២៣:៣១]

**ឆ៖** អ៊ូ! ស្តាប់សំណួរអត់បាន អំមិញគ្រាន់តែថា អ៊ីចេះអ្នកដែលគេត្រូវយកទៅសម្លាប់ហ្នឹង ខ្ញុំឃើញគ្នាបួនដប់នាក់។ នឹកស្មានថា សួរខ្ញុំថា អ្នកបញ្ជូន អ្នកដែលយកទៅសម្លាប់ហ្នឹង គឺអ្នកដែលគេចងហ្នឹងគឺចងមួយសាបួនដប់នាក់ៗ អ៊ីចឹង។

**ស៖** បាទ អ៊ីចឹងមួយសាបួនដប់នាក់ៗ អ៊ីចឹងមានន័យថាលោកបានឃើញ មិនមែនតែមួយសាមែនទេ អ្នកដែលគេ ជនរងគ្រោះដែលគេចងបញ្ជូនទៅ? លោកបានឃើញប៉ុន្មានសាដែរ?

**ឆ៖** ខ្ញុំបានឃើញតែម្តងហ្នឹងទេ ដូចថាចៃដន្យគេ ដូចថាខ្ញុំនិយាយអំមិញថា គេឲ្យយកទឹកអីយកទៅឲ្យគោលដៅរបស់គេហ្នឹងណ៎ា គោលដៅកន្លែងគេបញ្ចេញហ្នឹង គឺខ្ញុំបានត្រឹមហ្នឹង ហើយខ្ញុំឃើញគេដោតមួយជួរចេញមក ខ្ញុំក៏ត្រឡប់មកវិញមក។

**ស៖** បាទ សូមអរគុណ។ តើថ្ងៃ ឬក៏ពេលដែលគេបញ្ជូនមនុស្សយកចេញទៅ ប្រហែលបួនដប់នាក់ដែលលោកបានឃើញហ្នឹង លោកអាចបញ្ជាក់បានទេ តើមានអ្នកផ្សេងទៀតដែលគេមិនទាន់បញ្ជូនទៅ ដែលនៅរង់ចាំដែលត្រូវគេបញ្ជូននៅពេលក្រោយទៀតទេ នៅលើវិហារ?

**ធ៖** ខ្ញុំមិនបានដឹងដែរ។ ដូចខ្ញុំនិយាយខាងដើម ថាព្រលឹមឡើងគឺអស់មនុស្សតែម្តង ខ្ញុំមិនដឹងថាអីយ៉ាងម៉េចទៀត អីយ៉ាងម៉េចនោះ គឺខ្ញុំ--។

**ស៖** បាទ អរគុណ។ ព្រលឹមឡើងអស់មនុស្ស ចុះពេលដែលលោកឃើញពួកគាត់ដំបូងគឺឃើញនៅពេលល្ងាច ឬក៏ពេលព្រលប់ ឬក៏ពេលយប់នៅពេលដែលលោកដឹងថាមានមនុស្សចូលមកនៅក្នុងវិហារហ្នឹង? ហើយអ្នកដែលនៅក្នុង -- គេយកទៅដាក់នៅក្នុងវិហារហ្នឹង គ្នាប៉ុន្មាននាក់ លោកអាចបញ្ជាក់បានទេ?

[១៤:២៥:៤៥]

**ធ៖** ខ្ញុំមិនអាចបញ្ជាក់បានទេ ព្រោះថា ដូចខ្ញុំនិយាយពីខាងដើមថា ឃើញមនុស្សណែនវិហារមិនដឹងជាប៉ុន្មាន ព្រោះខ្ញុំនៅស្ទើរ ហើយខ្ញុំមិនកាន់តួនាទីខាងហ្នឹងផង។ ប៉ុនដឹងថាមនុស្សវាច្រើន។

**ស៖** លោកនិយាយថាណែនវិហារ ខ្ញុំចាប់អារម្មណ៍ពាក្យហ្នឹង។ ថាណែនវិហារ វិហារធំប៉ុនណាដែរដែលមានមនុស្សនៅណែនហ្នឹង លោកអាចបញ្ជាក់បានទេ? ប៉ុន្មានម៉ែត្របួនជ្រុង បណ្តោយប៉ុន្មាន ទទឹងប៉ុន្មាន ហើយដែលមានមនុស្សនៅណែនវិហារហ្នឹង?

**ធ៖** ខ្ញុំពិបាក មិនអាចបញ្ជាក់បានទេ ព្រោះវិហារយើងសព្វថ្ងៃហ្នឹងមិនដឹងប៉ុន្មាន មិនដឹងបណ្តោយប៉ុន្មាន អីប៉ុន្មានផង ស្តង់ដាររបស់ធ្វើវិហារហ្នឹង។

**ស៖** អ៊ីចឹងលោកអាចបញ្ជាក់ខ្ញុំមួយទៀតបានទេ វិហារហ្នឹងជាវិហារដែលមានទំហំស្តង់ដារនៃវិហារធម្មតាអ៊ីចឹងមែនទេ?

**ធ៖** បាទ វិហារធម្មតាហ្នឹង។

**ស៖** ចុះអ្នកដែលនៅក្នុងវិហារដែលលោកមើលឃើញថាមានណែនវិហារហ្នឹង លោកអាចបញ្ជាក់បានទេ លោកដឹងថាគាត់ជាជនជាតិអី ជាខ្មែរ ឬក៏ជាចាម?

**ធ៖** ភាគច្រើនគឺចាម។ ខ្មែរតិចតួចណាស់ បើតាមខ្ញុំមើលទៅណា ព្រោះវាដូចខ្ញុំនិយាយខាងដើម ខ្ញុំឮគេនិយាយដែរថាគេមានផែនការសម្លាប់ចាមហ្នឹងទាំងពូជហ្នឹងគឺថាវា ដូចខ្ញុំនិយាយថានៅក្នុងកង ស្រុកកងមាសមានតែពីរនាក់ប្តីប្រពន្ធដែលរស់នៅហ្នឹង ខ្ញុំដល់ពេលដាច់ហើយបានឮគេនិយាយអីគាត់នៅសព្វថ្ងៃរាល់ថ្ងៃហ្នឹងទៀត។

[១៤:២៧:៤២]

**ស៖** បាទ ខ្ញុំនឹងសួរសំណួរអំពីបញ្ហាផែនការនេះនៅពេលក្រោយ។ ចង់សួរបញ្ជាក់បន្តិច លោក

ធ្វើម៉េចបានដឹងថាមនុស្សដែលនៅក្នុងវិហារហ្នឹង គឺភាគច្រើនគឺជាជនជាតិចាម? តើលោកបាននិយាយជាមួយពួកគាត់ ហើយដឹងថាគាត់ហ្នឹងជាចាម ឬក៏គេប្រាប់លោកថាពួកគាត់គឺជាជនជាតិចាម? តើអាចបញ្ជាក់អំពីបញ្ហាហ្នឹង?

**ឆ៖** ខ្ញុំមិនបានសួរនាំគាត់ទេ ព្រោះកាលខ្ញុំសួរអ្នកដែលនៅដូចថាចុងភៅ ចុងអីគេអ៊ីចឹងណ៎ា ខ្ញុំថា គាត់ជាខ្មែរ ឬក៏អីអ៊ីចឹងទៅ។ ធម្មតាអ្នកទោស គេមិនដែលទុកបង្ហួចឱ្យយើងមើលអីអ៊ីចឹងទេ គឺយើងដឹងតាមរយៈដូចថាអ្នកទោសដូចគ្នាហ្នឹង អីទៅធូរស្រាលអ៊ីចឹងទៅ គេឱ្យធ្វើការបន្តិចបន្តួចអី មានគេអ្នកយាមអីផ្សេងៗ មានតួនាទីគេផ្សេងៗពីគ្នា ខ្ញុំគ្រាន់តែឃើញអ៊ីចឹង ទិដ្ឋភាពអ៊ីចឹងទេ។

**ស៖** បាទ អរគុណ។ ខ្ញុំចង់សួរបញ្ជាក់បន្តិចជុំវិញអ្នកដែលនៅក្នុងមន្ទីរសន្តិសុខក្នុងវត្តហ្នឹង តើលោកនៅចាំទេ ពេលដែលលោកនៅមន្ទីរសន្តិសុខ -- នៅក្នុងវត្តហ្នឹង ថាតើមានមនុស្សប៉ុន្មាននាក់ដែលគេធ្វើការនៅក្នុងវត្តហ្នឹង? ហើយពួកគាត់មានតួនាទីអីខ្លះដែលធ្វើការនៅក្នុងវត្តហ្នឹង?

**ឆ៖** ខ្ញុំមិនបានដឹងតួនាទីមួយៗទេ ក៏ប៉ុន្តែគ្រាន់តែដឹងថាអត់ពីឈ្មោះ ហាន ហ្នឹងទៅ គឺអ្នកទទួលខុសត្រូវបន្ទាប់គឺឈ្មោះ អីទេអំមិញ គួង ហើយនិង បុត្រ ហ្នឹងប៉ុន្តែ បុត្រ ហ្នឹងសម្លាប់ គេសម្លាប់ចោលហើយ ដូចខ្ញុំនិយាយអំមិញអ៊ីចឹង។ បន្ទាប់មកបានឡើងត្រឹម គួង ខ្ញុំដឹងត្រឹម គួង ហ្នឹង។

**ស៖** ពេលដែលគេយកចាមដែលលោកនិយាយថាមានពេញវិហារហ្នឹងមក ថាតើអ្នកណាគេជាអ្នកនៅនឹងវត្តហ្នឹង ជាអ្នកនៅគ្រប់គ្រងវត្តហ្នឹង? ឈ្មោះ គួង ឬក៏ឈ្មោះ បុត្រ ឬក៏ ហាន ជាអ្នកនៅគ្រប់គ្រងវត្តហ្នឹង លោកអាចបញ្ជាក់បានទេ?

**ឆ៖** មានតែឈ្មោះ គួង ទេ។

**ស៖** ហើយអ្នកផ្សេងទៀត ក្រៅពី គួង ហ្នឹង តើលោកមាននៅចាំទេ ពេលនោះមាននរណាគេផ្សេងទៀត លោកមានស្គាល់ឈ្មោះទេ? ហើយមានប៉ុន្មាននាក់ដែលនៅពេលនោះ?

**ឆ៖** អត់មាន បើ មានតែអនុប្រធានហ្នឹងមួយសម្រាប់គ្រប់គ្រងអ្នកទាំងនុ៎ង។

**ស៖** ខ្ញុំចង់និយាយអ្នកផ្សេងទៀត ដែលមិនមែនជាគ្រប់គ្រង អ្នកធ្វើការក្រោមបង្គាប់ពួកគាត់មានគ្នាប៉ុន្មាននាក់ដែលធ្វើការក្រោមបង្គាប់ពួកគាត់នៅពេលនោះ ដែលបណ្ដើរមនុស្សចេញទៅ? ហើយលោកមានបានឃើញទេ?

**ឆ៖** មានគ្នាប្រហែលជា១០នាក់ ធ្វើការនៅក្នុងវត្តហ្នឹង។

**ស៖** លោកមាននៅចាំឈ្មោះពួកគាត់ខ្លះទេ?

[១៤:៣១:១៣]

**ផ៖** ចាំបានខ្លះ ប៉ុន្តែមិនដឹងនៅឯណា។

**ស៖** សូមរៀបរាប់បានខ្លះ បើសិនថាលោកនៅចាំ សូមអញ្ជើញ!

**ផ៖** មានឈ្មោះ មឿន, ឈ្មោះ ភ្លេចអស់ហើយបង ភ្លេច។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ជាមួយលោក ដោយលោកនិយាយថា លោកបានឮមិត្តរបស់លោកហៅឱ្យជួយ តើលោកបាននិយាយអីចឹងមែនទេ មុនៗនេះ ពេលដែលខាងសហព្រះរាជអាជ្ញាអន្តរជាតិបានសួរលោកនោះ?

**ផ៖** បានឮដោយចៃដន្យ។ ពេលនោះឯង គឺពេលដែលគេប្រើខ្ញុំទៅយកទឹកទៅឱ្យនោះ ទទួលពេលនោះ គឺគេហៅគាត់ចង។

**ស៖** អីចឹងមិត្តរបស់លោកហ្នឹងហៅឱ្យលោកជួយតែម្តង ឬគាត់ហៅជាឱ្យមនុស្ស ដូចជាទូទៅឱ្យគេជួយផងអីចឹង? គាត់បានឃើញលោក ឬក៏យ៉ាងម៉េច?

**ផ៖** គាត់បានឃើញខ្ញុំ គាត់ស្គាល់ខ្ញុំច្បាស់។

**ស៖** លោកអាចនិយាយបានទេ គាត់ឈ្មោះអី?

**ផ៖** ភ្លេចទាំងឈ្មោះទៀតនុំង វាប្រហែលៗគ្នា។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធទៅនឹងបញ្ហានេះ។ មិត្តរបស់លោកហ្នឹងជនជាតិអី តើលោកអាចបញ្ជាក់បានទេ ជាតិអី?

**ផ៖** គាត់ជនជាតិខ្មែរ។

**ស៖** បាទ អរគុណច្រើន។ ខ្ញុំមានសំណួរមួយទៀត ដែលលោកបាននិយាយថា លោកឮថាមានផែនការប្រមូលចាម តើអ្នកណាគេនិយាយអំពីផែនការនេះឱ្យលោកដឹង ឬក៏លោកបានឮពីអ្នកណាគេដែលនិយាយថាមាន -- គេមានផែនការប្រមូលចាម?

[១៤:៣៣:៥៦]

**ផ៖** អ្នកនៅក្នុងវត្តហ្នឹង ដែលគេនៅយូរជាងខ្ញុំហ្នឹង។ ខ្ញុំលបសួរគេ ហើយគេប្រាប់ថាអីចឹង។

**ស៖** គេមាននិយាយលម្អិតពីរឿងហ្នឹង ថាហេតុអ្វីបានជាគេមានផែនការប្រមូលចាម? គេមានជម្រាបលោករហូតដល់បញ្ហាហ្នឹងទេ?

**ផ៖** អត់មានទេ។

**ស៖** បាទ អ៊ីចឹងសំណួរខ្ញុំចុងក្រោយត្រឡប់មកវិញបន្តិច ពេលដែលលោកយកទឹកយកទៅជូនគេហ្នឹង លោកអាចបញ្ជាក់ទេ ប្រហែលជាម៉ោងប៉ុន្មានដែលលោកយកទឹកយកទៅឱ្យគេនុ៎ង? ពេលយប់ ឬក៏ពេលល្ងាច ឬក៏ពេលព្រឹក?

**ឆ៖** ពេលម៉ោងប្រហែលប្រាំពីរ។

**ស៖** ប្រាំពីរព្រឹក?

**ឆ៖** ប្រាំពីរយប់។

**លោក ពេជ អង្គ៖**

បាទ អ៊ីចឹងអរគុណច្រើនចំពោះការឆ្លើយសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

[១៤:៣៥:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាក -- សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ប៉ុន្តែតាមភាសាបារាំង ខ្ញុំអត់បានស្តាប់ឮចម្លើយចុងក្រោយទេ ខ្ញុំមិនដឹងថាម៉ោងប្រាំពីរហ្នឹង ប្រាំពីរព្រឹក ឬក៏ប្រាំពីរយប់នោះទេ។ ដូច្នេះប្រសិនបើជាការល្អ សូមឱ្យមានការបកប្រែជាភាសាបារាំងផង ចំពោះចម្លើយចុងក្រោយនេះ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ លោកសាក្សី តើលោកអាចបញ្ជាក់អម្បាញ់មិញ ថាតើលោកបានឃើញគេបណ្តើរមនុស្សហ្នឹង ម៉ោងប្រាំពីរព្រឹក ឬក៏ម៉ោងប្រាំពីរយប់?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ម៉ោងប្រាំពីរយប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥២ នាទី)*

[១៤:៥២:០៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ហើយដោយសារមានចៅក្រម មានបំណងតាំងសំណួរដេញដោលចំពោះសាក្សីនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរដេញដោលសាក្សីនេះ មុននឹងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមជម្រាបសួលោកសាក្សី ខ្ញុំមានសំណួរមួយចំនួន ដើម្បីឲ្យលោកជួយបញ្ជាក់បំភ្លឺទៅលើចំណុចមួយចំនួន ដែលលោកបានផ្តល់សក្ខីកម្មនៅព្រឹកនេះ។ ជាដំបូង តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើនៅពេលណាដែលលោកចាប់ផ្តើមធ្វើការនៅវត្តអូរត្រកួន?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** ខ្ញុំអត់បានដឹងពីខែឆ្នាំអីទេ ប៉ុន្តែដូចខ្ញុំបាននិយាយ ដូចថារបបនោះគឺ ខ្ញុំនៅកុមារីនៅឡើយ នៅកុមារ។ ពេលដែលចូលមក ក៏អត់ដឹងថាឆ្នាំណាខែណាអ៊ីចឹង។

[១៤:៥៤:០២]

**ស៖** ប៉ុន្តែលោកអាចប្រាប់បានទេ ថាតើលោកឈប់ធ្វើការនៅពេលណាដែរ? តើលោកឈប់

នៅមុនពេលខ្មែរក្រហមដួលរលំយូរ<ហើយ> ឬក៏លោកឈប់បានបន្តិចទៅរបបខ្មែរក្រហមដួលរលំ?

**ឆ៖** ខ្ញុំនៅទាល់តែដាច់។ នៅទាល់តែដាច់ខ្មែរក្រហមនុ៎ង គឺកងទ័ពវៀតណាមចូលមកអ៊ីចឹងទៅ គឺត្រឹមហ្នឹងគឺចប់ហ្នឹង។

**ស៖** នៅពេលដែលលោកឈប់ហ្នឹង នៅពេលដែលលោកចេញហ្នឹង តើនៅមានសល់អ្នកទោសនៅក្នុងគុកនុ៎ងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះកាលហ្នឹងកងទ័ពវៀតណាមចូលមក គឺខ្ញុំត្រូវរត់ទៅផ្ទះវិញ។

**ស៖** នៅពេលដែលលោកនៅវត្តអូរត្រកួន តើលោកអាចធ្វើដំណើរទៅកន្លែងផ្សេងៗ<ក្នុងបរិវេណមន្ទីរសន្តិសុខហ្នឹង>បានដែរឬទេ? គឺខ្ញុំចង់មានន័យថា លោកអាចធ្វើដំណើរទៅអគារផ្សេងៗគ្នា ទៅកន្លែងផ្សេងៗគ្នានៅក្នុងមន្ទីរសន្តិសុខហ្នឹងដែរឬទេ?

**ឆ៖** គឺអត់មានមន្ទីរអីច្រើនទេ។ ដូចថានៅនឹងវត្តហ្នឹងមាននៅសាលាលោកអ៊ីចឹងទៅ អត់មានមនុស្សអីផង ដាក់ទៅចូលក្នុងវិហារអស់រលីងហើយ។ បើនិយាយរឿងអ្នកទោសវិញ គេដាក់ក្នុងវិហារអស់ហើយ យើងមិនអាចទៅឯណាណីទៀតទេ។

**ស៖** ហើយលោកបាននិយាយអំពីការសួរចម្លើយ ថាតើលោកអាចមើលឃើញកន្លែងដែលគេសួរចម្លើយមនុស្សនោះទេ?

**ឆ៖** ខ្ញុំគ្រាន់តែថា ដឹងកន្លែងថាគេសួរចម្លើយកន្លែងហ្នឹង។ ដឹងប៉ុណ្ណឹង គ្រាន់តែស្គាល់កន្លែងគេសួរចម្លើយ ប៉ុន្តែមិនដែលទៅដឹងថាគេសួរពីអីៗ គឺខ្ញុំអត់ដឹង។

**ស៖** មិនអីទេលោក។ ដូច្នេះតើលោកដឹងទេថា គេសម្លាប់មនុស្សនៅកន្លែងណាដែរ?

**ឆ៖** គេសម្លាប់មនុស្សនោះ ខ្ញុំដឹងថា យកទៅក្រៅវត្ត។

[១៤:៥៦:២៧]

**ស៖** តើលោកដឹងទេថា កន្លែងគេសម្លាប់ហ្នឹងនៅកន្លែងណាឲ្យជាក់លាក់ទេ?

**ឆ៖** បើសិនជាសព្វថ្ងៃហ្នឹង បើសិនអស់លោកអញ្ជើញទៅ ក៏វាមានកន្លែងនុ៎ងឲ្យសព្វថ្ងៃមើលដែរ ប៉ុន្តែគ្រាន់ថា ដឹងចម្ងាយប៉ុន្មានៗ ដឹង ហើយមានឆ្អឹងមានអីសម្រាប់នៅកន្លែងគេធ្វើស្តូបហ្នឹង។

**ស៖** មិនអីទេ។ អ្វីដែលខ្ញុំចង់ដឹង គឺថា<តើលោកអាចធ្វើអ្វីបានខ្លះ ហើយតើ>អ្វីដែលលោកដឹងនៅពេលដែលលោកធ្វើការនៅវត្តអូរត្រកួន ខ្ញុំចង់ដឹងថា នៅពេលហ្នឹងតើលោកដឹងទេថា តើគេសម្លាប់មនុស្សនៅកន្លែងណាដែរ នៅពេលសម័យនោះ?

**ឆ៖** ដូចខ្ញុំនិយាយអំមិញថា នៅខាងមុខវត្តអូរត្រកួនតែម្តង។

**ស៖** តើធ្វើយ៉ាងម៉េចបានលោកដឹងថា គេសម្លាប់នៅមុខវត្តហ្នឹង?

**ឆ៖** បើសព្វថ្ងៃហ្នឹងខ្ញុំនៅក្បែរហ្នឹងដែរ ខ្ញុំដឹង ឃើញកន្លែងគេសម្លាប់ហ្នឹង។ មិនមែនដឹងជំនាន់នោះ ឃើញទេ។ សូម្បីតែសព្វថ្ងៃហ្នឹង ប្រជាពលរដ្ឋនៅស្រុកខ្ញុំ នៅកន្លែងណាផ្សេងៗគេមកគោរពវិញ្ញាណក្ខន្ធ ក៏គេអាចទៅមើលកន្លែងនោះបានដែរ។ គេប៉ាន់ស្មានថាពី ដឹងថាកន្លែងនេះ នៅមុខវត្ត ស្រះលោកអ៊ីចេះទៅ គឺសុទ្ធតែកន្លែងសម្លាប់មនុស្ស តែប៉ុណ្ណឹង។

**ស៖** លោកសាក្សី ខ្ញុំស្តាប់ទៅដូចជាមិនយល់ច្បាស់។ លោកនិយាយថា មុននេះបានន័យថា លោកមិនដែលត្រឡប់ទៅវត្តអូរត្រកួនវិញទេ ក្រោយពេលដែលលោកចាកចេញពីកន្លែងនោះ<ដែលលោកជាកងការពារ>។ ដូច្នេះខ្ញុំមិនយល់ ហេតុអ្វីបានជាលោកដឹងអំពីព័ត៌មានទាំងអស់នេះ គឺក្រោយពេលដែលលោកចាកចេញពីវត្តអូរត្រកួនហ្នឹង? ដូច្នេះខ្ញុំមើលទៅឃើញមានការផ្ទុយគ្នា ប៉ុន្តែឥឡូវនេះខ្ញុំចង់អានឱ្យលោកស្តាប់នូវចម្លើយមួយ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E319/19.3.93។ គឺយើងនិយាយអំពីសំណួរចម្លើយ៧៧ ហើយសំណួរដូចតទៅនេះ៖ “ហេតុអ្វីបានជាលោក<អាច>មើលឃើញ<>ការសួរចម្លើយអ្នកទោស <និង>ការសម្លាប់អ្នកទោស? តើលោកអាចមើលឃើញតាមវិធីណា? ឆ្លើយ ខ្ញុំអាចធ្វើដំណើរមើលកន្លែងនេះ កន្លែងនោះតាមចិត្ត។ ហើយជាទូទៅដូចជាទៅកន្លែងសម្លាប់មនុស្ស ឬក៏ទៅកន្លែងសួរចម្លើយអ្នកទោស គឺខ្ញុំទៅជាមួយប្រធានរបស់ខ្ញុំ។” ដូច្នេះចំពោះខ្ញុំឃើញថាចម្លើយលោកនេះ គឺច្បាស់លាស់ណាស់។ ដូច្នេះតើលោកចាំទេថា លោកបានផ្តល់ចម្លើយបែបនេះ? ហើយថាតើចម្លើយដែលលោកផ្តល់កាលពីពេលមុនហ្នឹង វាជាចម្លើយត្រឹមត្រូវដែរឬទេ?

[១៥:០១:៤១]

**ឆ៖** បាទ ខ្ញុំដូចជាគ្មានអីហួសពីការដែលខ្ញុំនិយាយពីខាងដើមអ៊ីចឹង ថាខ្ញុំអត់មានតួនាទីអីទៅមើលកន្លែងនុ៎ង ទៅពិនិត្យ។ ហើយគ្រាន់តែដឹងថា ខ្ញុំឆ្ងល់ខ្លួនខ្ញុំថា មនុស្សក្រោយពីនៅក្នុងហ្នឹងពីរបីថ្ងៃមក ស្រាប់តែលេងអស់រលីងនេះ។ ដល់តែសួរទៅ គេថា យប់មិញមនុស្សទៅណាអស់ទៅ? ព្រលឹមឡើងស្រាប់តែអស់មនុស្ស ថាគេយកទៅសម្លាប់ចោល។ គ្រាន់ដឹងប៉ុណ្ណឹង។ ដូចថាដើរឱ្យទៅមើលកន្លែងនុ៎ងអីយ៉ាងម៉េចៗ គឺខ្ញុំគ្មាន។ ដូចថាខ្ញុំវានៅក្មេង ខ្ញុំមិនហ៊ានដើរ ជួនកាលទី១ គឺខ្លាចខ្មោចតែម្តងហ្នឹងហ្មង និយាយឱ្យអស់បណ្តោយ ខ្លាច។

**ស៖** លោកបានបញ្ជាក់មុននេះបន្តិចថា គេឲ្យលោកជួយយកទឹកទៅឲ្យអ្នកទោស។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកយកទឹកហ្នឹងទៅឲ្យអ្នកណា ទៅឲ្យនៅកន្លែងណា?

**ឆ៖** ឲ្យទឹកហ្នឹងក៏មិនឆ្ងាយពីកន្លែងដែលស្នាក់នៅរបស់ខ្ញុំដែរ កន្លែងមេហ្នឹងណ៎ា វាអត់ឆ្ងាយពីដូចថា ឧទាហរណ៍កុដិមួយទៅកុដិហ្នឹង វានៅជិតគ្នាដែរ មិនជាឆ្ងាយដែរ ប្រហែលជាប្អូនដប់ម៉ែត្រអីអ៊ីចឹងទៅ ពីកន្លែងគេវិហារហ្នឹង ព្រោះវិហារនៅខាងមុខអ៊ីចេះ កន្លែងមនុស្សនៅខាងក្រោយវិហារហ្នឹង។ យើងធ្លាប់ដឹងហើយថា វិហារហើយនិងកុដិហ្នឹង វាមិននៅជាឆ្ងាយប៉ុន្មានដែរទេ។

**ស៖** តើលោកយកទឹកហ្នឹងទៅឲ្យអ្នកណាដែរ? យកទៅឲ្យប្រធានរបស់លោក ឬក៏លោកយកទឹកហ្នឹងទៅឲ្យអ្នកទោស?

[១៥:០៤:០២]

**ឆ៖** យកឲ្យអនុប្រធានគេហ្នឹង ដូចថាមេគេអត់នៅអ៊ីចឹង ខ្ញុំទៅ ជួនកាលខ្ញុំ ចៃដន្យខ្ញុំនៅកន្លែងផ្ទះមេហ្នឹង។ ដល់អ៊ីចឹងគេហៅ ស្រែកហៅឲ្យយើងយកទឹកអ៊ីចឹងទៅ មួយភ្លែតហ្នឹងណ៎ា។ រួចទៅខ្ញុំត្រឡប់មកវិញមក ព្រោះខ្ញុំអត់មានភារកិច្ចអីទៅ អីផ្សេងពី ប្រាប់ថា អត់ពីមេទៅ គឺខ្ញុំនៅចាំផ្ទះតែម្តង។

**ស៖** នៅពេលដែលលោកយកទឹកទៅឲ្យម្នាក់នោះ តើលោកបានឃើញអ្នកទោសទេ?

**ឆ៖** បាទ ពេលនោះហើយដែលខ្ញុំនិយាយខាងដើម ថាពេលដែលយកទឹកហ្នឹង ដូចចៃដន្យ គេបញ្ចេញអ្នកទោស គេចងយកទៅអ៊ីចឹងហ្នងណ៎ា។ រួចក៏ខ្ញុំត្រឡប់មកវិញមក។

**ស៖** តើអ្នកទោសហ្នឹងនៅកន្លែងណាដែរ? ថាតើ<អ្នកទោសនោះនៅកន្លែងជាមួយ>ប្រធាន<ឬនៅក្នុងជាមួយ>អនុប្រធាន<>? ថាតើ<អ្នកទោសទាំងនោះ>នៅក្នុងរោងរួម ឬមួយក៏នៅកន្លែងណាឲ្យច្បាស់លាស់?

**ឆ៖** ប្រធានគេ អនុប្រធានគេហ្នឹង គេអ្នកគ្រប់គ្រងអ្នកទោសហ្នឹង គឺគេអ្នកប្រចាំការនៅកន្លែងហ្នឹងហ្នង ពេលដែលត្រូវការអីយ៉ាងម៉េចៗ គេអនុប្រធានហ្នឹងគេអ្នកដឹងទៅ គេព័ត៌មានគេអីផ្សេងៗជាមួយអ្នកដែលគេធ្វើឃាតហ្នឹងណ៎ា ចង់និយាយអ៊ីចឹង។ ហើយចំណែកខ្ញុំគ្មាន អត់មានដឹងអីទេ ព្រោះខ្ញុំវានៅតែជាមួយមេរហូតនោះ មេមិននៅគឺខ្ញុំនៅចាំកន្លែង។ ហើយបើអ៊ីចឹងទេ ខ្ញុំទៅនៅកន្លែងកងទាហានអ៊ីចឹងហ្នង ក្រុមទាហានប្រចាំការអីតាមភូមិតាមអី នៅមួយអាទិត្យអីអ៊ីចឹងទៅ។

**ស៖** លោកសាក្សី សូមលោកឆ្លើយសំណួររបស់ខ្ញុំឲ្យបានច្បាស់។ នៅពេលដែលលោកយកទឹកហ្នឹង ថាតើអ្នកទោសហ្នឹងនៅឯណា? ហើយតើលោកឃើញអ្នកទោសទេ? ប្រសិនបើលោកឆ្លើយថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើញអ្នកទោស តើលោកឃើញអ្នកទោសនៅកន្លែងណា?

**ឆ៖** អ្នកទោសនៅក្នុងវិហារ។

[១៥:០៧:១៤]

**ស៖** ដូច្នេះលោកឃើញអ្នកទោសហ្នឹងនៅក្នុងវិហារមែនទេ? តើលោកបានចូល<>ទៅក្នុងវិហារហ្នឹងដែរឬទេ?

**ឆ៖** គឺអត់បាន គេមិនអនុញ្ញាតឲ្យយើងចូលទៅក្នុងវិហារនោះដោយគ្មានការអនុញ្ញាតពីអនុប្រធានទេ។ ទោះបីខ្ញុំនៅជាមួយមេក៏ដោយ គឺការងារវាមិនអាចទៅបាន។

**ស៖** ខ្ញុំស្តាប់អត់យល់ទេ លោកសាក្សី។ តើលោកឃើញអ្នកទោសតាមជញ្ជាំង ឬមួយ – ដូច្នេះខ្ញុំចង់សួរលោកថាតើលោកធ្វើយ៉ាងណាអាចមើលឃើញអ្នកទោសបាន នៅពេលដែលអ្នកទោសហ្នឹងនៅក្នុងវិហារ? ប្រសិនបើលោកមិនអាចចូលទៅក្នុងវិហារទេ ធ្វើម៉េចលោកមើលឃើញអ្នកទោសកើត?

**ឆ៖** ខ្ញុំនៅឈរខាងក្រៅ ហើយវិហារហ្នឹងវាៗបែងចែកជាពីរ។ ខាងស្រីៗនោះគេៗមានបង្អួចគេ គេអត់មានអីមិនជាយកចិត្តទុកដាក់ដូចប្រុសៗទេ។ ដល់អ៊ីចឹងគេឃាំងមុខវិហារ មុខបល្ល័ង្កនោះមួយចំហៀង ខាងក្រោយព្រះហ្នឹងគឺស្រីៗ។ អ៊ីចឹងមួយកំណាត់អ៊ីចេះប្រុស មួយកំណាត់អ៊ីចេះស្រី។ អ៊ីចឹងខ្ញុំអើតឃើញតាមចម្រឹងដែកហ្នឹង គឺគេចំហនេះទ្វារហ្នឹងណ៎ា។

**ស៖** អ៊ីចឹងលោកឃើញតាមបង្អួច ហើយលោកក៏បាននិយាយផងដែរ ថាលោកមិនបានឃើញការសម្លាប់មនុស្សទេ ប៉ុន្តែលោកបាននិយាយថាលោកបានសង្កេតឃើញថានៅថ្ងៃក្រោយមកគឺបាត់មនុស្សអស់<។ តើពួកគេ>បាត់<បាត់>ពីក្នុងវិហារ<អស់ឬ?> ដូច្នេះខ្ញុំចង់សួរថាតើលោកបានត្រឡប់ទៅមើលវិហារ គឺ<ដើរកាត់ខាងមុខ>វិហារ<>ហ្នឹងដែរឬទេ នៅពេលដែលលោកថា<>លោកឃើញបាត់មនុស្សពីវិហារហ្នឹង?

[១៥:០៩:៤៤]

**ឆ៖** ខ្ញុំអត់បានឃើញទេ ក៏ប៉ុន្តែវាស្ងាត់ជ្រាបតែម្តង វាអត់មានដូចថាបបរអីដូចថាវាតិចតួចអីវាគ្មាន វាធ្លាប់តែថាឧទាហរណ៍បបរមួយខ្ទះ វាទៅជាមួយកន្លះខ្ទះអីអ៊ីចឹង ឧទាហរណ៍ណ៎ា មិនដឹងជាបាត់មនុស្សទៅណា។ ហើយដូចខ្ញុំបាននិយាយអ៊ីចឹងថា ក្រោយពីមកហ្នឹង យើងដឹងថាវាបាត់មនុស្ស គេមុខតែយកទៅសម្លាប់ហើយ ពីក្នុងចិត្តរបស់ខ្ញុំ។

**ស៖** មិនអីទេលោក។ <>យើង<បាន>និយាយអំពីវិហារ គឺថា<បើខ្ញុំមិនច្រឡំទេ> វាមាន

<>មួយផ្នែកគេឃុំមនុស្សប្រុស មួយផ្នែកទៀតគេឃុំមនុស្សស្រី។ តើលោកអាចប្រាប់អង្គជំនុំជម្រះបានទេ ថាតើមានមនុស្សប៉ុន្មាននាក់ដែរនៅក្នុងវិហារនុ៎ង?

**ឆ៖** តាមខ្ញុំស្មានគឺថា ដូចខ្ញុំនិយាយអ៊ីចឹងថាមានមនុស្សច្រើន ខ្ញុំអត់មានតួនាទីថាទៅរាប់មនុស្សឱ្យវាដឹងចំនួនថាប៉ុន្មាន គឺអត់ មិនអាចដឹងបានទេ។

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញសាកសពមនុស្សនៅវត្តអូរត្រកួនទេ?

**ឆ៖** ពេលនោះគឺខ្ញុំមិនបានឃើញទេ។ ដល់ពេលដាច់ក្រោយមកបានឃើញគេគាស់ស្នើយកមាសយកប្រាក់អី ដាច់ហើយហ្នឹងណា៎។ កាលដាច់នោះប្រជាជនយើង ក្រៗហ្នឹងនាំគ្នាទៅគាស់ថា មានមាសមានអីនោះ ផ្អើលទៅជីកស្នើនុ៎ង គឺខ្ញុំមិនទាន់មកនៅហ្នឹងដែរ មិនទាន់ដូចថាចូលបម្រើការងារនៅនុ៎ង គ្រាន់និយាយតគ្នាហ្នឹង ឃើញគេ មានគេជីកបានមាស បានអីពីអ្នកនៅក្នុងសាកសពនោះ។ បានជាបានឆ្អឹងបានអីយកមកទុកជាភ័ស្តុតាង។

[១៥:១២:៣៦]

**ស៖** មុននេះបន្តិចលោកបាននិយាយអំពីជនរងគ្រោះប្រហែលជា៣០.០០០នាក់។ ថាតើ<>ខ្ញុំស្តាប់អ្វីដែលលោកនិយាយថា មានជនរងគ្រោះ ៣០.០០០នាក់ហ្នឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំមិនប្រាកដថាៗ ៣០.០០០ ប៉ុន្តែគេសរសេរនៅកន្លែងស្តូបហ្នឹងថាជាង ៣០.០០០នាក់ ៣០.០០០ អេ្អ! ខ្ញុំមិនចាំទេ ដឹងតែថាបីម៉ឺនប៉ុន្មានពាន់នាក់ទេ។ នៅសព្វថ្ងៃហ្នឹងគេសរសេរនៅកន្លែងស្តូបហ្នឹង។ មិនពីណាអ្នកយកស្ថិតិហ្នឹង ដឹងស្ថិតិ ក៏ការប៉ាន់ស្មានក៏មិនដឹង វាអត់ដឹង។

**ស៖** មិនអីទេលោក មុននេះលោកក៏និយាយអំពីៗ<ចម្ការ>ដើមស្វាយ ហើយលោកនិយាយថា ដើមស្វាយត្រូវបានគេដាំនៅតាមកន្លែងដែលគេ<កប់>សាកសព។ ហើយខ្ញុំចង់ដឹងថា តើ<ពេល>ណាដែលគេដាំដើមស្វាយនោះ? ហើយអ្នកណាជាអ្នកដាំដើមស្វាយនុ៎ង?

**ឆ៖** ដាំដើមស្វាយហ្នឹង គឺម្ចាស់ដីកេរដំណែលរបស់គេតែម្តង។ ក្រោយពីដាច់មក គេដូចថាគេប្រកបផ្នែកកសិកម្ម ផ្នែកដំណាំដាំដុះហ្នឹងណា៎ ដាំចេកទៅ ដាំក្រូចឆ្មារទៅ។ ហើយដល់ឥឡូវដូចដីធម្មតាដែរឥឡូវ គេលែងឱ្យគាស់ ឱ្យអីទៀតហើយ ព្រោះជាកេរដីរបស់គេ។

**ស៖** <មិនអីទេ ប៉ុន្តែអត់>មានចម្ការទាំងអស់នុ៎ងទេនៅពេលដែលលោកធ្វើការនៅវត្តអូរត្រកួននុ៎ង <តើមែនទេ>?

**ឆ៖** អើខ្ញុំមើលទៅពីចម្ងាយទៅឃើញតែដើមស្លា ចេកអី ល្មុតអីពីដូនតាគេមកណា៎។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ឥឡូវនេះ ខ្ញុំចង់ឲ្យលោកប្រាប់អង្គជំនុំជម្រះបន្តិច ថាតើលោកស្គាល់ឃុំអង្គរបានដែរឬទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្គាល់កម្មាភិបាល<គ្រប់គ្រង>នៅមន្ទីរសន្តិសុខនៅអង្គរបានហ្នឹងដែរឬទេ?

[១៥:១៦:១៣]

**ឆ៖** បាទ ស្គាល់តើ ប៉ុន្តែសព្វថ្ងៃមិនដឹងនៅឯណា។ គ្រាន់តែស្គាល់គាត់នៅឃុំអង្គរបានមែន ប៉ុន្តែដល់ពេលដាច់ ប៉ុល ពត ហ្នឹងមិនដឹងជាទៅណាទៅណីអី មិនបានដឹង។

**ស៖** តើលោកចាំឈ្មោះគាត់ទេ?

**ឆ៖** ខ្ញុំចាំតើ ថាគាត់ឈ្មោះ គួង ហ្នឹងហើយ។

**ស៖** នៅថ្ងៃ១៤ ខែកញ្ញា ២០១៥ គឺថាសាក្សីម្នាក់គាត់មកដល់ផ្តល់សក្ខីកម្មនៅទីនេះ <ឈ្មោះ សែន ស្រ៊ុន>។ ខ្ញុំមិនចាំរហស្សនាមរបស់គាត់ទេ ប៉ុន្តែសាក្សីរូបនោះ បាននិយាយអំពីមនុស្សម្នាក់ឈ្មោះ <រុន> ដែលជាប្រធានមន្ទីរសន្តិសុខនៅអង្គរបាន។ តើលោកនឹកឃើញឈ្មោះ <រុន> ទេ?

**ឆ៖** ខ្ញុំដូចជាគ្មានឮឈ្មោះហ្នឹងទេ ព្រោះធម្មតាដូចខ្ញុំនិយាយអ៊ីចឹងថា អត់មានការងារអីក្រៅពីដើរជាមួយមេៗ ហើយគេមានការងារអី មេគេនិយាយជាមួយមេគ្នាគេទៅ ហើយយើងទៅអីដឹងរឿងហេតុការណ៍ គឺអត់មានដឹង។ អត់ស្គាល់ថាឃុំនេះ អ្នកនេះធ្វើប្រធានឃោធាឃុំអី គឺអត់ដឹង មិនដឹង។

**ស៖** តើលោកមានធ្លាប់ចូលរួមការប្រជុំដែលដឹកនាំដោយ កាន និង <ហន> ដែរឬទេ? <>

**ឆ៖** ខ្ញុំបាននិយាយរួចហើយ អាហ្នឹងសួរខ្ញុំម្តងហើយ ប៉ុន្តែខ្ញុំអត់បានឃើញទេ។ ធម្មតាគេមេៗ ហើយយើងត្រឹមដូចហៅថា ដើរតាមគេ គេអាណាគេឲ្យយើងដឹង។

[១៥:១៨:៥៨]

**ស៖** ខ្ញុំមិនមែននិយាយអំពីការប្រជុំដែលមេៗទាំងអស់ជុំគ្នានោះឡើយ ខ្ញុំនិយាយពីការប្រជុំដែល <រៀបចំសម្រាប់>សមាជិកសហករណ៍ <សាធារណជន និងថ្នាក់ស្រុក>។ ថាតើលោកធ្លាប់ចូលរួមការប្រជុំធំរួមមួយដែលដឹកនាំដោយ កាន ដែលជាប្រធាន<ស្រុក>ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែល – ខ្ញុំអត់ដែលឃើញផង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែរ៖**

សូមអរគុណលោកសាក្សី ខ្ញុំមិនមានសំណួរបន្ថែមទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីជនជាប់ចោទ ដែលដំបូងនេះ ផ្ដល់វេទិកាជូននៅក្រុមសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរតិចតួចទេ សម្រាប់សួរទៅលោកនៅថ្ងៃរសៀលនេះ។ សំណួរដំបូងរបស់ខ្ញុំ គឺខ្ញុំសួរអំពីថ្ងៃខែឆ្នាំកំណើតរបស់លោក។ ខ្ញុំបានសរសេរមកថាថ្ងៃកំណើតរបស់លោក គឺថ្ងៃទី០៧ ខែមិថុនា ១៩៦៧ហ្នឹង លោកបានឆ្លើយថ្ងៃនេះ ក៏ថាអ៊ីចឹងដែរ។ ត្រឹមត្រូវដែរទេ?

[១៥:២០:៥៤]

**លោក មុយ វ៉ាន់នី៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកធ្លាប់ឮ ឬក៏ឪពុកម្ដាយរបស់លោកធ្លាប់ប្រាប់លោកថា ថ្ងៃកំណើតរបស់លោកតាមពិតទៅ គឺ<>វាមិនមែនជាថ្ងៃទី០៧ ខែមិថុនា ៦៧ គាត់ដែលប្រាប់ថាអ៊ីចឹងទេ?

**ឆ៖** តាមការពិតទៅ គឺខ្ញុំយកអាយុធ្វើការរបស់ខ្ញុំ។ លោកគ្រូគាត់ដាក់ឲ្យអ៊ីចឹងទៅ ជាប់រហូតទាល់សព្វថ្ងៃហ្នឹង។

**ស៖** ហើយតើលោកដឹងថា ឬក៏ថាឯកសារមួយណា ឬក៏ប្រភពព័ត៌មានមួយណាដែលគ្រូរបស់លោកនេះ គាត់ៗយកមកសំអាង នៅពេលដែលលោកគ្រូរបស់លោកជាអ្នកកំណត់ថ្ងៃខែឆ្នាំកំណើតរបស់លោកអ៊ីចឹង? តើគាត់មានប្រភពអីមកពីណាទេ ទើបផ្លាស់ប្ដូរថ្ងៃខែឆ្នាំកំណើតរបស់លោកអ៊ីចឹង?

**ឆ៖** អឺ ខ្ញុំអត់បានដឹងដែរ ព្រោះធម្មតា ថាយកកូនទៅបង្រៀនគឺឪពុកម្ដាយខ្ញុំអ្នកឲ្យឆ្នាំកំណើតទៅលោកគ្រូហ្នឹងហើយ។

**ស៖** ដូច្នេះខ្ញុំសូមធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយដើម្បីកុំឲ្យមានការច្រឡំគ្នា គឺលោកប្រកាន់យកថ្ងៃខែឆ្នាំកំណើតនោះគឺថ្ងៃទី០៧ ខែមិថុនា ១៩៦៧។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការពិត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:២៣:១០]

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយថ្មី។ នៅពេលដែលលោកចាប់ផ្តើមធ្វើការជាមួយ ហាន បើខ្ញុំយល់មិនច្រឡំទេ គឺលោកយកៗលិខិតពី ហាន ទៅឲ្យអ្នកដទៃទៀត គឺលោកធ្វើការកំប៉ិកកំប៉ុកទេ<ឲ្យហាន>។ ប៉ុន្តែលោក<>ចាត់ទុកខ្លួនឯងថា លោកគឺជាកងការពាររបស់ ហាន។ តើការងាររបស់លោកនេះ ការពារសន្តិសុខឲ្យ ហាន ក្រែងលោមានអ្នកណាប្រទូសរ៉ាយមកលើគាត់<? តើនោះជាការណែនាំដល់លោក> ឬថាលោកគ្រាន់តែធ្វើការកំប៉ិកកំប៉ុកមួយចំនួនឲ្យគាត់ ដូចជានាំយកសំបុត្រពីគាត់ទៅឲ្យអ្នកណាអីចឹង?

**ឆ៖** បាទ អាហ្នឹងវាធម្មតា មេត្រូវការប្រើអីចឹងហើយ ប៉ុន្តែគ្រាន់ថា ខ្លឹមសារយ៉ាងម៉េចគឺអត់ដឹងថា អ្ហែ! យកទៅត្រូវធ្វើអីចេះៗ គឺយើងអត់ដឹង។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ អាចមានបញ្ហាពាក់ព័ន្ធទៅនឹងពាក្យពេចន៍ដែលលោកបានប្រើប្រាស់ទៅ ដល់ហើយបកប្រែទៅវាមិនចំ។ <>តាមខ្ញុំដឹងហ្នឹងគឺថា <> ពាក្យថា "បូឌី ហ្គាដ"នេះ "កងការពារ" នេះ មានន័យថា កាលណាប្រើពាក្យថា "កងការពារ" ហ្នឹងគឺលោកត្រូវការពារឈ្មោះ ហាន ពីគ្រោះថ្នាក់ផ្សេងៗ ដូចជាការវាយប្រហារដោយរូបភាពណាមួយជាដើម។ ឥឡូវខ្ញុំ<សូមរៀប>សំណួរ<ឡើងវិញ>ទៅចុះ តើ ហាន នេះធ្លាប់ត្រូវបានអ្នកណាម្នាក់លបវាយប្រហារអីមកលើគាត់ទេ? ហើយ<>លោកនេះ<ធ្លាប់បាន>ជួយការពារពីការវាយប្រហារហ្នឹងដែរទេ?

**ឆ៖** គឺអត់ដែលមានផង។

**ស៖** លោកធ្លាប់ទទួលបានការបណ្តុះបណ្តាលខាងយោធាដែរទេ?

**ឆ៖** អត់ដែលផង។

[១៥:២៦:០៣]

**ស៖** លោកក៏មិនមែនជាកម្មាភិបាលថ្នាក់ក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** បាទ។

**ស៖** លោកបានឆ្លើយថា ពេលខ្លះលោកស្ពាយកាំភ្លើង អា.កា៤៧។ អ្នកណា<>បង្ហាត់បង្រៀនឲ្យលោកប្រើប្រាស់កាំភ្លើងនុ៎ង?

**ឆ៖** ពេលនោះគឺអត់មានបង្រៀនអីទេ ហៅទៅថា "អាអូន អ្ហែងជិះម៉ូតូទៅមួយបង" អីចឹងទៅ

គេឲ្យកាំភ្លើងពាក់ស្ពាយទៅ។ ដល់ពេលក្រោយមកបានគេបង្ហាត់យើង របៀបបាញ់យ៉ាងម៉េចអីយ៉ាងម៉េច ប៉ុនមិនដែលបាញ់ មិនដែលបានបាញ់អីផង។

**ស៖** តើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថាតាមពិតទៅការងាររបស់លោកហ្នឹង គឺថាមិនមែនជាកងការពាររបស់ៗគាត់ទេ ប៉ុន្តែដោយសារតែលោកក្មេងមែនទែន អ៊ីចឹងក៏គេឲ្យលោកធ្វើការកំប៉ិកកំប៉ុកជាមួយគាត់។ បើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរទេ?

**ឆ៖** ពិត។

**ស៖** ខ្ញុំសូមចូលទៅនិយាយពេលវេលាដំបូងដែលលោកចាប់ផ្តើមធ្វើការជាមួយនឹង ហាន។ លោកថាលោកឈប់ធ្វើការងារជាមួយ ហាន នៅពេល<ចុងបញ្ចប់នៃ>របបខ្មែរក្រហម <នៅពេលដែលវៀតណាមចូល>។ សូមលោកបញ្ជាក់ជូនតុលាការឲ្យបានច្បាស់មើល ថាតើលោកធ្វើការឲ្យ ហាន អស់រយៈពេលប៉ុន្មាន? ខ្ញុំដកស្រង់សម្តីរបស់លោក លោកឆ្លើយថា សូមដកស្រង់៖ “ធ្វើការមួយរយៈពេលខ្លីទេ” បញ្ចប់ការដកស្រង់។ ពាក្យ “រយៈពេលខ្លី” កន្លែងនេះ តើលោកសំដៅថាពីរបីខែ បីបួនខែ ឬក៏<ប្រាំមួយខែ តើ>រយៈពេលប៉ុន្មាន<ឲ្យជាក់លាក់>? ដូច្នេះជាថ្មីម្តងទៀត សូមលោកឆ្លើយជូនតុលាការថាលោកធ្វើការងារឲ្យ ហាន ជាមួយ ហាន អស់រយៈពេលប៉ុន្មាន?

[១៥:២៨:៥៧]

**ឆ៖** តាមការពិតទៅ ខ្ញុំដូចខ្ញុំនិយាយខាងដើមថា មិនដឹងជាប៉ុន្មាន ការប៉ាន់ស្មានខ្ញុំគឺរយៈពេលខ្លីដែរទេ ហើយពេលនោះគឺនៅជាមួយទាល់តែដាច់តែហ្មង ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង។ ដាច់ ប៉ុល ពត ៗឆ្លងតាមកំពង់ចាមហ្នឹងមកនុ៎ង គឺយើងរត់ទៅផ្ទះរៀងខ្លួន។ គេទៅៗ បែកខ្ញែកគ្នាទៅ រត់សំដៅទៅរកផ្ទះ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ថារយៈពេលនេះវាយូរហើយ។ ហើយវាពិបាកនឹងឲ្យលោកឆ្លើយឲ្យចំៗ ថាតើលោកធ្វើការរយៈពេលប៉ុន្មានឲ្យពិតប្រាកដឲ្យ ហាន។ សំណួរគ្រាន់តែសួរ លោកឆ្លើយថារយៈពេលខ្លី រយៈពេលខ្លីហ្នឹងប៉ុន្មាន ពីរខែ បីខែ ពីរបីសប្តាហ៍? សូមលោកបញ្ជាក់ឲ្យបានជាក់លាក់ជូនតុលាការបន្តិចមើល៍?

**ឆ៖** ថាមិនតិចទេ ហើយក៏មិនច្រើនដែរ ប្រហែលជាប្រាំប្រាំមួយខែអី។

**ស៖** សូមអរគុណលោកសាក្សី។ តើវាត្រឹមត្រូវដែរទេ បើសិនណាជាខ្ញុំនិយាយថា ការធ្វើការងារកំប៉ិកកំប៉ុកដូចជានីរសារឲ្យ ហាន នេះ តើនេះលោកធ្វើតែកិច្ចការប៉ុណ្ណោះទេឬ? <លោកមិនបាន

ធ្វើការនៅ>មន្ទីរសន្តិសុខអូរត្រកួន<ជាផ្លូវការទេ> គឺលោកទៅហ្នឹងគឺ ដោយសារតែ ហន ទៅទីនោះទេ ទើបបានលោកមានឱកាសទៅមន្ទីរសន្តិសុខអូរត្រកួននោះ អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** បាទ ទាល់តែគាត់ទៅ ចុះទៅអូរត្រកួន បានខ្ញុំទៅជាមួយគាត់។ បើគាត់នៅកន្លែងទាហានទេ ខ្ញុំក៏នៅកន្លែងទាហាននុំងជាមួយគាត់ហ្នឹងទៅ។

[១៥:៣១:៣៨]

**ស៖** តើលោកនៅចាំបានទេក្នុងរយៈពេលប្រាំប្រាំមួយខែនុំង តើលោក<>បានទៅសម្រាក<> នៅវត្តអូរត្រកួន<ប៉ុន្មានយប់>ដែរ<> នៅពេលដែលលោកធ្វើការជាមួយនឹង ហន? តើលោកធ្លាប់បានទៅដេកនៅវត្តអូរត្រកួនបានប៉ុន្មានយប់ដែរ?

**ឆ៖**ជួនកាលបានទៅសម្រាកនោះ បើមេគេសម្រាកទៅហត់នឿយ គេសម្រាកបានពីរយប់អីអ៊ីចឹងទៅ ឬក៏បីយប់អ៊ីចឹងទៅ ថ្ងៃគេទៅចុះ គេហៅថាចុះតាមទាហាននុំងបន្តិចបន្តួច គេត្រឡប់មកសម្រាកវិញមក។

**ស៖** <>លោក<បាននិយាយមុននេះ>ថា សម្រាក<ពីរ>បី<>យប់អ៊ីចឹង តើលោក<អាចបញ្ជាក់ពី>រយៈពេល<នៃការសម្រាកហ្នឹង ជាសប្តាហ៍ ឬជាខែបានទេ?> ឥឡូវខ្ញុំសួរអ៊ីចេះ ថាតើក្នុងមួយខែ <>លោកបានទៅដេកនៅវត្តអូរត្រកួនបានប៉ុន្មានយប់?

**ឆ៖** ជួនកាលមួយយប់ទៅ ជួនកាលពីរយប់អ៊ីចឹងទៅ តាមមេរបស់ខ្ញុំ។ ប៉ុន្តែគ្រាន់តែថា គឺនៅសម្រាកនៅហ្នឹងគឺតិចណាស់ សម្រាកនឹងអូរត្រកួនហ្នឹង។

**ស៖** តើជាទូទៅ ហន គាត់ដេកនៅនឹងផ្ទះគាត់ ឬក៏យ៉ាងណានៅពេលដែលលោកធ្វើការជាមួយគាត់ប្រាំប្រាំមួយខែនុំង?

**ឆ៖** សុំម្តងទៀត។

[១៥:៣៤:២៥]

**ស៖** សំណួររបស់ខ្ញុំគឺខ្ញុំចង់ដឹង ថាក្នុងមួយខែលោកបានទៅដេកនៅវត្តអូរត្រកួនប៉ុន្មានយប់? ឥឡូវខ្ញុំរៀបសំណួរសាជាថ្មី។ តើក្នុងខែខ្លះលោកបានទៅដេកនៅវត្តអូរត្រកួនដោយសារតែមេរបស់ លោក ហន ហ្នឹងទៅវត្តអូរត្រកួន។ អ៊ីចឹងក្នុងមួយខែ តើលោកដេកនៅវត្តអូរត្រកួនហ្នឹងបានប៉ុន្មានយប់ដែរ?

**ឆ៖** ជួនកាលដេកបានមួយយប់ទៅ ជួនកាលពីរយប់អ៊ីចឹងទៅ។ ដូចខ្ញុំបាននិយាយខាងដើមថា បើមេ ដូចថាអស់កម្លាំងអ៊ីចឹងទៅ គាត់មកសម្រាកអី មួយយប់អ៊ីចឹងទៅ។ តែពីរយប់អី គាត់ចុះទៅតាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មូលដ្ឋានទ័ពហ្នឹងវិញទៅ។

**ស៖** ហើយ<ភាគច្រើន>មេរបស់លោកឈ្មោះ ហាន ដេកនៅកន្លែងកងទ័ពស្នាក់នៅហ្នឹង ឬក៏ ហាន ដេកនៅផ្ទះរបស់គាត់? <តើត្រឹមត្រូវដែរឬទេ?>

**ឆ៖** ពេលដែលគាត់ត្រឡប់មកកន្លែងអូរត្រកួនវិញ គាត់ដេកសម្រាកនៅនឹងផ្ទះ កន្លែងគាត់ផ្ទះមួយផ្សេងជាមួយខ្ញុំហ្នឹង។

**ស៖** នៅមុននេះបន្តិច លោកបានរៀបរាប់ថា នៅយប់មួយនោះ លោកបានឃើញគេចងអ្នកទោស។ នៅពេលដែលលោកបានឃើញគេចងអ្នកទោសហ្នឹង គឺនេះជា<យប់មួយដែលលោកស្នាក់នៅវត្តអូរត្រកួន ហើយ>លោកបានឃើញគេចងអ្នកទោសហ្នឹង?

[១៥:៣៦:៤៧]

**ឆ៖** បាទ ខ្ញុំឃើញហ្នឹងជាលើកដំបូងហើយ ដែលខ្ញុំ ដូចខ្ញុំបាននិយាយថាខ្ញុំស្លុត ដែលឃើញហ្នឹង ខ្ញុំស្លុតណាស់។

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត។ ពីខាងដើមនេះ លោកត្រូវបានសួរអំពីបទល្មើសតូចតាច បទល្មើសស្រាល ហើយនិងបទល្មើសធ្ងន់ធ្ងរ។ តើលោកចាំទេ ថាលោកបាននិយាយអំពីបទល្មើសស្រាល និងបទល្មើសធ្ងន់ធ្ងរ?

**ឆ៖** បទល្មើសស្រាលៗហ្នឹង ដូចថាវាពិបាកដែរ អាគ្រាន់តែលួចដំឡូង លួចអីបន្តិចបន្តួចអីចឹងទៅ ដូចថាមាននំអីចឹងទៅ គេចាប់អីចឹងណា៎។ អាហ្នឹងប្រជាជនយើងសាមញ្ញ សូម្បីតែប្អូនខ្ញុំក៏គេចង់រកចាប់ដែរ គ្រាន់តែចង់រក គ្រាន់តែថា ជ្រូកគ្រាន់តែឈ្នុសអាដីហ្នឹងចេញមើមដំឡូង យកមកស៊ីខ្ចីហ្នឹង ក៏ប្រធានកងហ្នឹងរករឿងដែរ។ និយាយឲ្យអស់អីចឹងទៅ។ អីចឹងអាទោសហ្នឹង ក៏វាទៅតាមហ្នឹងទៅ ហើយណាមួយ គេយល់ថាក្មេង ចុះបើមនុស្សចាស់វិញ អាហ្នឹងខ្ញុំមិនដឹងថាយ៉ាងម៉េច។

**ស៖** ប៉ុន្តែការញែកពីគ្នា ដែលលោកបានឆ្លើយទាំងក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត ក៏ដូចជាមុននេះ <>តើលោកធ្វើការញែកដាច់ពីគ្នានេះ ដោយសារតែលោកមានបងប្អូន<>ធ្លាប់<>មានទោសស្រាលអីចឹង ឬក៏លោកធ្វើការញែកទោស<ដាច់>ពីគ្នា ថាមានទោស<ស្រាល ឬ>ទោសធ្ងន់ហ្នឹង ដោយ<លោកបានឮពីអ្នកនៅវត្តអូរត្រកួនមែនដែរឬទេ>?

[១៥:៣៩:៣០]

**ឆ៖** ខ្ញុំ វាមិនបានដឹងថាស្រាលធ្ងន់ដែរ ប៉ុន្តែគ្រាន់តែថា បើក្មេងអាហ្នឹងវា ដូចថាគេអាចអត់ឱន

អីបន្តិចបន្តួចបាន ព្រោះយើងជាប្រជាជននៅស្រុកភូមិ។ ហើយបើចាស់ហ្នឹង ក៏ឃើញថា ដូចថាគេធ្លាប់អប់រំអ៊ីចឹង ថាកុំ មានចេកកុំកាប់ចេកស៊ីអី បាត់ចេកមួយស្ទង មួយស្និតអី គេរករឿង អាហ្នឹងវាអ៊ីចឹង ព្រោះតាមខ្ញុំ តាមមើលទៅ ភាគច្រើន តែមានដំណាំនៅនឹងផ្ទះហ្នឹង កាប់ហូបមិនបានផង ចុះបើបាត់ផ្លែចេកគេ បាត់សាគូគេ សួរថាពីណាអ្នកនេះ អាហ្នឹងវាអ៊ីចឹង។

**ស៖** ខ្ញុំយល់ហើយ ចម្លើយរបស់លោកច្បាស់លាស់សម្រាប់ខ្ញុំហើយ។ ប៉ុន្តែអ៊ីចេះបញ្ហាទោសស្រាល ទោសធ្ងន់ លោកដឹងពីទោសស្រាល ទោសធ្ងន់នេះ លោកដឹងអ៊ីចឹងដោយសារតែលោកបានទៅវត្តអូរត្រកួន ឬយ៉ាងណា? ពិបាកបន្តិចសំណួរនេះ។

**ឆ៖** បាទ ពេលដែលយកទៅអូរត្រកួន គឺខ្ញុំអត់ដឹងថាទោសអីយ៉ាងម៉េចៗទេ ព្រោះខ្ញុំមិនអ្នកសរសេរកំណត់ហេតុ ឬក៏មេអ្នកកាន់ខាងហ្នឹងដែរ ខ្ញុំអត់បានដឹង។ មិនដឹងជាទោសអី លួចអីត្រឹមណាត្រូវយកមក ឬក៏ស្អីត្រឹមណា ប៉ុន្តែខ្ញុំតាមដឹង គឺកងចល័តហ្នឹងគាត់គេយកទៅ។ គេយកទៅអ៊ីចឹង ខ្ញុំសួរថាមានរឿងអ៊ីចឹងទៅ ព្រោះវា គេដាក់ប្រហែលជាមួយអាទិត្យទេ។ ខ្ញុំសួរថា រឿងអីបានគេចាប់យកមក? អាមួយដេញដោលថា អ្ហែ!លួចខ្នុរគេ យកខ្នុរគេស៊ី ជាក្រុមអ៊ីចឹងទៅ គេដឹងគេហៅមកដាក់ទណ្ឌកម្មអ៊ីចឹងទៅ ដាក់គុកពីរបីអាទិត្យអ៊ីចឹងទៅណ៎ា ឧទាហរណ៍ថាអ៊ីចឹង។ ប៉ុន្តែខ្ញុំមិនដឹងថាដាក់ប៉ុន្មានថ្ងៃ អីប៉ុន្មានថ្ងៃទេ។ ប៉ុន្តែមានៗប្រហែលកងចល័តហ្នឹងមានស្រីៗជាប់នៅនឹងអូរត្រកួនហ្នឹង ហើយខ្ញុំលបសួរទៅ ថាមានរឿងអីបានគេចាប់ចែងងមកអ៊ីចឹងទៅណ៎ា រួចថាលួចខ្នុរយកមកស៊ីជាក្រុមអីហ្នឹងបានអី។ យើងមិនដឹង រួចគេបាត់ខ្នុរ គេសួរថាអត់ដឹងៗ ដល់គេតាមដានដឹងទៅក៏គេហៅមកអ៊ីចឹង។

[១៥:៤២:២៦]

**ស៖** សូមអរគុណលោកសាក្សី។ តែវា<ច្បាស់ណាស់>ដែលថាលោកមិនបានឃើញការសម្លាប់ណាមួយនៅវត្តអូរត្រកួននោះ។ មុនថ្ងៃ០៧ មករា ១៩៧៩ ឬក៏ក្រោយថ្ងៃ០៧ មករា ១៩៧៩ តើ<លោកធ្លាប់ឮថា តើ>ក្រុមសន្តិសុខនៅវត្តអូរត្រកួននេះជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្សដែរទេ? តើ<លោកធ្លាប់ឮឈ្មោះ>អ្នកដែលធ្វើការនៅមន្ទីរសន្តិសុខវត្តអូរត្រកួនដែលលោកបានឃើញ បានជួបហ្នឹង អាចជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្សដែរទេ?

**ឆ៖** សំណួរដូចវែងពេកហើយ ស្ដាប់ន័យមិនចង់បានទេ មិនបាន។

**ស៖** សូមអភ័យទោស។ តើលោកធ្លាប់ឮគេនិយាយឈ្មោះអ្នកធ្វើការនៅវត្តអូរត្រកួនហ្នឹង ធ្លាប់ឮឈ្មោះខ្លះទេ? ហើយធ្លាប់ឮគេនិយាយថាអ្នកទាំងហ្នឹងពាក់ព័ន្ធនឹងការសម្លាប់មនុស្សដែរទេ?

**ឆ៖** ធ្លាប់ឮគេនិយាយដែរ។ ធ្លាប់ឮគេនិយាយថាសម្លាប់អីអ៊ីចឹង ប៉ុន្តែមនុស្សទុំងគឺស្លាប់ដែរហើយ។ អ្នកដែលសម្លាប់គេហ្នឹង គឺស្លាប់ដោយខ្លួនឯងដែរ។

**ស៖** តើការដែលលោកឮនេះ លោកឮក្រោយឆ្នាំ១៩៧៩ ឬក៏យ៉ាងណា?

**ឆ៖** ពេលដែលដាច់ហើយហ្នឹង។ ពេលដែលដាច់ហើយហ្នឹង ឮគេថាមនុស្សឈ្មោះ ហាន ហ្នឹងគឺស្លាប់ហើយ។ ហើយសព្វថ្ងៃក៏ដឹងថាឈ្មោះហ្នឹងក៏អត់នៅដែរ ព្រោះស្លាប់ដែរ ព្រោះខ្ញុំអ្នកស្រុកកំណើតផ្សេង ហើយខ្ញុំមក គេចាត់ខ្ញុំឱ្យមកនៅបង្រៀននៅកន្លែងវត្តអូរត្រកួនតែម្ដង គឺដឹងថាឈ្មោះហ្នឹងស្លាប់មែន។

[១៥:៤៥:២១]

**ស៖** លោកសាក្សីនៅពេលមួយនោះ គឺលោកត្រូវបានសួរថា តើធ្វើម៉េចទើបលោកអាចដឹងថាអ្នកទោសខ្លះជាចាម? ហើយលោកឆ្លើយថា លោកអត់បាន<ឃើញពួកគេទេ ហើយបន្ទាប់មកលោកនិយាយថា លោកមិន>ឮគេសួរចម្លើយអំពីជីវប្រវត្តិអ្នកទាំងនោះទេ ប៉ុន្តែលោក<ថា លោក>បានសាកសួរអ្នកធ្វើការនៅផ្ទះបាយ។ តើធ្វើម៉េច សូមលោកជម្រាបជូនតុលាការបន្តិចមកថា តើធ្វើម៉េចបានជាអ្នកធ្វើការនៅរោងបាយហ្នឹង ដឹងពីជីវប្រវត្តិរបស់អ្នកទោស?

**ឆ៖** បាទ ព្រោះតាមការពិតគឺអ្នកនោះឯងគឺបាននៅយូរហើយ មិននៅពីអង្កាល់ណាមក គឺខ្ញុំអត់ដឹង ខ្ញុំចូលទៅហ្នឹងឃើញ យើងក្មេងៗចេះតែសួរអីលេងសើចអ៊ីចឹងណ៎ា។ សួរ រួចយើងគ្រាន់តែឮថាកន្លែងហ្នឹងយើងវាស្គុតអស់ហើយ ប៉ុន្តែដល់អ៊ីចឹងយើងសួរតិចៗ បង្អើប មិនសួរហ៊ានឱ្យវាម៉ាត់ណ៎ាព្រោះយើងវានៅស្ទើរជាការសួរអ៊ីចឹងដែរ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយរបស់ខ្ញុំ តើលោកនៅចាំថា លោកបាននិយាយអំពីបទល្មើសសីលធម៌ពីមនុស្សម្នាក់ដែលលោកនិយាយថា នៅអូរត្រកួននេះបានប្រព្រឹត្តបទល្មើសខុសសីលធម៌ ឈ្មោះ បុត្រ?

**ឆ៖** ពេលនោះខ្ញុំដឹងហ្នឹងតាមខ្សែរយៈចុងភៅនៅទុំងដែរ ចុងភៅគេនៅដាំស្លអីឱ្យពួកអ្នកងារវែងហ្នឹងអ្នកនៅកន្លែងហ្នឹង ហើយនារីហ្នឹងឯងគឺអនុប្រធានដែរ បុត្រ ហ្នឹងគឺជាអនុប្រធានសន្តិសុខ ហាន ហ្នឹង។ អ៊ីចឹងវាកាន់កូនសោអ៊ីចឹង វាទៅស្រឡាញ់នារីហ្នឹង។ ដល់ស្រឡាញ់នារីហ្នឹង ក៏មករាយការណ៍ប្រាប់មេប្រធានចុងភៅហ្នឹង ស្រីៗដូចគ្នាមកប្រាប់ ហាន ហ្នឹងក៏យប់ហ្នឹងក៏គេចាប់ បុត្រ ហ្នឹងទៅសម្លាប់ចោលទាំងពីរហ្នឹង។ ហើយខ្ញុំឮនិយាយទៀត មេហ្នឹងថា អញជិតលែងហើយអ៊ីចឹង ប៉ុន្តែគាត់អត់មាន

កំហុសអីទេ មិនដែល -- អនុប្រធានគឺទៅចាប់រំលោភបងស្រីហ្នឹង។ ដល់អ៊ីចឹងចុងភៅហ្នឹង ស្រីៗគ្នាគាត់ហ្នឹង គាត់មករាយការណ៍ឲ្យ មកប្រាប់មេ ហាន ហ្នឹង។ យប់ហ្នឹងគេចាត់គ្នាគេហ្នឹង ចាប់ បុត្រ ហ្នឹងទៅសម្លាប់ហ្នឹងទៅ។ ងាប់ទាំងពីរនាក់ហ្នឹងទៅ។

[១៥:៤៨:៥៩]

**ស៖** ការសម្លាប់<ឈ្មោះបុត្រ និងអ្នកទោសស្រី>នេះ ខ្ញុំក៏យល់ឃើញថាលោកក៏មិនបានឃើញដោយផ្ទាល់ភ្នែកដែរ។ តើ<ខ្ញុំយល់ត្រឹមត្រូវ>ទេ?

**ឆ៖** គាត់ជាអ្នកទោសស្រី។

**ស៖** ខ្ញុំស្ដាប់<យល់>ហើយ ប៉ុន្តែលោកថា បុត្រ ហើយអ្នកទោសស្រីម្នាក់ហ្នឹងត្រូវបានគេយកទៅសម្លាប់ចោលទាំងពីរ។ សំណួរខ្ញុំសួរថា តើលោកពិតជាបានឃើញគេសម្លាប់ បុត្រ ហើយនិងអ្នកទោសស្រីហ្នឹងដោយផ្ទាល់ភ្នែកដែរ ឬក៏អត់ទេ?

**ឆ៖** ពេលនោះគឺខ្ញុំអត់បានឃើញទេ ប៉ុន្តែគ្រាន់ថា ដឹងដំណឹងថាគេចាប់ បុត្រ ហ្នឹងហើយ។ ដល់ក្រោយមកវាៗ បាត់សូន្យទៅតែម្ដងទៅណា បាត់ទាំងអស់កាលនុ៎ង តែម្ដងទៅ។ ព្រោះតែណាដល់គេចាប់ហើយ គ្មានអីរស់ទេនៅកន្លែងនោះ អត់ៗងាយរស់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៥:៥០:៥៣]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៅកាន់លោក ក្នុងឋានៈខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន។ ជាដំបូងខ្ញុំចង់ឲ្យបានដឹងច្បាស់អំពីកាលបរិច្ឆេទ ខ្ញុំដឹងថាលោកមិនចាំអំពីកាលបរិច្ឆេទ

ច្បាស់ទេ ក៏ប៉ុន្តែខ្ញុំនឹងព្យាយាមសួរដើម្បីឲ្យលោកអាចចំណាំពេលវេលាបាន។ លោកៗកើតនៅភូមិអន្លង់អក គឺជាភូមិកំណើតរបស់លោក។ អ៊ីចឹងមែនទេ ភូមិអន្លង់អក?

**លោក មុយ វ៉ាន់នី៖**

**ឆ៖** បាទ ពិតប្រាកដ។

**ស៖** អម្បាញ់មិញនេះលោកបានឆ្លើយថា មុនវៀតណាមវាយចូល លោកបានរត់គេចទៅភូមិកំណើតរបស់លោកវិញ។ អ៊ីចឹងលោករត់ទៅហ្នឹង លោករត់ទៅភូមិអន្លង់អកហ្នឹងមែនទេ ពេលដែលលោកដឹងថាវៀតណាមវាយចូលមកនោះ?

**ឆ៖** បាទ ខ្ញុំរត់ទៅភូមិកំណើតរបស់ខ្ញុំវិញ។

[១៥:៥២:២១]

**ស៖** មុនពេលលោករត់ទៅភូមិកំណើត លោកនៅកន្លែងណា? ហើយពេលហ្នឹងលោកមានមុខងារអ្វី? លោកនៅវត្តអូរត្រកួន ឬក៏លោកនៅកន្លែងណាផ្សេង មុនពេលលោករត់ទៅភូមិកំណើតវិញនោះ?

**ឆ៖** បាទ ខ្ញុំរត់ទៅភូមិកំណើតតែម្តង។ ពេលនោះគឺថា ដឹងថាវៀតណាមចូលហើយ គឺគេបែកគ្នាទាំងអស់ រកផ្លូវរៀងខ្លួន។ អ៊ីចឹងខ្ញុំត្រូវទៅស្រុកកំណើតរបស់ខ្ញុំវិញ ព្រោះកាលនោះគឺយើងបែកគ្រួសារ ឪពុកម្តាយអីហ្នឹងណ៎ា មិនងាយបានមកជួបជុំទេ ដល់ឮអ៊ីចឹងទៅ យើងមាន កងទ័ពវៀតណាមចូលជួយអ៊ីចឹងទៅ យើងក៏រត់ទៅផ្ទះទៅ អាអ្នកនៅណារត់ខ្ចេចខ្ចី អស់រលីងទៅ មិនដឹងទៅខាងណាខាងណី។

**ស៖** ខ្ញុំយល់ហើយអំពីចំណុចនេះ ក៏ប៉ុន្តែខ្ញុំមិនចង់សួរលោកអ៊ីចឹងទេ។ ខ្ញុំចង់ដឹងថា ពេលដែលលោកដឹងថាវៀតណាមវាយចូលមកនោះ លោកនៅកន្លែងណា? គឺលោករត់ទៅភូមិកំណើតរបស់លោកហ្នឹង លោករត់ចេញពីកន្លែងណា?

**ឆ៖** ខ្ញុំរត់ចេញពីកន្លែងតំបន់ដែលទៅពាមជីកងហ្នឹង។ នៅពាមជីកងហ្នឹង ខ្ញុំដឹងថាកងទ័ពវៀតណាមចូលហើយ ក៏ខ្ញុំអត់មានចូលកន្លែងវិញទេ ព្រោះវាសុទ្ធតែម្នាក់ៗបបួលគ្នាថា យើងធ្វើម៉េចទៅដល់ផ្ទះ។ អ៊ីចឹងយើងត្រូវតែទៅដល់ អត់មានទៅឯណា ជាមួយពីណាពីណីទៀតផង គឺនឹកផ្ទះជាងអីទៀត នឹកឪពុកម្តាយ។

[១៥:៥៤:៣០]

**ស៖** សូមលោកស្តាប់សំណួរខ្ញុំឲ្យបានច្បាស់មុននឹងលោកឆ្លើយ។ លោកថាលោកនៅពាមជីកង ដូច្នេះខ្ញុំចង់ដឹងថាពេលដែលលោកស្តាប់ឮថាវៀតណាមវាយចូលហ្នឹង លោកនៅក្នុងវត្តអូរត្រកួនហ្នឹង មែនទេ? <តើលោកនៅធ្វើការនៅវត្តហ្នឹងទេ?>

**ឆ៖** ពេលនោះ គឺខ្ញុំអត់មាននៅវត្តអូរត្រកួនទេ ព្រោះឈ្មោះ ហាន ហ្នឹងគេបញ្ជាទ័ពឲ្យយកទៅទប់នៅពាមជីកងហ្នឹង។ ដល់ទប់មិនឈ្នះ ដូចថាវៀតណាមចេះតែមកច្រើនអ៊ីចឹងទៅ ក៏វា អាទ័ពនុ៎ងក៏វាប្រផាប់ពភឹងអស់ទៅណា ព្រោះវាអត់ជុំពេលនោះ ដោយទ័ពវាតិច ក្នុងស្រុកនុ៎ងវាតិច។ អ៊ីចឹងក៏សម្រេចចិត្តថា នាំគ្នាត្រូវទៅតាមផ្ទះរៀងខ្លួន ហើយវានុ៎ងក៏ទៅតាមដំណើរនុ៎ងដែរ មិនដឹងទៅខាងណាខាងណីមេហ្នឹង។ ធ្វើតែបន្លំទៅបត់ជើងតិចទៅ សៀរៗប្រូច។ ធ្វើម៉េចឲ្យតែថា កុំឲ្យគេឃើញកុំឲ្យមេហ្នឹងដឹងថាយើងរត់។ ទទួលគេជោគជ័យអ៊ីចឹងទៅ ក៏យើងវាបានដល់ថ្ងៃហ្នឹងដែរ។

**ស៖** ខ្ញុំមិនដឹងថាមានបញ្ហាបកប្រែ ឬក៏យ៉ាងម៉េច។ លោកបាននិយាយអំពីមនុស្សម្នាក់ ក៏ប៉ុន្តែខ្ញុំមិនចង់សួរអំពីមនុស្សម្នាក់ហ្នឹងទេ។ <នៅក្នុងសំណួរខ្ញុំ ខ្ញុំមិនបាននិយាយអំពីនរណាម្នាក់ទេ ដូច្នេះសូមលោកប្រាប់ខ្ញុំ បើសិនណា>លោកនិយាយ<អំពី>ឈ្មោះ ហាន <តើឈ្មោះ> ហាន <ក៏បាន>រត់<គេចខ្លួន>ដែរឬ<>?

**ឆ៖** បាទ ពេលនោះគឺរត់បែកគ្នា។ រត់ជាមួយគ្នាមែន ក៏ប៉ុន្តែដល់ពេលនោះគឺបែកគ្នា ម្នាក់ៗដូចថា អ្នើខ្ញុំបត់ជើង ហើយយើងមានចាំណាំ យើងទៅ គេទៅមុខ មេគេទៅមុខ។ រួចខ្ញុំចេះតែបង្វែងដាន ដើម្បីធ្វើម៉េចឲ្យបញ្ចៀសឲ្យផុតពីការទៅជាមួយមេហ្នឹង។

[១៥:៥៧:០៣]

**ស៖** ដូច្នេះមានន័យថា ពេលដែលលោកដឹងថាវៀតណាមជិតចូលមកហើយហ្នឹង លោកនៅតែធ្វើការឲ្យ ហាន ដដែល មែនទេ?

**ឆ៖** បាទ នៅជាមួយហ្នឹង ប្រហែលជាពីរបីថ្ងៃអីដែរ ម៉ែ្វហ្នឹងបើតាមមើល ពីរថ្ងៃបីថ្ងៃ តាមស្មានមើល។ តាមពិតទៅប្រហែលជាពីរថ្ងៃ ១ហ្នឹងគឺខ្លាំងហ្មង គឺត្រូវតែរត់ទ័ព បាក់ទ័ពអស់រលីងហើយមានទ័ពណានៅទៀត។ ដល់ទៅត្រៀមនុ៎ងទៅ ក៏គេចេះបណ្តោះៗអស់រលីងទៅ រាងស្បើយទ័ព អាមេនុ៎ងក៏ព្រូចទៅ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីកាលបរិច្ឆេទម្តង។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា និងសំណួររបស់មេធាវី កូប៉េ លោកថា លោកធ្វើការឲ្យ

ហន ហ្នឹងប្រហែលជាប្រាំទៅប្រាំមួយខែ។ អ៊ីចឹងមានន័យថា ប្រាំប្រាំមួយខែមុនបែករបបខ្មែរក្រហម មែនទេ? <ដូច្នេះតើយើងយល់ស្របគ្នាទេថា ការកំណត់រយៈពេលនេះ គឺមុនពេលចប់របបនុ៎ង?>

**ផ៖** បាទ មុនខ្មែរក្រហម។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅរយៈកាលមួយផ្សេងទៀត។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកបាននិយាយអំពីការងារពីរ។ ដំបូងគឺលោកធ្វើការនៅកងកុមារ និងបន្ទាប់មកទៀតលោកធ្វើការនៅក្នុងកងចល័តថ្នាក់ស្រុក ហើយដែលក្នុងនោះមានអ្នកដែលធ្វើការនោះមានអាយុពី២០ ទៅ៣០ឆ្នាំ។ តើលោកចាំទេថា លោកបាននិយាយអំពីកងពីរហ្នឹងជាមួយហ្នឹងសហព្រះរាជអាជ្ញា គឺកងកុមារ និងកងចល័តស្រុក?

[១៥:៥៩:២៧]

**ផ៖** កងកុមារហ្នឹង គឺបានន័យថាកងកុមារនៅតាមឃុំ។ ដល់មានបញ្ហានៅក្នុងអង្គភាពកុមារហ្នឹងទៅ ដូចថាគេស្អប់យើង គេបញ្ជូនយើងទៅកងចល័តស្រុក។ ឲ្យទៅរែកដីជាមួយគេអីអ៊ីចឹង ដូចថាខ្ញុំតូចជាងអ៊ីចឹង គេធំពីរនាក់ ខ្ញុំម្នាក់អ៊ីចឹងទៅ ខ្ញុំអ្នកអីអ៊ីចឹងទៅ ហើយបើគេៗផ្សេង។ ហើយនៅអង្គភាពកុមារឃុំនោះ ហ្នឹងវាស្រួលបន្តិច។ វាមិនស្រួលអីប៉ុន្មានទេ វាគ្រាន់ថាវាមិនរែកដី គ្រាន់តែថាធ្វើជីទៅ រកកណ្តុរអីអ៊ីចឹងទៅ មើលទប់ទឹកទប់អីកុំឲ្យអីចេញអ៊ីចឹង អាហ្នឹងនៅតាមឃុំ។ ដល់កងចល័តស្រុក អាហ្នឹងវាខ្លាំង។ អាហ្នឹងគេហៅថា អ្នកប្រយុទ្ធហើយអាហ្នឹង ប៉ុន្តែយើងវានៅខ្ចី។

**ស៖** លោកសាក្សី ល្ងាចណាស់ទៅហើយ ដូច្នេះខ្ញុំសុំឲ្យលោកស្តាប់សំណួរឲ្យបានច្បាស់ ខ្ញុំសួរអីសូមឲ្យលោកឆ្លើយហ្នឹង ខ្ញុំអត់ចង់ឲ្យលោកឆ្លើយវែងអន្លាយទេ។ ប្រហែលជាលោកស្តាប់សំណួរខ្ញុំមិនយល់ ឬក៏យ៉ាងម៉េច? ខ្ញុំគ្រាន់តែសួរលោកថា លោកបានចាំថា លោកបាននិយាយអំពីការងារទាំងពីរនេះ គឺកងចល័ត និងកងកុមារជាមួយនឹងសហព្រះរាជអាជ្ញា លោក<ឆ្លើយ>អ៊ីចឹង។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីកងកុមារឃុំ លោកចាំទេថា លោកចាប់ផ្តើមធ្វើការនៅក្នុងកងកុមារឃុំហ្នឹងនៅឆ្នាំណា លោកចាំទេ?

**ផ៖** ខ្ញុំអត់បានចាំទេ ឲ្យតែថាកុមារ គឺអង្គភាពកុមារឃុំអ៊ីចឹង។ មិនដឹងឆ្នាំណាអីឆ្នាំណាគឺខ្ញុំអត់ចាំ។

**ស៖** លោកបាននិយាយជាមួយសហព្រះរាជអាជ្ញា អំពីការចាប់ខ្លួនជនជាតិចាមនៅក្នុងកងមួយ។ ខ្ញុំមិនដឹងថាតើការចាប់ជនជាតិចាមហ្នឹង នៅពេលដែលលោកនៅក្នុងកងកុមារ ឬក៏នៅក្នុងកងចល័តស្រុកដែលលោកថា មានអាយុពី២០ ទៅ៣០ឆ្នាំហ្នឹង? លោកអាចបញ្ជាក់បានទេថា ការចាប់ខ្លួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជនជាតិចាមហ្នឹងនៅក្នុងពេលដែលលោកធ្វើការនៅកងមួយណា កងកុមារ ឬក៏កងចល័តស្រុក?

[១៦:០២:២៨]

**ឆ៖** បាទ ពេលដែលខ្ញុំដឹងថា ចាប់ចាមហ្នឹងគឺកងចូលក្នុងចល័តស្រុកហើយ។

**ស៖** លោកប្រធាន ខ្ញុំឃើញថាម៉ោងជិតដល់ហើយ ប្រហែលជាសំណួរចុងក្រោយសម្រាប់រសៀលនេះ។ សហព្រះរាជអាជ្ញាបាននិយាយអំពីកុមារពាក់ព័ន្ធនឹងអ្នកដែលត្រូវបានគេចាប់ខ្លួន ប៉ុន្តែលោក១ថាអ្នកដែលចាប់ខ្លួននោះ មានអាយុពី២០ ទៅ៣០ឆ្នាំ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ ថាអ្នកដែលគេចាប់ខ្លួនហ្នឹង ជនជាតិចាមហ្នឹងជាកុមារ ឬក៏ជាយុវជន?

**ឆ៖** គាត់ជាយុវជន ព្រោះកាលណាចាប់ពីអាយុច្រើនទៅហើយ ចូលយុវជនហើយ។ ជំនាន់នោះមិនដឹងគេហៅស្អីផង គេថាកងចល័ត ៗហ្នឹងគេទៅ ប៉ុន្តែមិនដឹងគេថាចាប់ពីប៉ុន្មានអីប៉ុន្មាន គេអត់កំណត់ មិនដឹងម៉េច។

**ស៖** អ៊ីចឹងគឺលោកឯកភាពទេថា អ្នកទាំងអស់ហ្នឹងមិនមែនជា<សមាជិកក្នុងកង>កុមារទេ មែនទេ?

**ឆ៖** បាទ គាត់មិនមែនជាកុមារទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសុំបញ្ចប់សម្រាប់រសៀលនេះ លោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១២ ខែមករា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី មុយ វ៉ាន់នី បញ្ចប់ ហើយនឹងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្ស-នាម 2-TCW-988 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះអរគុណលោក មុយ វ៉ាន់នី។ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នក

ជំនាញជូនលោក មុយ វ៉ាន់នី រួមទាំងសាក្សីបម្រុង 2-TCW-988 ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងសូមឲ្យអញ្ជើញពួកគាត់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*